ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ត្រូវតែប្រឈមមុខនឹងអតីតកាល
- ការអភិវឌ្ឍន៍ដ៏ធំសម្រាប់យុត្តិធម៌ក្នុងជាតិ

លេខ៩៨ ខែមិថុនា ឆ្នាំ២០០៨

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៥៤ ខែមិថុនា ឆ្នាំ២០០៤

## មាតិកា


- សំបុត្រៈ ត្រូវតែប្រឈមមុខនឹងការពិត................................ ១

**ផ្នែកឯកសារ**

- លាវ ហ្វូសែ អតីតលេខាធិការរបស់ ឡុង បូរ៉េត......................២
- កិច្ចសន្ទនារបស់សមមិត្តប៉ុលពត..........................................៤
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ............៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- បើថ្នាក់លើអត់ដឹងពីការសម្លាប់ប្រជាជន.............................. ១១
- ខ្ញុំចង់សងសឹក...............................................................១២
- ជនរងគ្រោះម្នាក់នៃរបបខ្មែរក្រហម....................................១៤
- បានត្រឹមតែលីដែកប្រហោងមួយជីវិត...............................១៦
- ព្រះតេជគុណ ប៉ែន សេន...............................................១៨

**ផ្នែកច្បាប់**

- ច្បាប់កម្ពុជាទាក់ទងនឹងដីកាចាប់ខ្លួន.....................................២១

**វេទិកាពិភាក្សាសាធារណៈ**

- ឆ្លើយតបទៅនឹងអត្ថបទ.....................................................២៣
- ការអភិវឌ្ឍន៍ដ៏ធំសម្រាប់យុត្តិធម៌អន្តរជាតិ..........................២៤
- តុលាការព្រហ្មទណ្ឌអន្តរជាតិ...........................................២៩
- ការលំបាកក្នុងការកសាងសន្តិភាពនៅកម្ពុជា..........................៣៦
- ជុំវិញការកាត់ទោស សាដាម ហ៊ូសេន..................................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- ស្រមោលបង................................................................៥០




អ្នកទោសមន្ទីរស-២១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, លី សុខឃាង, ព្រុំ ដល្លា, ហេង សុខដាន់ណា, អៀ ម៉េងទ្រី, ទូច បូរ៉ា, វ៉េម៉ិន ចូហាន់សិន, អាន់តូនីញ៉ូ ខាសសេ, អាន់តូនី ដកឃីន, ម៉ារី ឡាប៊ីក **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូហ្វារីណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្លូ ប៊ុនស៊ី **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ត្រូវតែប្រឈមមុខនឹងការពិត

បច្ចុប្បន្ន ខ្មែរក្រហមចូលចិត្តនិយាយអំពីការបំភ្លេចអតីតកាល ប៉ុន្តែ កាលពីខ្លួនកាន់កាប់អំណាច ខ្មែរក្រហមបែរជាមិនដែលបំភ្លេចចោលនូវអតីតកាលទៅវិញ ។ ខ្មែរក្រហមចងចាំមនុស្សគ្រប់រូបនៅក្នុងរបបមុន ហើយព្យាយាមសម្លាប់អ្នកទាំងនោះមិនឲ្យសល់ម្នាក់ ។

ខ្មែរក្រហមបច្ចុប្បន្ននេះក៏ចូលចិត្តនិយាយអំពី «ការផ្សះផ្សាជាតិ» ប៉ុន្តែនៅក្នុងរបបដែលខ្លួនដឹកនាំ ខ្មែរក្រហមមិនដែលចង់ផ្សះផ្សាជាមួយនរណាម្នាក់ឡើយ ។ អ្នកណាដែលគោរពបញ្ញាអង្គការគឺរស់ មិនគោរពបញ្ញាអង្គការគឺស្លាប់ ។

ខ្មែរក្រហមចូលចិត្តនិយាយថាការអភិវឌ្ឍន៍សេដ្ឋកិច្ចគឺជាអាទិភាពតែមួយគត់ ប៉ុន្តែហេតុផលដែលធ្វើឲ្យសេដ្ឋកិច្ចអន់ថយយ៉ាងនេះ គឺពីព្រោះតែខ្មែរក្រហមបានបំផ្លាញសេដ្ឋកិច្ចជាតិទាំងស្រុងមិនមែនកសាងសេដ្ឋកិច្ចទេ ។ ខ្មែរក្រហមចូលចិត្តនិយាយថា «ស្ថិរភាព» និង «ការរក្សាសន្តិភាព» មានសារសំខាន់បំផុត ប៉ុន្តែខ្មែរក្រហមបែរជាគំរាមបញ្ឆេះភ្លើងសង្គ្រាមដើម្បីបំភិតបំភ័យប្រជាជនមិនឲ្យបង្ហាញនូវសេចក្តីស្រេកឃ្លានយុត្តិធម៌ទៅវិញ ។ ហេតុនេះ ខ្ញុំគិតថាខ្មែរក្រហមមិននិយាយដោយស្មោះត្រង់ទេ ហើយក៏មិននិយាយការពិតចេញពីបេះដូងដែរ ។ ខ្មែរក្រហមបរិយាយដោយប្រើប្រាស់ពាក្យកាត់បង្កើតឡើងដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ជាជាងសម្រាប់ផលប្រយោជន៍ជាតិទាំងមូល ។

ដើម្បីសន្តិភាពពិតប្រាកដ ការផ្សះផ្សាជាតិពិតប្រាកដ ការអភិវឌ្ឍន៍ពិតប្រាកដ និងស្ថិរភាពពិតប្រាកដ កម្ពុជាត្រូវតែប្រឈមមុខនឹងការពិត ហើយស្វែងរកយុត្តិធម៌ ។ បុព្វហេតុនេះអាចសម្រេចបានលុះត្រាណាតែជនទាំងឡាយដែលបានទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ត្រូវបាននាំឡើងតុលាការ ហើយបកស្រាយពន្យល់និងការពារទង្វើរបស់ខ្លួននៅចំពោះមុខប្រជាជន ។ មានតែធ្វើយ៉ាងនេះទេ ទើបប្រជាជនកម្ពុជាអាចបំភ្លេចចោលនូវអតីតកាលដ៏ជូរចត់ ហើយចាប់ផ្តើមកសាងអនាគតថ្មីមួយ ។ របបប្រល័យពូជសាសន៍ខ្មែរក្រហមត្រូវបានផ្តួលរំលំនៅក្នុងសង្គ្រាម ប៉ុន្តែមិនទាន់ត្រូវបានផ្តួលរំលំដោយច្បាប់ ។ កម្ពុជាមិនអាចក្លាយទៅជាជាតិមួយដែលមានធម្មាធិបតេយ្យបានទេ លុះត្រាតែការផ្តួលរលំដោយច្បាប់កើតឡើង ។ បើគ្មានធម្មាធិបតេយ្យ កម្ពុជាក៏មិនអាចអភិវឌ្ឍន៍ជាតិឲ្យបានសុខសាន្តនិងរុងរឿងបានដែរ ។




**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# លាវ ហួសែ អតីតលេខាធិការរបស់ ឡុង បូរ៉េត


លាវ ហួសែ

លាវ ហួសែ ជាបុគ្គលិកក្រសួងឃោសនាការនិងជានាយលេខាធិការដ្ឋានរបស់ ឡុង បូរ៉េត នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ ហួសែ មានស្រុកកំណើតនៅភូមិព្រែកស្វាយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ។ ហួសែ រៀបការពីរដង ។ គាត់បានលែងលះប្រពន្ធទី១ ហើយបានរៀបការម្ដងទៀតជាមួយនារីម្នាក់ដែលជាបុគ្គលិកនៅក្នុងក្រសួងឃោសនាការជាមួយគ្នា ។ ក្រោមការគ្រប់គ្រងរបស់អង្គការបដិវត្តកម្ពុជា ហួសែ ត្រូវបានជម្លៀសទៅកាន់ខេត្តបាត់ដំបង និងត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ពីបទចោទប្រកាន់ថាគាត់ជាសេ.អ៊ី.អា និងមានផែនការរត់ទៅប្រទេសថៃ ។

ហួសែ បានចម្រើនវ័យនៅក្នុងខេត្តកណ្ដាល ។ នៅពេលមានអាយុ១៥ឆ្នាំ ហួសែ បានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សាព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ហើយមកបន្តការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិភ្នំពេញ ។ នៅឆ្នាំ១៩៥១ ហួសែ ឈប់រៀន ហើយទិញរថយន្តមួយគ្រឿងដឹកទំនិញលក់ ។ បន្ទាប់មក ហួសែ ត្រូវចាស់ទុំចាត់ចែងរៀបការជាមួយនារីម្នាក់ឈ្មោះ អេង បួយហួរ ។

ឆ្នាំ១៩៥៦ ហួសែ បានបោះបង់របររកស៊ីហើយមកបម្រើការនៅក្រសួងឃោសនាការ បានទទួលប្រាក់ខែចំនួន៣ពាន់រៀល ។ នៅខែឧសភា ឆ្នាំ១៩៥៩ ហួសែ ត្រូវបានក្រសួងចាត់តាំងឲ្យទៅហ្វឹកហ្វឺនជំនាញផ្នែកបោះពុម្ពអក្សរនិងសៀវភៅនៅប្រទេសបារាំងរយៈពេលបីខែកន្លះ ។ នៅខែមករា ឆ្នាំ១៩៦០ ហួសែ បានទៅទស្សនកិច្ចរោងពុម្ពកាសែតនិងកន្លែងតម្កល់ឯកសារនៅប្រទេសជប៉ុនរយៈពេលមួយសប្ដាហ៍ រួចបន្តទៅទស្សនាកន្លែងថតខ្សែភាពយន្តនិងស្ថានីយ៍ផ្សាយវិទ្យុនៅប្រទេសហ្វីលីពីនមួយសប្ដាហ៍ទៀត ។ បន្ទាប់ពីគាត់បានលែងលះជាមួយប្រពន្ធ នៅចុងឆ្នាំ១៩៦០ ហួសែ បានរៀបការជាមួយនារីម្នាក់ទៀតឈ្មោះ អ៊ុក អ៊ីវន ជាបុគ្គលិកក្រសួងឃោសនាការជាមួយគ្នា ។

ហួសែនិងភរិយាមានកូនចំនួន៧នាក់ ប្រុសបួននាក់និងស្រីបីនាក់ ។ ដោយមានការលំបាកក្នុងការថែរក្សាកូនៗ អ៊ីវន បានលាលែងពីការងារមកធ្វើជាមេផ្ទះ ។ នៅឆ្នាំ១៩៦២ ហួសែ បានទទួលប្រាក់បៀវត្សរ៍ចំនួន៥ពាន់៥រយរៀល ។ ក្រៅពីការងារនេះ ហួសែ បានស្វែងរកការងារផ្សេងទៀតធ្វើដើម្បីបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារ ។

នៅឆ្នាំ១៩៦៩ ហួសែ បានចូលជាសមាជិកសេ.អ៊ី.អា តាមការណែនាំរបស់ឈ្មោះ ឆាំង សុង និង កែម សារ៉ាត ដែលមានទីស្នាក់ការនៅស្ថានទូតអាមេរិក ។ ហួសែ បានទទួលប្រាក់ខែពីអង្គការសេ.អ៊ី.អាចំនួន២ម៉ឺន៥ពាន់រៀលក្នុងមួយខែ ។

នៅក្នុងឆ្នាំ១៩៧០ ហួសែ បានចាប់ផ្ដើមសកម្មភាពខ្លាំងក្លាដោយអញ្ជើញអ្នកកាសែតបរទេសមួយចំនួនទៅស៊ីផឹក ហើយបញ្ចុះបញ្ចូលឲ្យអ្នកទាំងនោះជួយគាំទ្ររដ្ឋាភិបាលលន់ណុល ។ ហួសែ បានឧបត្ថម្ភជាប្រាក់ដល់អ្នកកាសែតក្នុងស្រុកចំនួនពីរ-បីម៉ឺនរៀលរៀងរាល់សប្ដាហ៍ ។

នៅដើមឆ្នាំ១៩៧២ ហួសែ, ថោង លឹមហួង, សន ថាត, ធូថុន និង កែវ ឈួន បានអនុវត្តផែនការរបស់សេ.អ៊ី.អានៅតាមសាលារៀននិងមហាវិទ្យាល័យច្បាប់ ដើម្បីបំផុសប្រជាជននិស្សិតនិងគ្រូបង្រៀនឲ្យប្រឆាំងនឹងបដិវត្តន៍ ដូចជា បង្កើតឲ្យមានចលនាឆក់ប្លន់ប្រជាជនដែលនិយមកុម្មុយនិស្ត រួចទម្លាក់កំហុសទៅលើកុម្មុយនិស្ត និងទិញទឹកចិត្តអ្នកកាសែតឲ្យជួយគាំទ្ររដ្ឋាភិបាលលន់ណុល ហើយបន្ទុះបង្អាប់កុម្មុយនិស្ត ។ នៅខែកញ្ញា ហួសែ បានទៅបំពេញបេសកកម្មនៅអង្គការសហប្រជាជាតិ

ជាមួយ ឡុង បូរ៉េត នៅទីក្រុងញូវយ៉ករយៈពេលពីរខែកន្លះ ។

នៅឆ្នាំ១៩៧៤ ពេលត្រឡប់មកពីទីក្រុងញូវយ៉ក ហ៊ូសែ បានផ្លាស់ទៅបម្រើការនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឋានៈជាលេខាធិការផ្ទាល់របស់ ឡុង បូរ៉េត ។ នៅក្នុងឆ្នាំនេះ ហ៊ូសែ ពុំសូវមានវត្តមាននៅក្នុងប្រទេសទេ គឺតែងតែធ្វើដំណើរទៅក្រៅប្រទេសជាមួយ ឡុង បូរ៉េត ជាញឹកញាប់ ។ នៅខែកក្កដា ហ៊ូសែ បានទៅបំពេញបេសកកម្មនៅប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី និងបាងកករយៈពេលដប់ប្រាំថ្ងៃ ។ នៅខែកញ្ញា ហ៊ូសែ បានទៅទស្សនកិច្ចនៅប្រទេសអារ៉ាប់និងហ្សកដានីរយៈពេល១៥ថ្ងៃ ក្នុងគោលបំណងសុំដាក់ទូតនៅក្នុងប្រទេសនោះ ។ នៅខែវិច្ឆិកា ហ៊ូសែ បានទៅបំពេញបេសកកម្មទីក្រុងញូវយ៉កម្តងទៀត ។

ដោយសារ ហ៊ូសែ បំពេញការងារបានល្អ គាត់ត្រូវបានដំឡើងប្រាក់ខែរហូតដល់៧ម៉ឺនរៀលស្មើនឹងពីរដងកន្លះនៃប្រាក់បៀវត្សរ៍រដ្ឋការរបស់គាត់ ។

ក្រោយមកដោយឃើញសភាពការណ៍ក្នុងប្រទេសកាន់តែដុនដាប ថោង លីមហ៊ួង បានបញ្ជាឲ្យ ហ៊ូសែ ផ្អាកសកម្មភាពមួយរយៈសិន រង់ចាំបទបញ្ជាថ្មី ។

នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ វេលាម៉ោង៨ទៀបភ្លឺ ហ៊ូសែ បានទទួលទូរស័ព្ទពី ថោង លីមហ៊ួង ឲ្យមកជួបជុំគ្នានៅផ្ទះរបស់ ឡុង បូរ៉េត ដើម្បីទទួលផែនការថ្មី ។ ឃី តាំងលីម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង ហ៊ូ ទិត ទាហានស័ក្តិ៥ទទួលភារកិច្ចដឹកនាំពលទាហានរបស់ សឺង ង៉ុកថាញ់ ទៅព្រំដែនកម្ពុជា-ថៃ ប៉ុន្តែផែនការនេះត្រូវអាក់ខានទៅវិញ ដោយសារគ្មានមធ្យោបាយក្នុងការធ្វើដំណើរ ព្រោះឧទ្ធម្ភាគចក្រមួយចំនួនត្រូវអ្នកបើកបរបើកហោះគេចខ្លួនក្រោយពេលដឹងថាសភាពការណ៍ក្នុងប្រទេសមិនប្រក្រតី ។

នៅវេលាថ្ងៃត្រង់ ហ៊ូសែ បានឮវិទ្យុផ្សាយថា ឡុង បូរ៉េត និង ថោង លីមហ៊ួង បានចូលទៅបង្ហាញខ្លួននៅក្រសួងឃោសនាការ ហើយក៏ត្រូវខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃនោះតែម្តង ។ ហ៊ូសែ លាក់ខ្លួនរហូតដល់ត្រូវជម្លៀសចេញពីទីក្រុង ។

ហ៊ូសែ និងក្រុមគ្រួសារត្រូវបានជម្លៀស ឲ្យទៅរស់នៅភូមិពង្រ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបង) ។ ខ្សែបណ្តាញរបស់គាត់បែកខ្ញែកគ្នាអស់ ។ ប៉ុន្តែចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៧៥ ហ៊ូសែ បានរួមសកម្មភាពជាមួយ ថេន ជឿន, ទេស ជិនតេង និងសមាជិកក្រុមដទៃទៀត ក្នុងការចូលរួមគំនិតរៀបចំគម្រោងការបំផុសប្រជាជនឲ្យទៅរត់ចូលទឹកដីថៃតាមផែនការពីរ÷ ទី១) បំផុសប្រជាជនឲ្យលែងមានជំនឿលើអង្គការ និងទី២) ទាក់ទងអ្នកនាំផ្លូវទៅកាន់ប្រទេសថៃឆ្លងកាត់តាមខេត្តឧត្តរមានជ័យ ។ ដោយសារ ថេន ជឿន មានជំងឺធ្ងន់ ហ៊ូសែ និង ទេស ជិនតេង ជាអ្នកដឹកនាំចលនានេះ ។ ជិនតេង មាននាទីបំផុសប្រជាជនជម្លៀសប៉ែកខាងខ្មែរ, លឹម បាក់សៀង ទៅបំផុសបំផុលប៉ែកខាងប្រជាជនចិន, លឹម អ៊ី ជាអ្នកនាំផ្លូវទៅប្រទេសថៃ ។ ក្នុងការរៀបចំផែនការនេះ ក្រុមការងាររបស់ ហ៊ូសែ បានប្រជុំគ្នាចំនួន៧ដង ។

លុះដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ វិទ្យុកម្ពុជាប្រជាធិបតេយ្យបានផ្សព្វផ្សាយអំពីគម្រោងរដ្ឋធម្មនុញ្ញថ្មី ។ ហ៊ូសែ ក៏បានលើកយករដ្ឋធម្មនុញ្ញថ្មីមកពិភាក្សាជាមួយសមាជិកក្រុមរបស់ខ្លួន ។ បន្ទាប់ពីប្រជុំចប់ ហ៊ូសែ ក៏បានបែកគំនិតចេញពីគម្រោងការនេះទៅវិញ ព្រោះគាត់គិតថាគ្រួសារគាត់មានសមាជិកច្រើនមិនងាយនឹងភៀសខ្លួនបាន ។ ហ៊ូសែ ក៏ផ្អាកការប្រជុំជាមួយសមាជិកក្រុមចាប់តាំងពីពេលនោះមក ។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ អង្គការបានដាក់ទិសឲ្យគាត់ទៅរៀនសូត្រនៅភ្នំស្រុកចំនួន៥ថ្ងៃ ហើយអង្គការក៏បញ្ជូនគាត់មកមន្ទីរស-២១នៅខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២០ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីសួរចម្លើយរួច ។

**លី សុផល**

# ពាក្យស្លោកខ្មែរក្រហម

**◆ សមរភូមិ កំពង់ផែ ឃ្លាំង ដឹកជញ្ជូនជើងទឹក ជើងគោក ផ្លូវដែកនិងពាណិជ្ជកម្ម ប្តេជ្ញាខាយសម្រុកសម្រេចផែនការ១០០ភាគរយនិងឱ្យលើសថែមទៀត។**

**◆ បដិសេធ "មិត្តភាពពិសេស" "សាមគ្គីពិសេស" បោកប្រាស់របស់យួនខាតធីលេបទឹកដី។**

*(សៀវភៅទង់បដិវត្តពាក្យស្លោកប្រចាំឆ្នាំ១៩៧៨)*

(ឯកសារសន្តិបាល)

# កិច្ចសន្ទនារបស់សមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិមបក្សកម្ពុជា រដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាមួយគណៈប្រតិភូសមាគម បែលស៊ិក-កម្ពុជា

***ភ្នំពេញថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨***

***១) តើកងទ័ពទទួលរ៉ាប់រងខាងសន្តិសុខទេ?***

កងទ័ពបដិវត្តកម្ពុជាមិនមានភារកិច្ចសន្តិសុខទេ មានភារកិច្ចតែការពារប្រទេស ។ លើកលែងតែក្នុងកាលៈទេសៈណាដែលមានអគ្គការណាមួយពឹងពាក់អង្គភាពកងទ័ពណាមួយឲ្យជួយមួយដងមួយកាល ទៅរួមបំពេញភារកិច្ចសន្តិសុខ ។

***២) សន្តិសុខ:*** សន្តិសុខរបស់យើងគឺសន្តិសុខសាធារណៈរ៉ាប់រងជាមូលដ្ឋានដោយប្រជាជនខ្លួនឯង ។ ពីព្រោះនយោបាយរបស់យើងគឺបង្ការមិនឲ្យមានអសន្តិសុខជាមុន ។ បានន័យថាប្រជាជនដោះស្រាយទំនាស់តូចធំផ្សេងៗជាមុនស្រេចនៅផ្ទៃក្នុងគេ ។ គេមានរបបប្រជុំធ្វើទិតៀន-ស្វ័យទិតៀនជាប់ ដើម្បីដោះស្រាយទំនាស់ជាបន្តបន្ទាប់ ហើយដើម្បីរស់នៅសុខស្រួលជាមួយគ្នាជាអតិបរមា ។ សមាសភាពឱនថយយ៉ាងណាក៏ដោយឲ្យតែកសាងគ្នារាល់ថ្ងៃ មុខជាបានចម្រើន ។

ក្រសួងសន្តិសុខនៅកម្ពុជាប្រជាធិបតេយ្យមានតិចជាអតិបរមា ។ គ្មានការបង្ក្រាបដូចពីសង្គមចាស់ទេ ។ ប្រជាជនដើរតួនាទីខ្លួនឯងជាសំខាន់ ។

## I. បញ្ហាហ្វឹកហ្វឺនប្រជាជនខាងយោធា

យើងខ្ញុំគ្មានការហ្វឹកយោធាក្នុងប្រជាជនទេ ។ ប៉ុន្តែយើងខ្ញុំអប់រំប្រជាជនជាប្រចាំឲ្យជ្រួតជ្រាបជាមាគ៌ាបដិវត្តន៍ ឲ្យស្នេហាជាតិ ស្នេហាប្រជាជន ឲ្យរួមចំណែកការពារប្រទេស និងកសាងប្រទេសឲ្យសាមគ្គីជាមួយមិត្តភក្តិលើសកលលោក ឲ្យស្អប់ពួកអ្នកឈ្លានពានវាតទី ។ ឈរលើនយោបាយនេះ ប្រជាជនស្នេហាជាតិយ៉ាងមោះមុត នេះជាកត្តាមូលដ្ឋានដើម្បីការពារប្រទេសនិងការពាររដ្ឋអំណាចកម្មករ-កសិករបដិវត្ត ។

## II. អំពីវប្បធម៌ កីឡា និង កំសាន្ត

១) វប្បធម៌

វប្បធម៌នៃកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជាវប្បធម៌ថ្មី

◆ឈរលើលក្ខណៈជាតិនិងលើប្រពៃណីភាពជាតិ

◆ឈរលើលក្ខណៈចម្រើន ។

ប្រពៃណីជាតិ យើងខ្ញុំយកតែចំណុចណាដែលចម្រើន ហើយអាចបំពេញចលនាបដិវត្តយើង ដោយបំបាត់ចំណុចណាដែលប្រតិកិរិយាដែលឱនថយ ។ ម្យ៉ាងទៀត ដោយឈរលើលក្ខណៈជាតិ ប្រពៃណីជាតិ និងលក្ខណៈចម្រើន យើងខ្ញុំពង្រីកវប្បធម៌ថ្មីបន្ថែមដើម្បីបម្រើដល់ការកសាងប្រទេស និងដើម្បីបម្រើជីវភាពថ្មីរបស់ប្រជាជនឲ្យកាន់តែស្អាតស្អំ ហើយឲ្យកាន់តែរីកចម្រើនធូរធារ ក៏ដូចជាបម្រើការបំពាក់បំប៉នខាងនយោបាយសតិអារម្មណ៍ ខាងគោលជំហរបដិវត្តន៍ ខាងគោលជំហរស្នេហាជាតិ ស្នេហាឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី ។

អ្វីដែលជាកេរដំណែលរបស់ជាតិ ហើយដែលនៅសល់ពីការបំផ្លិចបំផ្លាញរបស់ខ្មាំងក្នុងពេលសង្គ្រាម យើងខ្ញុំយកចិត្តទុកដាក់ថែរក្សាដើម្បីចាត់តាំងស្រាវជ្រាវជាបណ្តើរៗសម្រាប់បម្រើចលនាបដិវត្តរបស់យើងខ្ញុំ ។ ឯសៀវភៅបរទេសគ្រប់ផ្នែកដែលចម្រើន ដែលនៅសល់ពីសង្គ្រាម យើងខ្ញុំថែរក្សាទុកដើម្បីស្រាវជ្រាវបម្រើចលនាបដិវត្តជាបណ្តើរៗ ។

ចំពោះវប្បធម៌បរទេសឲ្យតែចម្រើនយើងយកប្រើប្រាស់ ។

២) អំពីការកម្សាន្ត

យើងខ្ញុំរៀបចំឲ្យមានការកម្សាន្តជាបណ្តើរៗ ។ ហើយកម្សាន្តនេះលៃទៅតាមលទ្ធភាពនៃប្រទេសជាបណ្តើរៗ ។ ឥឡូវការ

កម្សាន្តនៅមានកម្រិតនៅឡើយ ដោយជាប់រវល់ធ្វើការងារបង្កបង្កើនផល ដោះស្រាយជីវភាពនៅពេលក្រោយសង្គ្រាម ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានការរៀបចំកម្សាន្ត កាន់តែចម្រើនឡើងៗជារៀងរាល់ថ្ងៃចាប់តាំងពី១៩៧៩មក ។ កម្សាន្តដោយជួបជុំគ្នា ស្តាប់ភ្លេងនិងចំរៀងតាមវិទ្យុ កម្សាន្តដោយចាត់តាំងក្រុមសិល្បៈក្រៅអាជីពនៅតាមមូលដ្ឋានខ្លួន ដោយមើលខ្សែភាពយន្តតាមលទ្ធភាព...។ល។ ក្រៅពីនេះក៏មានការចាត់តាំងទស្សនកិច្ចជិតឆ្ងាយ តាមការដាក់ស្តែងកន្លែងនីមួយៗ ។ ទស្សនកិច្ចទាំងនេះជាការកម្សាន្តផង ជាការផ្លាស់ប្តូរពិសោធន៍ផង បើកទស្សនៈធំទូលាយក្នុងការស្គាល់ប្រទេសរបស់ខ្លួនខាងកសិកម្ម ឧស្សាហកម្ម វប្បធម៌ និងការងារផ្សេងៗទៀតផង ។

៣) អំពីកីឡា

យើងខ្ញុំរៀបចំកីឡាជាបណ្តើរៗ ដូចជាហាត់ប្រាណក្នុងអង្គភាពកងទ័ពមានហាត់ជាទូទៅ ។ កុមារា កុមារី ក្មេងជំទង់ យុវជន យុវនារី ហាត់ប្រាណជាប់និងការបង្កបង្កើនផល ។ ភ្ញាក់ឡើងបោសសម្អាតផ្ទះសម្បែង ទីធ្លា រួចហើយស្រោចដំណាំមុនទៅធ្វើការតាមក្រសួងមន្ទីរនិងតាមផ្ទះ ។

៤) អំពីសិល្បៈ

យើងខ្ញុំមានសិល្បៈផ្សាយតាមវិទ្យុ មានភាពយន្ត និងលេងសិល្បៈក្រៅអាជីពតាមក្របខណ្ឌកន្លែងនីមួយៗ ។ នៅភ្នំពេញក៏មានចាត់តាំង នៅតាមជនបទតាមសហករណ៍ក៏មានចាត់តាំង ហើយយើងខ្ញុំបន្តពង្រឹងប្រពៃណីនេះថែមទៀត ។ ដូចជាយើងខ្ញុំបានរក្សាកេរដំណែលអង្គរវត្ត គឺយើងខ្ញុំរក្សាទុកប្រពៃណីណាដែលល្អសម្រាប់បម្រើជីវភាពប្រជាជន ។

## III. អំពីតុលាការ

នៅកម្ពុជាប្រជាធិបតេយ្យ ប្រជាជនដោះស្រាយគ្រប់បញ្ហាទាំងអស់ ។ ពួកខ្មាំងសត្រូវនិងរដ្ឋអំណាចប្រជាជនស្រេចតែប្រជាជនវិនិច្ឆ័យ ។ ជាធម្មតា ប្រជាជនគេមានរបបប្រជុំជីវភាពទៀងទាត់របស់គេ ។ អ្នកណាមានគុណសម្បត្តិអី អ្នកណាខ្វះខាតអី គេកសាងគ្នាទៅវិញទៅមកជាប់ ។ ដូច្នោះ ការអប់រំនៅក្នុងប្រជាជនជាវិធានការការពារកុំឲ្យមានពួកដែលប្រឆាំងនឹងរដ្ឋអំណាចប្រជាជនជាមុនទៅហើយ ។ ហើយបើមានគឺមានតិចជាអតិបរមា ។ សមាសភាពជាខ្មាំងប្រឆាំងបដិវត្តន៍ បើប្រជាជនគេទិតៀនជាបន្តបន្ទាប់មិនកែប្រែ ប្រជាជនវិនិច្ឆ័យទោស ។ ឯតុលាការគ្រាន់តែអនុម័តតាមការវិនិច្ឆ័យរបស់ប្រជាជនទេ ។

យើងខ្ញុំមិនមានគុកទេ ហើយយើងខ្ញុំក៏មិនប្រើពាក្យគុកនេះផង ។ ចំពោះអ្នកដែលមិនល្អ យើងខ្ញុំមានការចាត់តាំងទៅបង្កបង្កើនផល ។

១) អ្នកមានកំហុសធម្មតា ត្រូវទៅបង្កបង្កើនផលក្នុងប្រជាជន ។

២) បើប្រព្រឹត្តកំហុសជាច្រើនលើកច្រើនគ្រាហើយជាប្រភេទមានពិសពុល ត្រូវទៅបង្កបង្កើនផលទៅការដ្ឋាន ឬកសិដ្ឋានដោយឡែក ដើម្បីកសាងខ្លួនក្នុងការងារ ។

## IV. អំពីបញ្ហាកសាងគ្រួសារ

យុវជនយុវនារីកសាងគ្រួសារដោយសាមីខ្លួនស្ម័គ្រចិត្ត ។ ដល់រៀបចំគ្រួសារហើយ បើមានបញ្ហាក្នុងគ្រួសារ មហាជនជួយមតិដើម្បីដោះស្រាយសម្រុះសម្រួលគ្នា ។ តែបើសាមីខ្លួនមិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ការលែងលះគ្នាស្រេចតែខ្លួនគេទាំងសងខាងទេ គ្មានកាត់សេចក្តីទេ ។ ឥឡូវនេះធម្មតាមិនសូវមានចោទបញ្ហាលែងលះគ្រួសារទេ ពីព្រោះទាំងប្តីទាំងប្រពន្ធមានការភ្ជាប់ពុកខាងនយោបាយ ហើយគ្រួសារនីមួយៗមានជីវភាពធានាអះអាងក្នុងសង្គមជាតិមួយស្អាតស្អំ មិនពុករលួយ ។ ដូច្នោះមិនមានអ្វីទំនាស់ជាប្រចាំហើយដោះស្រាយមិនរួចនៅក្នុងគ្រួសារទេ ។

## V. អំពីជីវភាពប្រជាជន

ចំពោះប្រជាជន៩៥ភាគរយជីវភាពរបស់គេធូរស្រាលជាងពីកាលសង្គមចាស់ច្រើន ព្រោះពីមុនគេអត់ដី អត់ផ្ទះ អត់ការងារធ្វើ អត់បាយ អត់ទឹក ឈឺថ្កាត់ លក់កូនប្រុស លក់កូនស្រី ខ្លះលក់ទាំងប្រពន្ធទៀត ។ ជីវភាពលំបាកមិនធានាអះអាងទេ ។ ម្យ៉ាងទៀត គេស្ថិតក្នុងសភាពត្រូវជិះជាន់សង្កត់សង្កិនធ្វើការងារក្នុងឋានៈជាខ្ញុំគេ ហើយអត់បានទទួលផលតាមការងារនេះផង ត្រូវគេកេងប្រវ័ញ្ចអស់ ។

ឥឡូវគេធ្វើម្ចាស់លើការងារនិងលើផលដែលគេធ្វើបាន ។ គេធ្វើការងារដូចធ្លាប់ធ្វើកាលពីមុន ឬស្រាលជាងពីមុន តែ

ជីវភាពរបស់គេធូរធារជាងមុន ហើយមានការធានាអះអាងជាងមុន ។ ជីវភាពក្នុងគ្រួសារគេក៏មានលក្ខណៈល្អជាងមុន ។ មានតែ ៥ភាគរយទេដែលធ្វើការងារច្រើនជាងពេលមុន ព្រោះអ្នកទាំងនេះពីដើមអត់ធ្វើការឬធ្វើការងារតិចតួច ។ ប៉ុន្តែឥឡូវគេភ្ញាក់រឭកថារស់នៅត្រូវធ្វើការងារ ហើយធ្វើការងារដើម្បីរួមកសាងប្រទេស ការពារប្រទេស និងលើកតម្កើងជីវភាពប្រជាជនទូទៅ ។

ដូច្នោះជីវភាពរបស់ប្រជាជនទាំងមូលកាន់តែធានាអះអាងកាន់តែបានធូរធារបណ្ដើរៗលើគ្រប់ផ្នែក ។ ហើយប្រជាជនទទួលសុភមង្គលក្នុងសង្គមក្នុងគ្រួសារនិងផ្ទាល់ខ្លួនគេកាន់តែច្រើនឡើងៗ តាមសភាពការណ៍នៃការរីកចម្រើនរបស់ប្រទេសលើគ្រប់ផ្នែក ។

## VI. *សភាតំណាងប្រជាជនកម្ពុជា*

សមាជិកសភាតំណាងប្រជាជន មានបក្សជនផងនិងមិនមែនបក្សជនផង ។ បក្សជនមាន៦០ភាគរយ ។

## VII. អំពីសិទ្ធិរបស់ប្រជាជន

នៅកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំអនុវត្តប្រជាធិបតេយ្យប្រមូលផ្ដុំនៅក្នុងប្រជាជនគ្រប់បញ្ហាទាំងអស់ ។

ឈរលើគោលការណ៍នេះ ទាំងអស់គ្នាមានសិទ្ធិបញ្ចេញមតិ ជាមតិស្របក្ដី ជាមតិមិនស្របក្ដី ជាមតិជំទាស់ក្ដី ក្នុងគ្រប់អង្គប្រជុំនិងលើគ្រប់បញ្ហាទាំងអស់ ។ ម្នាក់ៗបញ្ចេញមតិអស់ហើយទើបប្រមូលភាពអនុម័ត ។ ថ្ងៃក្រោយ បើមានមតិមិនយល់ស្របនិងការសម្រេចពីមុន ឬក៏មានមតិស្នើកែលម្អការសម្រេចនោះ អង្គប្រជុំក៏លើកឡើងពិភាក្សាគ្នាជាប្រជាធិប-តេយ្យទៀត ហើយសមូហភាពអនុម័ត ។

យើងខ្ញុំធ្វើយ៉ាងនេះជារបបប្រជាធិបតេយ្យប្រមូលផ្ដុំរបស់យើងខ្ញុំ ។

## VIII. *អំពីសាសនា*

នៅកម្ពុជា ពុទ្ធសាសនាជាប់នឹងកសិករ ។ លោកសង្ឃចេញពីមជ្ឈដ្ឋានកសិករ ។ កសិករបានចូលរួមធ្វើបដិវត្តន៍ ហើយមានការភ្ញាក់រឭកបដិវត្តយ៉ាងជ្រាលជ្រៅ ។ ពិសេសក្នុងសង្គ្រាមរំដោះជាតិ ចលនាបដិវត្តខ្លាំងក្លាណាស់ ។ កសិករមួយរួមចំណែកយ៉ាងសកម្មបំផុតក្នុងចលនា មួយផ្នែកដោយផ្ដល់យុទ្ធជនទៅសមរភូមិមុខ មួយផ្នែកទៀតទៅបង្កបង្កើនផល ។ លោកសង្ឃមួយចំនួនច្រើនបានសឹកមកធ្វើបដិវត្តន៍ ។ ពិសេសចាប់ពីឆ្នាំ ១៩៧៣-៧៤មក មានលោកសង្ឃជាអតិបរមា ។ ឥឡូវក៏កាន់តែថយច្រើននៅសល់តែចាស់មួយចំនួនតិច ។ ដូច្នេះនៅកម្ពុជា បញ្ហាសាសនាវាដោះស្រាយខ្លួនឯងបែបនេះ ។ វត្តអារាមមានតែខ្លាំងទេដែលកម្ទេច ។ សព្វថ្ងៃនេះ វត្តណាដែលនៅល្អយើងរក្សាទុក ។

## IX. បញ្ហាអតីតអ្នករដ្ឋការក្នុងរបបអា លន់ ណុល

សព្វថ្ងៃ គេរស់នៅនិងធ្វើការងារដូចប្រជាជនឯទៀតនៅក្នុងសហករណ៍ ។ នាយទុនជាតិក៏នៅក្នុងសហករណ៍ ។ មានខ្លះនៅធ្វើការក្នុងក្រសួងមន្ទីរ តែភាគច្រើននៅសហករណ៍ ។

## X. បញ្ហាអ្នកមកពីបរទេស

អ្នកមកពីបរទេសមួយផ្នែកនៅសហករណ៍ មួយផ្នែកនៅការដ្ឋាន មួយផ្នែកទៀតនៅក្រសួងមន្ទីរ ។ សំណូមពររបស់យើងខ្ញុំគឺឲ្យគេទៅបង្កបង្កើនផលចូលប្រឡូកក្នុងចលនាជាក់ស្ដែងដើម្បីគេឃើញប្រភពវិជ្ជាមិនចេះរីងស្ងួតដែលមាននៅក្នុងមហាជន ដើម្បីគេកាន់តែមានជំនឿលើប្រជាជនឯង ជាតិឯង ។ បើគេមានជំនឿយ៉ាងនេះហើយ គេអាចយកវិជ្ជារបស់គេមករួមផ្សំជាមួយពិសោធន៍ដ៏សម្បូររបស់មហាជន រួមចំណែកកសាងប្រទេសបានតាមសភាពជាក់ស្ដែងនៃប្រទេស ។

បើមិនដូច្នោះទេ គេមិនចេះច្នៃប្រឌិត ។ ឥឡូវភាគច្រើនគេកសាងជំនឿលើប្រជាជនបាន គេក៏រួមចំណែកក្នុងកិច្ចការកសាងប្រទេសបាន ។

## XI. បញ្ហាជនជាតិកម្ពុជានៅបរទេស

គេចង់មកស្រុកវិញពេលណាក៏មកបាន ។ ទោះគេរស់នៅប្រទេសណាក៏ដោយ បើគេគេចង់ត្រឡប់មកប្រទេសវិញ គេមកបានឲ្យតែមកតាមច្បាប់ទម្លាប់ ។

ពួកដែលទៅប្រទេសក្រៅមុនដែលយើងខ្ញុំរំដោះនិងក្នុងរយៈពេលដែលយើងខ្ញុំរំដោះភ្លាម ពួកនេះអ្នកខ្លះក៏ជាភ្នាក់ងាររបស់ខ្មាំង ។ ប៉ុន្តែអ្នកខ្លះក៏ភាន់ច្រឡំដោយខ្មាំងវាបំភ័ន្ត ។ អ្នកដែលភាន់ច្រឡំ តែងតែចង់ត្រឡប់មកប្រទេសវិញ ។ បើគេសម្រេចមកប្រទេសវិញ យើងខ្ញុំរីករាយទទួលគេ ។ ខ្លះបានមក

ប្រទេសវិញខ្លះៗហើយ ។ ម្យ៉ាងទៀត មានជនជាតិខ្មែរជាច្រើន ដែលនៅក្រៅប្រទេស ក៏គេស្នេហាជាតិ គេការពារកម្ពុជាប្រជាធិបតេយ្យយ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងពួកចក្រពត្តិនិយម វាតទីនិយមប្រតិកិរិយា និងពួកក្បត់ជាតិ ។

ឯពួកដែលក្បត់ជាតិនិងជាភ្នាក់ងាររបស់ខ្មាំងសត្រូវមាន តែមួយចំនួនតិចទេ ។ កាលវានៅក្នុងប្រទេសក៏វាក្បត់ជាតិ នៅក្រៅប្រទេសក៏វាក្បត់ជាតិ ។ បញ្ហានេះមិនជាបញ្ហាអីប្លែកទេ ។ ប្រទេសទាំងអស់នៅក្នុងសកលលោកសុទ្ធតែមានបញ្ហានេះ ។ បើតាមយើងខ្ញុំដឹង បញ្ហានេះកម្ពុជាប្រជាធិបតេយ្យមានមិនច្រើន ដល់ប្រទេសឯទៀតទេ ។

## XII. អំពីបញ្ហាគ្រួសារបរទេស

យើងខ្ញុំគោរពតាមការស្ម័គ្រចិត្តរបស់គេ ។ គេចង់មកតាមគ្រួសារគេនៅកម្ពុជាគេមកបាន ។ ឯកូនចៅគេក៏ស្រេចតែគេយកសញ្ជាតិណាក៏បាន ។ ស្រេចតែសាមីខ្លួន យើងខ្ញុំអត់មានរើសអើងទេ ។ យើងខ្ញុំពិនិត្យឃើញថា អ្នកខ្លះដោយសង្គ្រាមជួនកាលគេទ្រាំទ្រមិនបាន គេមិននៅកម្ពុជា គេដកខ្លួនទៅបរទេស ។ ឥឡូវប្រទេសយើងខ្ញុំរំដោះហើយ តែប្រទេសយើងខ្ញុំស្ថិតនៅក្នុងសភាពក្រោយសង្គ្រាមមហាវិនាសកម្ម ។ យើងខ្ញុំត្រូវខិតខំបង្កបង្កើនផលខបត្តម្ភខ្លួន ។ ក្នុងសភាពការណ៍នេះមួយចំនួនគេត្រឡប់មកវិញ ។

## XIII. អំពីទូរគមនាគមន៍

យើងខ្ញុំកំពុងដំណើរការជាបណ្តើរៗតាមលទ្ធភាព ។ ឥឡូវយើងខ្ញុំមានការទាក់ទងខាងទូរមនាគមន៍ជាមួយប្រទេសចិន ហើយតាមរយៈប្រទេសចិន ក៏អាចទាក់ទងជាមួយសកលលោកបាន យើងខ្ញុំទើបនឹងមានការទាក់ទងដោយផ្ទាល់ជាមួយសិង្ហបូរី ហើយនិងដំណើរការទាក់ទងជាមួយប្រទេសឯទៀតជាបណ្តើរៗ ។

ចំពោះជនជាតិកម្ពុជានៅបរទេសដែលមិនទាន់មានការទាក់ទងជាមួយគ្រួសារឬមិត្តភក្តិគេនៅក្នុងប្រទេស គេចង់ផ្ញើសំបុត្រមកប្រទេសក៏បាន តាមរយៈស្ថានទូតខ្ញុំនៅប៉េកាំង ។

## XIV. អំពីទីក្រុង

ប្រជាជនត្រឡប់មករស់នៅទីក្រុងជាបណ្តើរៗតាមសភាពនៃការរីកលូតលាស់ខាងខស្សរាហកម្មជាបណ្តើរៗ ។

អំពីអ្នកដក់អាភៀន-ស្រីពេស្យានិងកូនចៅរបស់គេះ

យើងខ្ញុំឲ្យគេត្រឡប់ទៅរស់នៅក្នុងប្រជាជន រួមជីវភាពនិងកសាងខ្លួនក្នុងប្រជាជន ។ នៅក្នុងប្រជាជនមានការអប់រំរៀនសូត្រនយោបាយ ។ ភាគច្រើនគេទៅជាប្រជាជនធម្មតា ។ កូនចៅគេរស់នៅក្នុងប្រជាជនដូចប្រជាជនធម្មតា ។

## XV. អំពីបញ្ហារដ្ឋប្រហារ

តាំងពីរំដោះមក ចក្រពត្តិអាមេរិករៀបចំធ្វើរដ្ឋប្រហារជាបន្តបន្ទាប់តែវាធ្វើមិនបាន គ្រាន់តែប៉ុនប៉ងតែប៉ុណ្ណោះ ។ តែការប៉ុនប៉ងធ្វើរដ្ឋប្រហារសំខាន់ជាងគេគឺពីសំណាក់យួននិងបក្សពួក ពីព្រោះយួននិងបក្សពួកចង់លេបទឹកដីកម្ពុជា ។ ហើយឈរលើនយោបាយលេបទឹកដីនេះ មួយផ្នែកវាខំអូសទាញនិងបោកប្រាស់ តែដោយបោកប្រាស់មិនបាន វាក៏វាយយើងខ្ញុំពីខាងក្រៅ ។ មួយផ្នែកទៀត វាខំចាត់តាំងធ្វើរដ្ឋប្រហារដោយចាត់តាំងឲ្យភ្នាក់ងាររបស់វាលបធ្វើឃាតអ្នកដឹកនាំកម្ពុជា ។ ចាប់ពីឆ្នាំ១៩៧៦ មកវាធ្វើជាប់ ។ តែវាធ្វើមិនបាន ។

## XVI. គោលជំហរកម្ពុជាប្រជាធិបតេយ្យចំពោះអង្គការសហប្រជាជាតិ

កម្ពុជាប្រជាធិបតេយ្យយល់ឃើញថា ជាទ្រឹស្តី ធម្មនុញ្ញអង្គការសហប្រជាជាតិជាការត្រឹមត្រូវ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ពួកចក្រពត្តិនិយមនិងពួកវាតទីនិយមអនុវត្តបំភ្លើសដើម្បីផលប្រយោជន៍របស់វា ហើយដើម្បីបិទបាំងអំពើឈ្លានពាននិងសកម្មភាពជ្រៀតជ្រែករបស់វាលើប្រទេសដទៃ ពិសេសប្រទេសនិងប្រជាជនក្រីក្រ ។

នៅកម្ពុជាប្រជាធិបតេយ្យបច្ចុប្បន្ន ប្រជាជនមានសិទ្ធិសាធារណៈនិងនយោបាយ ក៏ដូចជាសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ជាមូលដ្ឋាន ។ ប្រជាជនមានសិទ្ធិរស់នៅគ្រប់ផ្នែកដោយមានស្រែចម្ការធ្វើ ដោយធានាអះអាងមានការងារធ្វើ ដោយធានាអះអាងក្នុងរោងចក្រក្តី ក្នុងផ្នែកផ្សេងទៀតក្តី មានស្បៀងគ្រប់គ្រាន់ និងធានាអះអាងមានសម្លៀកបំពាក់គ្រប់គ្រាន់ និងធានាអះអាងមានពេទ្យព្យាបាលគ្រប់គ្រាន់ ធានាអះអាងមានផ្ទះសម្បែងនៅ ធានាអះអាងមានការរៀនសូត្រ កម្ចាត់ការមិនចេះអក្សរជាទូទៅ ។ ប្រជាជនទូទៅមានសិទ្ធិបង្កើនការរៀនសូត្រគ្រប់ៗគ្នា ។

### XVII. *សាធារណៈសុខាភិបាល*

បក្សកុម្មុយនិស្តកម្ពុជានិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានផែនការបង្កើនចំនួនប្រជាជនពី១៥ ទៅ២០លាន ក្នុងរយៈពី១០ ទៅ១៥ឆ្នាំ ។ ដូច្នេះ យើងមាននយោបាយការពារកម្លាំងប្រជាជនយើង ។ ក្នុងនេះយើងមាននយោបាយបង្ការនិងការពារគ្រោះថ្នាក់ការងារជាមុន ។ ការពិតការងារយើងខ្ញុំមិនទាន់មានអីដែលជាលក្ខណៈនាំឲ្យមានគ្រោះថ្នាក់ធំដុំ ដូចសំណង់រោងចក្រខ្ពស់ៗ រោងចក្រស្លដែកថែប ឬអណ្ដូងរ៉ែផ្សេងៗនៅឡើយទេ ។

ទន្ទឹមនឹងនេះ យើងខ្ញុំខំបំប៉នសុខភាពប្រជាជនយើងខ្ញុំក៏ដូចជាកម្មករយើងខ្ញុំៈ

១) ស្បៀងអាហារ ធានាអះអាងគ្រប់គ្រាន់

២) ថ្នាំសង្កូវ ធានាអះអាងគ្រប់គ្រាន់

៣) យើងខ្ញុំមិនរត់តាមសន្ទាក់ ការបង្ខិតបង្ខំធ្វើការងាររបស់នាយទុនទេ ដែលវាបង្ខំសម្រុកតាមម៉ោង តាមសន្ទាក់អាស្យាណូរបស់វានោះទេ ។ កម្មករយើងខ្ញុំមានពេលសម្រាក ។ ព្រឹកក៏មានពេលសម្រាក រសៀលក៏មានពេលសម្រាក ។ ក្រៅពីនេះ លក្ខណៈធ្វើការរបស់យើងខ្ញុំស្ថិតនៅក្នុងភាពទូលាយមិនចង្អៀតចង្អល់ បរិវេណទូលាយ ធូរស្រាលមិនតឹងតែង មានអាកាសល្អ ខ្យល់ចេញចូលស្រួល ។ មានពន្លឺថ្ងៃគ្រប់គ្រាន់ ។

ធ្វើការនៅជនបទ បើថ្ងៃក្ដៅយើងសម្រាកញឹក ហើយរកពេលត្រជាក់ធ្វើ ។

ហើយលក្ខណៈមួយទៀត ពលករយើងខ្ញុំស្ថិតនៅក្នុងសង្គមមួយស្អាតស្អំ ។ ដូច្នេះមិនដើរលេងពាលាអាវ៉ាសែ គ្មានរោគសង្គមដែលនាំឲ្យសុខភាពពលករយើងខ្ញុំទ្រុឌទ្រោមទេ ។ សុខភាពពលករយើងខ្ញុំមានតែរីកចម្រើនយ៉ាងឆាប់រហ័ស ។

### XVIII. បញ្ហាសេដ្ឋកិច្ច

មូលហេតុនៃការបំបាត់ប្រាក់កាសនិងទិសដៅអនាគត

ការបំបាត់ប្រាក់កាស មានមូលហេតុទាក់ទងដល់សភាពការណ៍នៃសង្គ្រាមរំដោះជាតិរបស់យើងខ្ញុំ ។

នៅឆ្នាំ១៩៧០-៧១ យើងខ្ញុំរំដោះបានប្រទេសពី៧៥ ទៅ៨០ភាគរយ ។ ក្នុងរយៈពេលនោះយើងខ្ញុំក្ដាប់រដ្ឋអំណាចខាងនយោបាយនិងខាងយោធា ។ ប៉ុន្តែយើងខ្ញុំឥតក្ដាប់រដ្ឋអំណាចសេដ្ឋកិច្ចទេ ។ សេដ្ឋកិច្ចនៅក្នុងកណ្ដាប់ដៃពួកម្ចាស់ដីនិងពួកនាយទុន ។ ទន្ទឹមនឹងនេះ នៅតំបន់យើងខ្ញុំមានចាយលុយ លន់ ណុល នៅឡើយ ដូច្នេះពួកម្ចាស់ដីនិងពួកនាយទុនប្រមូលផលិតផលអស់ដោយសារគេមានក្រដាសប្រាក់ប៉ុយរបស់អាលន់ណុល ។ ហើយយកផលិតផលនេះទៅលក់ឲ្យអាណុល ។ ប្រជាជនមានការលំបាកខាងស្បៀង ។ កងទ័ពមានការលំបាកខាងស្បៀង ។ ដូច្នេះមានការប៉ះពាល់ធ្ងន់ធ្ងរដល់សង្គ្រាមរំដោះជាតិ ។ ក្នុងសភាពការណ៍ដូច្នេះ យើងខ្ញុំមិនអាចយកជ័យជម្នះបានទេ ។ យកជ័យជម្នះបានលុះត្រាតែយើងខ្ញុំក្ដាប់ផលិតផលស្រូវ ។ យើងខ្ញុំមានតែផ្លូវមួយគត់ គឺចាត់តាំងសហករណ៍កសិករផលិតកម្មដែលទើបកកើតឡើងនៅជាច្រើនកន្លែងនៃតំបន់រំដោះឲ្យបានជាទូទៅ ។ យើងខ្ញុំក៏បានចាត់តាំងសហករណ៍កសិករផលិតកម្មជាទូទៅនៅពាក់កណ្ដាលឆ្នាំ១៩៧៣ ។

ដល់មានសហករណ៍កសិករផលិតកម្មជាទូទៅដូច្នេះ កសិករនិងរដ្ឋអំណាចបដិវត្តក្ដាប់ផលិតផលស្រូវបានទាំងអស់ ។ ជីវភាពប្រជាជនក៏បានធានាអះអាងជាមុន ។ ឧបត្ថម្ភកងទ័ពក៏បាន ។ ហើយនយោបាយកាត់ផ្ដាច់ស្បៀងខ្មាំង ក៏មានប្រសិទ្ធភាពជាងមុន ។ រដ្ឋកាន់កាប់ដោយផ្ដាច់មុខនូវផលិតកម្មជាយុទ្ធសាស្ត្រ ដូចជាស្រូវ អំបិល ក្រណាត់ និងប្រេង ។ នៅក្នុងតំបន់រំដោះយើងខ្ញុំ តួនាទីរបស់ប្រាក់កាស ក៏កាន់តែចុះថយអស់យ៉ាងឆាប់ ។ នៅឆ្នាំ១៩៧៤ ចុះថយអស់៨០ភាគរយ ។ មុនរំដោះអត់មានចាយលុយទេ ។ ទម្លាប់នេះនាំឲ្យយើងខ្ញុំឈប់ចាយលុយកាក់រហូតមកដល់ថ្ងៃនេះ ។

តើបញ្ហានេះតទៅមុខទៀតយ៉ាងម៉េច?

បញ្ហានេះស្រេចតែនឹងប្រជាជនទេ ។ បើប្រជាជនត្រូវការចាយលុយវិញ យើងខ្ញុំនឹងធ្វើតាមប្រជាជន ។ ប៉ុន្តែរហូតមកដល់ឥឡូវនេះប្រជាជនយើងខ្ញុំមិនទាន់ឃើញថាចាំបាច់ត្រូវចាយលុយវិញទេ ។

ភ្នំពេញ, ថ្ងៃទី៥ សីហា ១៩៧៨

**(ឯកសារ D១០៧)**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៨៣១ | ផន ទូច ហៅ តក់ | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣២ | អែម សន ហៅ សុត | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៣ | វង យ៉េត | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៤ | នង ហ៊ាង ហៅ វុទ្ធី | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៥ | យឹម តាំងវេង ហៅ សិត | យុទ្ធជន | កងពល១៧០ | ២៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៣៦ | ស៊ឹង ញឹប ហៅ សំអាន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៧ | ហួត ហ៊ែល | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៨ | ម៉ៅ សេង | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៣៩ | យិន អេន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៤០ | ជិន ជួន | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤១ | យិន អួន | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤២ | យ៉ាន់ យ៉ន | យុទ្ធជន | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៣ | យិន ធឿន | អនុក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៤ | យឹម សារួន | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៥ | យឹម យឿន | យុទ្ធជន | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៦ | គង់ ជា | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៧ | ជូ ឈិត | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៨ | ម៉ុក គង់ | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៤៩ | ស៊ឹង យាន | យុទ្ធជន | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥០ | កែវ បុល | អនុក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥១ | លឿង សុក | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥២ | ស៊ុម សារុន | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៣ | សៀង ផល | មេពួក | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៤ | ជុិ កន | មេពួក | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៥ | ណុប សាលួត | មេក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៦ | សុក អប | យុទ្ធជន | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៧ | សួន មុី | អនុក្រុម | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១៨៥៨ | ស្រ៊ន ស្រេង ហៅ ចាន់ថា | យុទ្ធជន | កងពល៥០២ | ៨-១១-៧៦ | ២១-១២-៧៦ |
| ១៨៥៩ | ទេប បក្ស | ប៉ូលិស | តំបន់២៥ | ២៤-១០-៧៦ | ២១-១២-៧៦ |
| ១៨៦០ | ឡាយ ឡេងឡេង (ស្រី) | ប្រពន្ធ ប៊ុន ឈៀង | យួន | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៨៦១ | កង ប៉ាត់ | កម្មករចាស់ | រទេះភ្លើង | ២៨-៩-៧៦ | ២១-១២-៧៦ |
| ១៨៦២ | ចាង សេងណុង | គ្រូបង្រៀន | ស្រុកបារាំង | ២៨-១០-៧៦ | ២១-១២-៧៦ |
| ១៨៦៣ | ស៊ូ សយ ហៅ សៀក | កម្មករថ្មី | ផែកំពង់សោម | ៧-១០-៧៦ | ២១-១២-៧៦ |
| ១៨៦៤ | ទូច ប្រិល | យុទ្ធជន | រទេះភ្លើង | ២៣-១០-៧៦ | ២១-១២-៧៦ |
| ១៨៦៥ | អ៊ឹម សូត្រ ហៅ វ៉ាន់ | យុទ្ធជន | ថាមពល | ៣-១១-៧៦ | ២១-១២-៧៦ |
| ១៨៦៦ | គាំ សំអុន ហៅ សុន | គ្រូបង្រៀន | តាឡី | ២៤-១០-៧៦ | ២១-១២-៧៦ |
| ១៨៦៧ | ជុំ ខ្វាន | កម្មករចាស់ | រទេះភ្លើង | ២៨-១០-៧៦ | ២១-១២-៧៦ |
| ១៨៦៨ | ញៀប ណុប ហៅ គឹម ពិសិទ្ធ | ចោរព្រៃ | ពេជ្រនិល | ១១-១១-៧៦ | ២១-១២-៧៦ |
| ១៨៦៩ | យ៉ាញ់ យិញ | ចារបុរសយួន | យួន | ១២-១១-៧៦ | ២១-១២-៧៦ |
| ១៨៧០ | ញ៉ឹក នរិន | កម្មករចាស់ | រដ្ឋករទឹក | ២-១១-៧៦ | ២១-១២-៧៦ |
| ១៨៧១ | នាក់ ដួន ហៅ ឡាយ | សមាជិក | តំបន់៣៣ | ៧-១០-៧៦ | ២១-១២-៧៦ |
| ១៨៧២ | វ៉ី វឿត | យុទ្ធជន | រទេះភ្លើង | ១៥-១០-៧៦ | ២១-១២-៧៦ |
| ១៨៧៣ | នៀម យិនណាត | យុទ្ធជន | រទេះភ្លើង | ២១-៩-៧៦ | ២១-១២-៧៦ |
| ១៨៧៤ | អេង សារដ្ឋ | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២១-១២-៧៦ |
| ១៨៧៥ | ទូច សុកហៀងហៅ សុកថាពេជ | កម្មករ | តំបន់២៥ | ២៥-១០-៧៦ | ២២-១២-៧៦ឈឺស្លាប់ |
| ១៨៧៦ | សួង កុំ | កម្មករចាស់ | រទេះភ្លើង | ២៨-១០-៧៦ | ២៣-១២-៧៦ឈឺស្លាប់ |
| ១៨៧៧ | ហេង លី ហៅ យិន | កម្មករថ្មី | រទេះភ្លើង | ១២-១២-៧៦ | ២៥-១២-៧៦ |
| ១៨៧៨ | អេង ម៉ាការីន (ស្រី) | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៥-១២-៧៦ ចង្អុក |
| ១៨៧៩ | គីក គាំរាសី ស្រី) | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៥-១២-៧៦ |
| ១៨៨០ | អេង វុទ្ធី (ស្រី) | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៥-១២-៧៦ |
| ១៨៨១ | អេង រស្មី ហៅ ប៉ិច (ស្រី) | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៥-១២-៧៦ |
| ១៨៨២ | អេង វុធថា ហៅ ពៅ (ស្រី) | កូន គីក សេងអេង | រទេះភ្លើង | ១៩-១២-៧៦ | ២៥-១២-៧៦ |
| ១៨៨៣ | អ៊ី ប៉េងសៀង | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ២៨-១២-៧៦ |
| ១៨៨៤ | ថន | កម្មករ | ស្រែអំបិល | ១៨-១២-៧៦ | ២៨-១២-៧៦ |
| ១៨៨៥ | សុក វណ្ណា | យុវជនចល័ត | ផែកំពង់សោម | ៨-១០-៧៦ | ២៨-១២-៧៦ |
| ១៨៨៦ | ហែម ហឿង (ស្រី) | ប្រពន្ធ គីម ឆិល | រោងចក្រ ដ-៤ | ២០-១០-៧៦ | ២៨-១២-៧៦ |
| ១៨៨៧ | សៀន ដើង ហៅ វ៉ន (ស្រី) | ប្រពន្ធ ហ៊ិន | កំពង់សោម | ១១-១០-៧៦ | ២៨-១២-៧៦ |
| ១៨៨៨ | ជា សុក (ស្រី) | ប្រពន្ធ ស្រី យ៉ត | រោងចក្រ ប-៤ | ២០-១០-៧៦ | ២៨-១២-៧៦ |
| ១៨៨៩ | ស្រ៊ុន មួយ (ស្រី) | ប្រពន្ធ ប៉ោ ឡេង | រោងចក្រ ក-១១ | ២៥-១០-៧៦ | ២៨-១២-៧៦ **(នៅមានត)** |

# បើថ្នាក់លើអត់ដឹងពីការសម្លាប់ប្រជាជន ចុះមន្ទីរ៨៧០ជារបស់អ្នកណា?

សួន រី ហៅ ខាត់ ខាន់ បច្ចុប្បន្នអាយុ៤៩ឆ្នាំ រស់នៅភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ ។ រី មានប្រពន្ធឈ្មោះ កែវ នឿន អាយុ៤៤ឆ្នាំ និងកូន៣នាក់ ។ រី ចិញ្ចឹមជីវិតដោយធ្វើស្រែចម្ការ ។ កាលពីសង្គមចាស់ រី ឈប់រៀនត្រឹមថ្នាក់ទី៨ ដោយសារប្រទេសកើតសង្គ្រាម ។

ក្រោយពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភូមិត្រាចបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ យុវជននិងយុវនារីនៅក្នុងភូមិបានត្រូវបង្ខំឲ្យកាន់អាវុធប្រយុទ្ធជាមួយទាហាន លន់ ណុល ។

នៅឆ្នាំ១៩៧២ រី បានចូលបម្រើជាកងឈ្លបភូមិត្រាច និងមានមុខងារខាងតាមដានសកម្មភាពខ្មាំង ។ រី បំពេញភារកិច្ចនៅក្រោមការគ្រប់គ្រងរបស់ ហាយ ហួរ (ស្លាប់) និង ឡេង ឆន (បច្ចុប្បន្នរស់នៅក្នុងភូមិត្រាច) ។

នៅឆ្នាំ១៩៧៣ រី ត្រូវបានបញ្ចូលជាកងទ័ពក្នុងកងវរសេនាតូចដែលមានមិត្តបេង ជាប្រធាន ចំណុះឲ្យកងពលលេខ១ ដែលស្ថិតនៅក្នុងភូមិភាគឧត្តរនិងដឹកនាំដោយសមមិត្ត អឿន ។

ការប្រយុទ្ធយ៉ាងក្តៅគគុករវាងកងទ័ពខ្មែរក្រហមនិងកងទ័ពនៃរបបសាធារណរដ្ឋខ្មែរកើតមានជារៀងរាល់ថ្ងៃ ។ ប្រហែលនៅម៉ោង១១ព្រឹក ថ្ងៃទី១៧ មេសា ១៩៧៥ ក្រុងភ្នំពេញទាំងមូលត្រូវបានកងទ័ពខ្មែរក្រហមកាន់កាប់ទាំងស្រុង ។ រី បានរំឭកឡើងវិញថា កាលណោះប្រជាជននៅក្នុងទីក្រុងភ្នំពេញត្រេកអរចំពោះជ័យជម្នះរបស់កងទ័ពខ្មែរក្រហមណាស់ ប៉ុន្តែមួយប៉ព្រិចភ្នែកសោះ ប្រជាជននាំគ្នាជ្រួលច្របល់បន្ទាប់ពីបានឮសេចក្តីប្រកាសរបស់កងទ័ពខ្មែរក្រហមឲ្យប្រជាជនក្រុងភ្នំពេញចាកចេញពីផ្ទះបីថ្ងៃ ។ នៅតាមដងផ្លូវ អ្នកជម្លៀសដ៏ច្រើនសន្ធឹកសន្ធាប់បានធ្វើដំណើរឆ្ពោះទៅកាន់ទីជនបទឬស្រុកកំណើតរបស់ខ្លួន ។ ដោយឡែក អតីតទាហាន លន់ ណុល ត្រូវបានឃាត់ទុកមួយកន្លែងនៅត្រង់ផ្សារតីឡូម៉ែត្រលេខ៦ ។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចំនួន៣០០នាក់នៅក្នុងកងវរសេនាតូចមួយ ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើជាកម្មករនៅកំពង់ផែកំពង់សោម ។ រី និងមិត្តភក្តិរបស់គាត់មួយចំនួនដែលមកពីភូមិត្រាចជាមួយគ្នា ដូចជា ថាត, ហ៊ឹម ហាន, លុយ អិន, លុយ គឿន, អិន ហៅគឿន, ឡាញ់ និងកងទ័ពនៃកងវរសេនាតូចទាំងអស់មានភារកិច្ចដឹកជញ្ជូនទំនិញចេញពីកប៉ាល់ដាក់ឡានដើម្បីដឹកមកទីក្រុងភ្នំពេញ ។ ក្រោយមក តាមួយ បានទទួលតួនាទីជាមេបញ្ជាការកងវរសេនាតូចជំនួស មិត្តបេង ។

នៅឆ្នាំ១៩៧៦ រី និងកម្មករមួយចំនួន ត្រូវអង្គការបញ្ជូនមកកាន់ពាណិជ្ជកម្មរដ្ឋនៅទីក្រុងភ្នំពេញ ។ រី បានត្រូវអង្គការខ្មែរក្រហមតែងតាំងជាប្រធានឃ្លាំងពាណិជ្ជកម្មផ្នែកខាងសម្រិតសម្រាំងអនុផលនិងទទួលបន្ទុកគ្រប់គ្រងផលិតផលកសិកម្មគ្រប់ប្រភេទ ។ អនុផលទាំងអស់ដែលនាំមកពីគ្រប់ភូមិភាគត្រូវកម្មករសម្រិតសម្រាំង រៀបចំដាក់កេស ឡាំង ឬបាវ រួចនាំចេញទៅបរទេសដើម្បីដោះដូរយកគ្រឿងម៉ាស៊ីន និងគ្រឿងចក្រផ្សេងៗមកវិញ ។ បញ្ជីសារពើភ័ណ្ឌនៅខាងឃ្លាំងពាណិជ្ជកម្មក្នុងប្រទេសត្រូវបញ្ជូនទៅឲ្យ នារីថា និងបន្តទៅឲ្យ វ៉ាន់ រិត គណៈក្រសួងពាណិជ្ជកម្ម ដើម្បីត្រួតពិនិត្យនិងសម្រេច ។ រី ត្រូវជួបប្រជុំជាមួយ នារីថា និង វ៉ាន់ រិត ចំនួនបីដងក្នុងមួយខែ នៅទួលទំពូងទល់មុខរោងកុនបូកគោ ដើម្បីទទួលការអប់រំបន្ថែមអំពីការពិនិត្យគុណភាពលើទំនិញនាំចូល និងរបៀបរៀបចំទំនិញនាំចេញទៅក្រៅប្រទេសឲ្យបានល្អ ។ រី បានបន្ថែមថា យូរៗម្តងទើបឃើញ ខៀវ សំផន គណៈប្រធានរដ្ឋ មកទស្សនកិច្ចនៅឃ្លាំងពាណិជ្ជកម្មរដ្ឋ ។ នៅក្នុងអំឡុងពេលបម្រើការជាប្រធានឃ្លាំង រី មានឱកាសបានទៅសហករណ៍ឃុំកំពង់អំពិល ស្ថិតក្នុងខេត្តតាកែវតែម្តងគត់ដើម្បីដឹកជញ្ជូនអនុផលមួយចំនួនដូចជា បន្លែ ត្រីងៀតនិងអំណើក ។ នៅពេលនោះ រី បានសង្កេតឃើញការរស់នៅរបស់ប្រជាជននៅក្នុងសហករណ៍មានការលំបាកសព្វបែបយ៉ាង

តាំងពីរបបហូបចុក សម្លៀកបំពាក់ និងធ្វើការហួសម៉ោងរាល់ថ្ងៃ។ រ៉ី បានរាយការណ៍តាមសភាពជាក់ស្តែងប្រាប់ វ៉ាន់ រិត ។ វ៉ាន់ រិត ឆ្លើយថា "ខ្ញុំមិនដឹងយ៉ាងម៉េចដែរ អង្គការចែកស្បៀងហូបគ្រប់គ្រាន់នៅតាមសហករណ៍ ចុះមូលហេតុអ្វីបានជាសហករណ៍នៅតែលត់ដំដល់ថ្នាក់ហ្នឹង?" ។

នៅក្នុងឆ្នាំ១៩៧៦ កម្មាភិបាលមួយចំនួនបានបាត់ខ្លួនជាបន្តបន្ទាប់ ។ កម្មាភិបាល៥នាក់ដែល រ៉ី ធ្លាប់បានដឹកនាំឲ្យធ្វើការនៅកំពង់សោមត្រូវបាត់ខ្លួនយ៉ាងអាថ៌កំបាំង ។

ក្នុងនាមជាកម្មាភិបាលម្នាក់ធ្លាប់បម្រើការក្នុងសម័យខ្មែរក្រហម រ៉ី មិនយល់ស្របទាល់តែសោះចំពោះការបដិសេធរបស់ថ្នាក់ដឹកនាំខ្មែរក្រហមដែលថាខ្លួនគ្មានពាក់ព័ន្ធនឹងការសម្លាប់មនុស្ស ។ រ៉ី ឆ្ងល់ថា "បើថ្នាក់លើអត់ដឹងពីការសម្លាប់ប្រជាជន ចុះមន្ទីរ៨៧០ជាមន្ទីររបស់អ្នកណា? អ្នកណាអ្នកបង្កើតមន្ទីរនេះ? អ្នកណាជាអ្នកចេញឯកសារឲ្យចាប់ខ្លួន បើមន្ទីរ៨៧០ នេះតែងតែចេញបញ្ជាឲ្យចាប់មនុស្សរាប់មិនអស់នោះ?" ។

ជាចុងក្រោយ រ៉ី មានសេចក្តីត្រេកអរចំពោះការផ្សះផ្សាជាតិ ព្រមទាំងគាំទ្រដល់ដំណើរការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សព្វថ្ងៃ រ៉ី ប្រាថ្នាចង់បាននូវការរស់នៅសុខសប្បាយមិនចង់ឲ្យប្រទេសជាតិមានសង្គ្រាមទៀតឡើយ ។

**លី សុខឃាង**

# ខ្ញុំចង់សងសឹក


គីម ហួន

នៅក្នុងរបបខ្មែរក្រហម គ្មានទេការដឹងគុណ ការតបស្នង និងការយោគយល់ ។ មនុស្សម្នាក់ដែលបានបម្រើបដិវត្តន៍ខ្មែរក្រហមអស់ពីចិត្តថ្លើមនៅតែត្រូវខ្មែរក្រហមចោទថាក្បត់បដិវត្តន៍ រួចចាប់យកទៅធ្វើទារុណកម្មនិងសម្លាប់ចោល ។ ខ្លះទៀតខ្មែរក្រហមសម្លាប់សាច់ញាតិក្រុមគ្រួសារអស់ ដោយយកលេសនេះលេសនោះមកធ្វើជាហេតុផល ។ បងប្រុសរបស់ គីម ហួន ឈ្មោះ គ្រាន បានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ នៅសមរភូមិក្រោយ ខ្មែរក្រហមបានចាប់ឪពុកម្តាយនិងប្អូនតូចៗរបស់គាត់យកទៅសម្លាប់ចោល ។

មុនឆ្នាំ១៩៧៥ គីម ហួន និងបងប្អូនប្រុសស្រីចំនួន៧នាក់រស់នៅជាមួយឪពុកម្តាយ នៅភូមិដក់ពរ ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ។ ហួន បានចេញទៅកងកុមារ ហើយបងប្រុសទី៣របស់ ហួន ឈ្មោះ គ្រាន បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាមការចុចឈ្មោះរបស់គណៈឃុំបឹងត្រាញ់ខាងត្បូង ឈ្មោះ ជៀស ។ គ្រាន ចេញដំណើរទៅជាមួយយុវជន៣នាក់នៅក្នុងភូមិជាមួយគ្នា ។ នៅពេលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ឪពុករបស់ ហួន ទទួលបានដំណឹងថា គ្រាន នៅភ្នំពេញ ហើយបានទៅលេងជាមួយកូនម្តង ។

នៅឆ្នាំ១៩៧៨ ឪពុកម្តាយនិងប្អូនតូចៗ៣នាក់របស់ ហួន (ប្អូនពៅទើបតែមានអាយុកន្លះខែ) ព្រមទាំងអ្នកភូមិមួយចំនួនទៀតត្រូវអង្គការផ្លាស់ឲ្យទៅភូមិថ្មី ។ ហួន មិនបានទៅជាមួយនឹងឪពុកម្តាយទេ ព្រោះគាត់ត្រូវគណៈឃុំស្នើឲ្យទៅដឹកព្រែក ។ ពេលទៅដល់កន្លែងដឹកព្រែក ហួន អ្នកដឹកនាំការដ្ឋាននិយាយ ថា ហួន នៅក្មេងពេក មិនអាចដឹកព្រែកបានទេ ។ ដូច្នេះ ហួន ក៏ត្រូវបញ្ជូនត្រឡប់មកភូមិវិញ ។ មកដល់ភូមិមិនឃើញម្តាយឪពុក ហួន ក៏យំដើររកពួកគាត់ ប៉ុន្តែត្រូវអ្នកភូមិឃាត់ ។ ម្តាយឪពុករបស់ ហួន មិនមែនផ្លាស់ទៅភូមិថ្មីទេ គឺត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ។ អ្នកភូមិម្នាក់ឈ្មោះ ម៉ុត ដែលនៅឃ្វាលគោ

នៅក្បែរគុម្ពឫស្សីមុំវត្តរំលេច បានឃើញសកម្មភាពរបស់ខ្មែរក្រហមដែលកំពុងតែសម្លាប់ឪពុកម្តាយរបស់ ហួន និងគ្រួសារដទៃទៀត ប៉ុន្តែគាត់មិនហ៊াননិយាយប្រាប់ ហួន ទេ ខ្លាចអង្គការដឹងចាប់គាត់យកទៅសម្លាប់ដែរ ។ លុះក្រោយពេលរបបខ្មែរក្រហមដួលរលំ ទើបគាត់ហ៊ាននិយាយប្រាប់ ហួន អំពីអ្វីដែលគាត់បានឃើញ ។ តាំងពីពេលនោះមក ហួន និងបងប្អូន៤នាក់ទៀតបានសុំផ្ទះអ្នកភូមិម្នាក់ឈ្មោះ ទូន ស្នាក់នៅ ។

ក្រោយឆ្នាំ១៩៧៩ ហួន និងបងប្អូននៅតែបន្តរស់នៅជាមួយ យាយទូន រហូតដល់ពេលរៀបការ ។ នៅក្នុងឆ្នាំ២០០២ បងស្រីរបស់ ហួន ឈ្មោះ ម៉ៅ បានស្លាប់ដោយសារជំងឺ ។ កាលពីឆ្នាំមុន ហួន បានធ្វើបុណ្យបង្សុកូលបញ្ជូនវិញ្ញាណក្ខន្ធឪពុកម្តាយបងប្អូនរបស់គាត់ឲ្យទៅកាន់សុគតិភព ។ គាត់បានរំឭកឡើងថា «បងរបស់ខ្ញុំខំចេញទៅបម្រើបដិវត្តន៍ខ្មែរក្រហមហើយ ហេតុអ្វីបានជាខ្មែរក្រហមយកឪពុកម្តាយនិងប្អូនតូចៗរបស់ខ្ញុំទៅសម្លាប់ចោលព្រៃផ្សៃបែបទៀតនេះ» ។

គ្រាន បងប្រុសរបស់ ហួន បានបាត់ខ្លួនរហូតដល់បច្ចុប្បន្នមិនឃើញត្រឡប់មកស្រុកភូមិវិញ ។ ក្នុងចំណោមយុវជនបីនាក់ដែលចេញទៅជាមួយ គ្រាន ម្នាក់បានវិលត្រឡប់មក វិញប៉ុន្តែឥឡូវនេះគាត់ពិការភ្នែកទៅហើយ ។

សព្វថ្ងៃនេះ បងប្អូនរបស់ ហួន នៅរស់៤នាក់ ។ ៣នាក់នៅភូមិដក់ពរជាមួយគ្នា ហើយម្នាក់ទៀតឈ្មោះ ខិះ រស់នៅភូមិកំពង់ព្រៃ ។ រហូតមកដល់ពេលនេះ ហួន នៅតែមានសង្ឃឹមថា បងប្រុសរបស់គាត់នៅរស់ ហើយនឹងវិលត្រឡប់មកភូមិវិញនៅថ្ងៃណាមួយ ។ ហួន និយាយថា «បងរបស់ខ្ញុំជាមនុស្សល្អស្រឡាញ់ប្អូនៗ ខ្ញុំចង់ជួបមុខបងតែបន្តិចក៏អស់ចិត្តដែរ» ។ បច្ចុប្បន្នអ្នកដែលយកឪពុកម្តាយបងប្អូនរបស់ ហួន ទៅសម្លាប់នៅរស់នៅឡើយ ដែលជាហេតុធ្វើឲ្យ ហួន មិនអាចបំភ្លេចគំនុំដែលខ្មែរក្រហមធ្វើមកលើក្រុមគ្រួសារគាត់ឡើយ ។ ហួន បន្ថែមថា «ខ្ញុំចង់សងសឹកណាស់ ប៉ុន្តែមិនដឹងធ្វើអ្វីកើតមានតែទ្រាំប៉ុណ្ណោះ» ។

**សុ ហ្វារីណា**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេស ឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮ និងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំដាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំគួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ជនរងគ្រោះក្រោមរបបខ្មែរក្រហមម្នាក់បានទទួលសេវាពីគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម"

ស្រ៊ុន ស្រៀន គឺជាជនរងគ្រោះដោយអំពើទារុណកម្មនៃរបបខ្មែរក្រហម ដែលបានទទួលការផ្តល់ប្រឹក្សានិងថ្នាំព្យាបាលសុខភាពផ្លូវចិត្តក្រោមគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គម្រោងនេះត្រូវបានបង្កើតឡើងក្រោមកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការចិត្តសង្គមអន្តរវប្បធម៌ ឬកម្មវិធីផ្លូវចិត្តសហគមន៍ ។ គម្រោងនេះមានទិសដៅចម្បងពីរគឺ ១) បន្តចងក្រងឯកសារអំពីរបបខ្មែរក្រហម និង ២) ជួយជនរងគ្រោះដោយអំពើទារុណកម្មតាមរយៈការផ្តល់ប្រឹក្សានិងថ្នាំព្យាបាលសុខភាពផ្លូវចិត្ត ។

តាមរយៈប្រវត្តិរូបសង្ខេបរបស់ ស្រ៊ុន ស្រៀន ដែលបន្សល់ទុកពីរបបខ្មែរក្រហម បុគ្គលិកគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅជួបសម្ភាសន៍អំពីដំណើរជីវិតនិងស្ថានភាពសុខភាពផ្លូវចិត្តរបស់គាត់នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៣ ។ ស្រៀន កើតនៅក្នុងឆ្នាំ១៩៥៥ នៅភូមិព្រែកកេរ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។ ស្រៀន មានឪពុកឈ្មោះ ស្រ៊ុន លក និងម្តាយឈ្មោះ ទ្រី យន ។ ឪពុកម្តាយរបស់ ស្រៀន បានបញ្ជូនគាត់ឲ្យចូលរៀននៅសាលាក្នុងភូមិ ប៉ុន្តែសង្គ្រាមប្រទាញប្រទង់រវាងទាហានលន់ណុលនិងកងទ័ពខ្មែរក្រហមបណ្តាលឲ្យ ស្រៀន បោះបង់ចោលការសិក្សា បន្ទាប់ពីបញ្ចប់ថ្នាក់ទី១១ (ថ្នាក់ទី២បច្ចុប្បន្ន) ។ បន្ទាប់មក ស្រៀន បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៤ តាមរយៈប្រធានភូមិឈ្មោះ អូ យ ។

ស្រៀន ត្រូវបានបញ្ជូនចេញពីភូមិទៅហ៊ឹកហាត់បច្ចេកទេសយោធានៅកោះខ្សាច់ទន្លាក្នុងស្រុកស្អាង ខេត្តកណ្តាល ។ បន្ទាប់ពីហាត់ហ៊ឹកហ៊ឺនអស់រយៈពេល៣ខែ ស្រៀន បានក្លាយខ្លួនជាយុទ្ធជនក្នុងកងពលលេខ១២ ក្រោមការគ្រប់គ្រងរបស់ប្រធានក្រុមឈ្មោះ ឡេង និងប្រធានកងពលឈ្មោះ ណាត ។ នៅចុងឆ្នាំ១៩៧៥ ស្រៀន ត្រូវខ្មែរក្រហមចាប់ខ្លួនបញ្ជូនទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខ០៨ ខេត្តកណ្តាលភ្លាមៗបន្ទាប់ពី ឡេង ត្រូវបានចាប់ខ្លួននិងប្រហារជីវិត ។ នៅដើមឆ្នាំ១៩៧៦ ស្រៀន ត្រូវបានបញ្ជូនខ្លួនពីមន្ទីរអប់រំ០៨ ទៅមន្ទីរលត់ដំព្រៃស ។ នៅទីនោះ ស្រៀន ត្រូវជាប់ខ្នោះជើងទាំងសងខាង ហើយទទួលរងការវាយធ្វើបាបយ៉ាងដំណំ ជាពិសេសនៅពេលសួរចម្លើយ ។

ស្រៀន រំឭកថា "ខ្ញុំធ្លាប់ត្រូវគេ (ខ្មែរក្រហម) វាយនឹងដំបងក្តៅគោ និងឆក់ខ្សែភ្លើងរហូតសន្លប់" ។ អ្នកទោសខ្លះស្លាប់បន្ទាប់ពីសួរចម្លើយរួច និងខ្លះទៀតស្លាប់ដោយសារខ្វះជីវជាតិ និងគ្មានរបបហូបចុកគ្រប់គ្រាន់ ។ ស្រៀន បញ្ជាក់ថា "អាទ្រីងដេកជិតខ្ញុំ វាស្លាប់ដោយគ្មាននរណាដឹងសោះ ។ វាឈឺស្លាប់ដោយសារខ្វះជាតិស្ករក្នុងខ្លួន" ។ ក្នុងរយៈពេលស្ថិតនៅក្នុងមន្ទីរលត់ដំព្រៃស ស្រៀន បានប្រទះឃើញអ្នកទោសរាប់រយនាក់ផ្សេងទៀតជាពិសេសកងទ័ពខ្មែរក្រហមមកពីខាងភូមិភាគបូព៌ា ក្រោមការគ្រប់គ្រងរបស់ ច័ន្ទ ចក្រី ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួននិងប្រហារជីវិតក្នុងឆ្នាំ១៩៧៦ ។

នៅក្នុងឆ្នាំ១៩៧៧ ស្រៀន ត្រូវបានសម្រាលទោស ប៉ុន្តែត្រូវបានតម្រូវឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរទាំងថ្ងៃទាំងយប់ និងក្រោមតំណក់ទឹកភ្លៀង ។ ខណៈពេលដែលកងទ័ពវៀតណាមលុកលុយចូលប្រទេសកម្ពុជានៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ស្រៀន ត្រូវខ្មែរក្រហមជម្លៀសចេញពីមន្ទីរលត់ដំព្រៃសទៅខេត្តកំពង់ស្ពឺ និងជម្លៀសបន្តរហូតព្រំដែនកម្ពុជា-ថៃ ។ ក្នុងអំឡុងពេលរស់នៅព្រំដែនកម្ពុជា-ថៃ ស្រៀន បានជួបប្រទះការខ្វះខាតម្ហូបអាហារ គ្មានទីជម្រក ដូច្នេះ គាត់បានសម្រេចចិត្តវិលត្រឡប់មករស់នៅក្នុងស្រុកកំណើតវិញ ។

បទពិសោធន៍ជាអ្នកទោសរបស់ខ្មែរក្រហមបានធ្វើឲ្យ ស្រៀន ក្លាយទៅជាមនុស្សមានបញ្ហាសុខភាពផ្លូវចិត្ត ។ តាមរយៈការ

ចង្អុលបង្ហាញរបស់បុគ្គលិកគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមផ្តល់ប្រឹក្សានិងគ្រូពេទ្យចិត្តសាស្ត្ររបស់អង្គការចិត្តសង្គមអន្តរវប្បធម៌បានជួបផ្តល់ប្រឹក្សានិងផ្តល់ថ្នាំឲ្យ ស្រៀន ជាបន្តបន្ទាប់ ក្នុងអំឡុងឆ្នាំ ២០០២និងឆ្នាំ២០០៣ ។ វេជ្ជបណ្ឌិត ឈឹម សុធារ៉ា នាយកអង្គការចិត្តសង្គមអន្តរវប្បធម៌ បានប្រាប់ឲ្យដឹងអំពីសុខភាពរបស់ ស្រៀន ថា "ពេលដែលខ្ញុំជួបគាត់ដំបូងស្ថានភាពសុខភាពរបស់គាត់យ៉ាប់យ៉ឺនណាស់ ។ គាត់គ្មានកម្លាំងកំហែង ទឹកមុខស្លេកស្លាំង និងស្រពាប់ស្រពោន" ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៤ បុគ្គលិកគម្រោង "ជួយជនរងគ្រោះរងគ្រោះដោយអំពើទារុណកម្មនៃរបបខ្មែរក្រហម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅជួប ស្រៀន ម្តងទៀត ។ ស្ថានភាពសុខភាពរបស់ ស្រៀន មានលក្ខណៈខុសប្លែកពីមុនទាំងស្រុង ។ ទឹកមុខរបស់គាត់ប្រែជាស្រស់ថ្លានិងរីករាយរាក់ទាក់ ។ សមាជិកក្រុមគ្រួសាររបស់ ស្រៀន សប្បាយរីករាយចំពោះស្ថានភាពដ៏ប្រសើររបស់គាត់ ។ អ្នកជិតខាងរបស់ ស្រៀន ក៏សប្បាយត្រេកអរចំពោះការធូរស្បើយរបស់គាត់ដែរ ។ គ្រប់ៗគ្នាបានថ្លែងអំណរគុណ និងសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាពង្រីកគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម" ឲ្យកាន់តែទូលាយជាងមុន ។ អ្នកជិតខាងម្នាក់របស់ ស្រៀន ឈ្មោះ គីម និយាយថា "ខ្ញុំភ្ញាក់ផ្អើលនិងសប្បាយចិត្តណាស់ពេលឃើញអាស្រៀន បានធូរស្បើយ ។ ខ្ញុំចង់ឲ្យក្មួយជួយព្យាបាលជំងឺរបស់ខ្ញុំផង ព្រោះខ្ញុំក៏មានជំងឺដូច ស្រៀន ដែរ" ។

នៅឆ្នាំ២០០៤នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានពង្រីកគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម" ទៅខេត្តចំនួន៣ផ្សេងទៀត គឺខេត្តតាកែវ ខេត្តកណ្តាលនិងខេត្តកំពត ។ មូលហេតុសំខាន់នៃការពង្រីកគម្រោងនេះទៅខេត្តតាកែវ និងកណ្តាល គឺដោយសារខេត្តតាកែវនិងខេត្តកណ្តាល ជាខេត្តដែលមានទីតាំងមន្ទីរសន្តិសុខនិងវាលពិឃាតច្រើន ជាពិសេសមន្ទីរអប់រំស្រុកត្រាំកក់ហៅគុកក្រាំងតាចាន់និងមន្ទីរអប់រំស្រុកកណ្តាលស្ទឹងហៅគុកសង់ ។ ដោយឡែកការជ្រើសរើសយកតំបន់កោះស្លាក្នុងស្រុកឈូក ខេត្តកំពត គឺដោយសារតំបន់នេះជាតំបន់ខ្មែរក្រហមផ្តាច់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការចូលរួមរបស់ខ្មែរក្រហមផ្តាច់ខ្លួនដើម្បីកត់ត្រាអំពីរបបខ្មែរក្រហម គឺជាការសំខាន់ ។ ម្យ៉ាងទៀតការផ្តល់ប្រឹក្សានិងថ្នាំព្យាបាលចំពោះខ្មែរក្រហមផ្តាច់ខ្លួនបង្ហាញច្បាស់ថា គម្រោង"ជួយជនរងគ្រោះដោយអំពើទារុណកម្ម" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួយដល់ជនរងគ្រោះគ្រប់រូបដោយគ្មានការរើសអើង ។ បច្ចុប្បន្ននេះ បុគ្គលិកគម្រោង "ជួយជនរងគ្រោះដោយអំពើទារុណកម្ម"របស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាកំពុងបំពេញការងាររបស់ខ្លួននៅក្នុងខេត្តទាំង៣ខាងលើនេះ ដោយសង្ឃឹមថានឹងអាចជួយជនរងគ្រោះដោយអំពើទារុណកម្មដូចជា ស្រៀន ឲ្យបានធូរស្បើយកាន់តែច្រើនថែមទៀត ។




**អៀ ម៉េងទ្រី**

# បានត្រឹមតែលីដែកប្រហោងមួយជីវិត


យុន យន

«ខ្ញុំមិនទៅទៀតទេ ខ្ញុំឆ្អែតហើយគ្មានបានផលអីទេ បានត្រឹមតែលីដែងប្រហោងមួយជីវិត» ។ នេះជាការត្អូញត្អែររបស់ យុន យន។ យន គឺជាឈ្មោះបដិវត្តន៍ ។ ឈ្មោះដែលឪពុកម្តាយបានដាក់ឲ្យគឺ យឿន ។

យន បានចូលបម្រើបដិវត្តន៍ជាមួយយុទ្ធជន៥០នាក់ទៀតនៅក្នុងភូមិ ប៉ុន្តែអ្នកទាំងអស់នោះសុទ្ធតែស្លាប់និងបាត់ខ្លួន ។ ឆ្នាំនេះ យន អាយុ៤៩ឆ្នាំ ។ គាត់រស់នៅខេត្តកំពង់ចាមជាមួយប្រពន្ធនិងកូន៣នាក់ ។ យន ជាកូនច្បងនៅក្នុងចំណោមបងប្អូនប្រុស៥នាក់ ។ ប្អូនៗរបស់ យន សុទ្ធតែចូលម្រើកងទ័ពទាំងអស់ ។ នៅឆ្នាំ១៩៧៤ ប្អូនរបស់ យន ម្នាក់ឈ្មោះ ខែន បានស្លាប់នៅក្នុងគុក ។ ឪពុករបស់ យន ឈ្មោះ ថង់ យុន ម្តាយឈ្មោះ ដាន់ យ៉ុត ។

យន រារែកចិត្តមិនចង់រំឭករឿងឈឺចាប់របស់ខ្លួននៅក្នុងរបបខ្មែរក្រហមទេ ប៉ុន្តែបន្ទាប់ពីស្តាប់ការពន្យល់របស់ក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីសារសំខាន់នៃការចែករំលែករឿងរ៉ាវរបស់គាត់ យន ក៏យល់ព្រមនិយាយរឿងរ៉ាវរបស់គាត់ ។

យន បានចូលបដិវត្តន៍តាំងពីឆ្នាំ១៩៧៣ នៅស្រុកស្គន់តាមការណែនាំពីមនុស្សម្នាក់ឈ្មោះ សេង ជាយោធាឃុំ ។ កាលណោះ យន គ្មានគោលបំណងច្បាស់លាស់ឡើយ គាត់គ្រាន់តែដឹងថា មនុស្សប្រុសពេញវ័យត្រូវតែចូលធ្វើទ័ព ។ ឪពុកម្តាយរបស់ យន ក៏យល់ព្រមឲ្យកូនៗធ្វើទ័ពដែរ ។ យន មានតួនាទីជាប្រធានក្រុមផងនិងប្រធានពួកផង ។ ប្រធានរបស់ យន ឈ្មោះ តាអឿន ប្រធានកងពលលេខ១ និង ហាក់ ជាអនុប្រធាន ។ យន និងយុទ្ធមិត្តបានធ្វើដំណើររហូតដល់ព្រៃគ្រី ហើយបានចូលប្រយុទ្ធនៅសមរភូមិព្រៃគ្រីអស់រយៈពេលជាងពីរខែ ដោយទ័ពខ្មែរក្រហមស្លាប់ច្រើនណាស់នៅពេលនោះ ។ បន្ទាប់មក យន បន្តទៅវាយដល់ភ្នំប្រុសភ្នំស្រី រួចបន្តមកដល់ផ្សាវ ស្រុកបាធាយទៀត ។

មុនពេលវាយប្រយុទ្ធមកដល់ក្រុងភ្នំពេញប៉ុន្មានខែ យន បានឃើញរថយន្តហ្ស៊ីប៤គ្រឿងរបស់ទាហានស័ក្តិធំៗរបស់ លន់ ណុល មកសុំចរចាជាសម្ងាត់ជាមួយ តាអឿន និង ហាក់ នៅពេលយប់នៅបន្ទាយព្រែកតាគង់(ម្តុំភ្នំប្រសិទ្ធិ) ដោយនាំមកជាមួយនូវជំនូនជាច្រើន ។ ការចរចាមានរយៈពេលកន្លះខែ ។ យន និងកងទ័ព៥០នាក់ត្រូវបានចាត់តាំងឲ្យយាមល្បាតនៅក្នុងការចរចានេះ ។ បន្ទាប់ពីមន្ត្រីរបស់ លន់ ណុល ចាកចេញទៅគាត់និងប្រធានកងផ្សេងទៀត ចូលទៅយកជំនូននោះមកចែកកូនទាហាន ។ នៅពេលនោះ យន បានទទួលការព្រមានពី តាអឿន និង ហាក់ ថាប្រសិនបើរឿងនេះបែកការណ៍ គាត់នឹងត្រូវស្លាប់ទាំងពូជ ។ តាំងពីពេលនោះមក យន មិនដែលនិយាយប្រាប់នរណាឡើយ ។

នៅឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមវាយកាន់កាប់ទីក្រុងភ្នំពេញ ប្រជាជននៅក្នុងទីក្រុងទាំងអស់ត្រូវបណ្តេញចេញ ។ ចំណែក យន បានដកខ្លួនមកនៅភូមិភាគឧត្តរដើម្បីជួយធ្វើស្រែប្រជាជនមួយឆ្នាំ ។ នៅក្នុងឆ្នាំនោះ អង្គការដក យន មកនៅខ្មែរលើវត្តជុំខាងអង្គស្នួល ។ យន ត្រូវអង្គការបញ្ជូនឲ្យទៅលើកប្រឡាយស្ទើរពេញ២៤ម៉ោង លើកលែងតែពេលហូបបាយទេ ក្នុងមួយថ្ងៃ យន សម្រាកបានតែជាងកន្លះម៉ោងប៉ុណ្ណោះ ។ យន រៀបរាប់ថា «ធ្វើស្រែមិនដែលមានគោក្របីទេ ក្នុង៥នាក់ឲ្យបានមួយហិកតា ។ បើ៥នាក់មិនបានមួយហិកតាទេ គេដកម្នាក់សល់បួននាក់ ។ បើកាប់នឹងចប៥នាក់ហ្នឹងបានមួយហិកតា ស្អែកឡើងប្រធានកងពេញចិត្ត គេដាក់ថែមម្នាក់ឲ្យធូរកម្លាំងយើងបន្តិច ។ ដល់ពេលស្ទូងក្នុងមួយហិកតាមាន១៥នាក់» ។ យន ហូបមិនដែលឆ្អែតទេ ។ គាត់អាចរស់រានមានជីវិតដោយសារតែហូបត្នោតទុំ ។ មានទាហានខ្លះដើរលួចក្តាមរើសខ្យងតាមភ្លឺស្រែ នៅ

ពេលដែលអង្គការតាមទាន់ចាប់យកទៅដាក់គុកទាំងអស់ ។ យន និយាយថា «បើអ្នកណាឃ្លានដើរលួចខ្ទះក្តាមខ្ទះអីទៅគេវ៉ៃដាក់គុកដាក់ច្រវាក់ មួយជំនាន់ហ្នឹងវេទនាមែនទែន ។...ខ្ញុំរស់ដោយសារត្នោតទុំ ។ ត្នោតទុំត្រង់ណាខ្ញុំយកអង្រឹងទៅចងដេកត្រង់ហ្នឹង...» ។ ក្រោយមក យន បានស្នើអង្គការធ្វើជាអ្នកឡើងត្នោតដើម្បីបានរបបបន្ថែម ។ នៅពេលឡើងត្នោតម្តងៗ យន តែងតែលួចចិតផ្លែត្នោតយកគ្រាប់ដាក់នៅនឹងថ្នក់ចង្កេះយកមកចែកអ្នកធ្វើការជាមួយគ្នា ។

ធ្វើការនៅទីនោះប្រហែលជាពីរខែ អង្គការបានចាប់ផ្តើមដកប្រធានក្រុម ប្រធានកង ប្រធានកងធំ-តូច និងអ្នកចូលសម្ព័ន្ធពេញសិទ្ធិ ម្តង៥០នាក់ ៤០នាក់ ៣០នាក់ ឲ្យទៅរៀនសូត្រ ។ យន មិនត្រូវបានដកចេញឡើយ ព្រោះអង្គការទុកឲ្យឡើងត្នោត ។ យន ដឹងច្បាស់ថា អ្នកដែលត្រូវអង្គការដកទៅរៀនសូត្រទាំងប៉ុន្មាន គឺសុទ្ធតែដកយកទៅសម្លាប់ចោល ។ យន មិនដឹងថាអង្គការយកអ្នកទាំងនោះទៅសម្លាប់ចោលនៅកន្លែងណាទេ គាត់គ្រាន់តែដឹងថាអ្នកទាំងអស់នោះបានបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ ។ ក្រុមឡើងត្នោតរបស់ យន មានគ្នា៩នាក់ អ្នកអារខស៩នាក់ អ្នករម្ងាស់ស្ករ៩នាក់ ។ ក្នុងមួយថ្ងៃ យន ឡើងយកទឹកត្នោតបាន ២០ខ្ទះ ។

នៅក្នុងឆ្នាំ១៩៧៦ យន បានចូលរៀនវគ្គនយោបាយរយៈពេលកន្លះខែ ដែលមាន តាអឿន ជាអ្នកបង្រៀន ។ មេរៀននោះនិយាយសុទ្ធតែអំពីលទ្ធិផ្តាច់ការ មិនឲ្យគិតម៉ែឪបងប្អូន ពោលគឺឲ្យគិតតែពីរឿងបុគ្គលម្នាក់ៗនិងដាច់ខាត ។ នៅពេលរៀនចប់ តាអឿន បានបញ្ជូនសិក្ខាកាមទៅភ្នំប្រសិទ្ធិ អង្គរស្ស ដើម្បីលត់ដំ ។

នៅអំឡុងឆ្នាំ១៩៧៨ អង្គការបានរំសាយក្រុមធ្វើត្នោតដើម្បីយកកម្លាំងទាំងអស់នោះទៅប្រយុទ្ធទប់ទល់នឹងវៀតណាម ។ យន និងមិត្តរួមការងារត្រូវអង្គការបញ្ជូនទៅវាយនៅខេត្តកំពង់ចាម ។ យន បានឡើងវាយប្រយុទ្ធជាច្រើនកន្លែង ដូចជា ក្រែក មេមត់ ត្រពាំងផ្លុង ផ្សារក្រដាស ផ្សារផ្អាវ បន្ទាយស្នាច់ បន្ទាយ២៧ រួចបន្តទៅដល់ភ្នំដើងមីដែង(ទឹកដីវៀតណាម) ។ នៅក្នុងសមរភូមិ យន និងយុទ្ធមិត្តដាច់ស្បៀងអស់រយៈពេល៧ថ្ងៃ ហើយត្រូវកងទ័ពវៀតណាមដេញបាញ់រត់រហូតដល់ស្រុកកំណើតវិញ ។ យន បញ្ជាក់ថា «អត់មានអ្នកណាយកស្បៀងទៅឲ្យ ដាច់ស្បៀង៧ថ្ងៃខ្ញុំឆ្ងល់ហេតុម៉េចក៏អ្នកក្រោយមិនយកបាយយកអង្ករទៅឲ្យ ដល់ទៅគេវ៉ៃក្រោយខ្នង ខ្ញុំថាទ័ពនៅក្រោយគេចេះតែវ៉ៃ យើងប្រឹងតែទៅមុខ ។ ដល់ពេលថាដាច់ហើយ ខ្មែរក្រហមចាញ់ ខ្ញុំរត់តាំងពីហ្នឹងរហូតដល់ឆ្លងអ្នកលឿងឆ្លងអរិយក្សត្ររថក្រោះដេញបាញ់ខ្ញុំរហូតដល់ភ្នំពេញ រួចបកចុះបកឡើងបានរត់ទៅមកដល់ទីហ្នឹង ។ ខ្ញុំអត់ទៅទៀតទេ ចូលផ្ទះខ្ញុំហើយ ព្រោះខ្ញុំបែកម៉ែបែកឪ ខ្ញុំលែងទៅណាហើយ» ។

ក្រោយឆ្នាំ១៩៧៩ យន បានស្ម័គ្រចិត្តចូលបម្រើកងទ័ពអស់រយៈពេលបីឆ្នាំទៀត ប៉ុន្តែមិនបានធ្វើឲ្យជីវភាពរស់នៅរបស់គាត់ប្រសើរឡើយ ដោយហេតុនេះ យន បានសម្រេចចិត្តលាឈប់ពីការងារមកកសាងជីវិតថ្មីក្នុងជីវភាពជាកសិករវិញ ។

យន និយាយរឿងរ៉ាវទាំងនេះឲ្យអ្នកភូមិស្តាប់ ក្មេងៗបានចោទគាត់ថា «អឹងឯងធ្វើខ្មែរក្រហម» ។ យន មិនខ្វាចនឹងទទួលពាក្យនេះឡើយ ។ គាត់ផ្តាំកូនៗកុំឲ្យធ្វើដូចគាត់ ព្រោះការធ្វើសង្គ្រាមគ្មានបានផលប្រយោជន៍ទេ ។ យន និយាយថា «ខ្ញុំចង់ផ្តាំថា កូនអើយជំនាន់ក្រោយនេះ ធ្វើម៉េចបើថាសង្គ្រាម កូនឯងចេះតែគេចវេះៗ គេចរួចចេះតែគេចទៅ កុំទៅឲ្យសោះ វេទនាណាស់ អត់មានសេចក្តីសុខទេ ទុក្ខទាល់អស់មួយជីវិត ។ បានសុខស្រួលដូចសព្វថ្ងៃហ្នឹងខ្ញុំអរណាស់ អរចេញពីក្រអៅចេះដូងទោះបីអត់បាយក្រហាយទឹកយ៉ាងណា កូនចៅហូបចុកយ៉ាងម៉េចដូចថាយើងអាចលុបលាងកំហុសដែលខុសពីណោះមក» ។

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

◆ **បេ្តជ្ញាគោរពនិងអនុវត្តការដឹកនាំ និងធ្វើការដោយស្មារតីទទួលខុសត្រូវខ្ពស់ និងចាត់ចែងការងារដោយស្វាហាប់ ច្នៃប្រឌិតកសាងរស់រវើក ដើម្បីបម្រើចលនាឱ្យឆាប់និងល្អបំផុត។**

(ដកស្រង់ចេញពីសៀវភៅយស់ សុ)

# ព្រះតេជគុណ ប៉ែន សេន ព្រះសង្ឃក្នុងរបបខ្មែរក្រហម

នៅក្នុងខណៈដែលព្រះពុទ្ធសាសនានិងសាសនាដទៃទៀត ត្រូវលុបបំបាត់ចោលទូទាំងប្រទេសនៅក្នុងរបបខ្មែរក្រហម ព្រះសង្ឃមួយអង្គព្រះនាម ប៉ែន សេន ស្ថិតនៅជាសង្ឃរហូតដល់ថ្ងៃបញ្ចប់នៃរបបនេះ ។ រឿងរ៉ាវរបស់ព្រះតេជគុណ ប៉ែន សេន ដែលអ្នកភូមិស្គាល់ថា ព្រះអង្គស បានក្លាយជារឿងរ៉ាវមួយ ដែលប្រជាជននៅភូមិជើងផ្នូក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ដឹងឮគ្រប់ៗគ្នា ។


ព្រះតេជគុណ ប៉ែន សេន

កាលអាយុ១២ឆ្នាំ(ក្នុងឆ្នាំ១៩០៨) មាតាបិតាបាននាំកុមារ ប៉ែន សេន ទៅរៀនអក្សរសាស្ត្រជាតិនៅវត្តតាំងស្រែ ក្នុងសង្កាត់តាំងគោក ស្រុកជើងព្រៃ ខេត្តកំពង់ចាម ក្នុងសំណាក់ព្រះគ្រូសុវណ្ណបទុមកុល ។ លុះដល់រៀនយល់ដឹងល្មមពីអក្សរសាស្ត្រជាតិហើយ លោកក៏បួសជាសាមណេរក្នុងអាយុ១៣ឆ្នាំក្នុងគណៈធម្មយុត្តិ នៅវត្តសុវណ្ណគិរី ជើងផ្នូក និងបួសបំពេញភិក្ខុក្នុងព្រះជន្ម២១វស្សា ។ បន្ទាប់មកលោកបានទៅសិក្សានៅប្រទេសថៃអស់ក្នុងរយៈពេល៨ឆ្នាំ ។ ពេលដែលព្រះគ្រូសុវណ្ណបទុម កុល ទទួលអនិច្ចធម្ម ប្រជាជននៅក្នុងភូមិបាននិមន្តលោកធ្វើជាព្រះចៅអធិការវត្តសុវណ្ណគិរី ជើងផ្នូក បន្តពីគ្រូរបស់លោក ។

លោកតា កៅ ធិន ជាអាចារ្យវត្តសុវណ្ណគិរី និងត្រូវជាប្អូនជីដូនមួយរបស់ព្រះតេជគុណ ប៉ែន សេន បានរៀបរាប់ថា ខ្មែរក្រហមបានគ្រប់គ្រងតំបន់ខាងលើនេះតាំងពីមុនឆ្នាំ១៩៧៥ ហើយបានបង្ខំឲ្យព្រះសង្ឃធ្វើផ្លូវស្ពាន ធ្វើស្រែបង្កបង្កើនផល ជាមួយនឹងប្រជាជន ព្រះសង្ឃអង្គខ្លះជិះកង់យកនំកាតំនិងមាន់ទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ ភ្លាមៗបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានព្រះសង្ឃខ្មែរក្រហមដែលបំពាក់ដោយកាំភ្លើងខ្លីនិងមានកងការពារអមដង ដើរឃោសនាក្នុងចំណោមប្រជាជនអំពីមនោគមវិជ្ជារបស់ខ្មែរក្រហម ។ ប្រជាជនស្គាល់ច្បាស់ប្រធានសង្ឃដែលខ្មែរក្រហមតែងតាំងគឺជាជនប្រមឹកម្នាក់នៅក្នុងឃុំកងតាណឹង ហើយពុំដែលបួសរៀននៅក្នុងព្រះពុទ្ធសាសនាទាល់តែសោះ ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមប្រមូលព្រះសង្ឃនៅតាមវត្តឲ្យចូលរួមធ្វើស្រែ សង់ស្ពាន លើកប្រឡាយ ធ្វើសិប្បកម្ម ប៉ុន្តែអនុញ្ញាតឲ្យស្លៀកស្បង់ចីវរ ។ ប្រហែលអំឡុងពាក់កណ្ដាលឆ្នាំ១៩៧៦ ព្រះសង្ឃទាំងអស់ត្រូវបង្ខំឲ្យសឹក ។ ព្រះតេជគុណ ប៉ែន សេន ប្រកែកដាច់អហង្ការមិនព្រមសឹក ។ លោកតា កៅ ធិន ដែលកាលណោះជាកូនសិស្សរបស់លោកបានស្នើសុំខ្មែរក្រហមរក្សាទុកព្រះតេជគុណ ប៉ែន សេន ដោយសុំកសាងកុដិតូចមួយនៅចង្កេះភ្នំជើងផ្នូកជូនលោកស្នាក់នៅ និងសុំឲ្យក្មេងប្រុសម្នាក់ឈ្មោះ លឹម អេង នៅចាំបម្រើលោក ។ ដោយសារតែកម្មាភិបាលខ្មែរក្រហមមួយចំនួនធ្លាប់គោរពប្រតិបត្តិព្រះតេជគុណ ប៉ែន សេន ពីពេលមុន និងដោយសារចៅប្រុសម្នាក់របស់លោកគឺជាគណៈស្រុកបាធាយផងនោះ កម្មាភិបាលខ្មែរក្រហមពុំបានឆ្លើយថាយល់ព្រមឬក៏បដិសេធទេ គឺធ្វើមិនដឹងមិនឮចំពោះសំណើនេះ ។

ចាស់ៗបាននាំគ្នាកសាងកុដិ និងប្រារព្ធពិធីបុណ្យឡើងកុដិនៅពេលយប់ដែលមានព្រះតេជគុណ ប៉ែន សេន តែមួយអង្គឯងសូត្រធម៌ក្នុងពិធីនោះ ។ ព្រះតេជគុណបានរក្សាទុកព្រះពុទ្ធរូបនិងសៀវភៅធម៌ជាច្រើនក្បាលនៅក្នុងកុដិរបស់លោក ។ ប្រជាជនតែងតែប្រគេនចង្ហាន់ដល់ព្រះតេជគុណនៅក្នុងលក្ខណៈលួចលាក់ ហើយច្រើនតែយកទៅនៅពេលយប់ ។ មិនតែប៉ុណ្ណោះកម្មាភិបាលថ្នាក់ធំៗក៏យកចង្ហាន់មកប្រគេនលោកមិនឲ្យដាច់ដែរ ។ ព្រះអង្គមានវិទ្យុមួយគ្រឿង លោកស្ដាប់តែប៉ុស្តិ៍ពីរទេ គឺប៉ុស្តិ៍អាមេរិកនិងប៉ុស្តិ៍ថៃ ។ កុដិរបស់លោកប្រៀបបានដូចជាកន្លែងមជ្ឈិមសម្រាប់ប្រជាជនរងគ្រោះនិងជនដៃដល់ ។ ប្រជាជនដែលមានសាច់ញាតិស្លាប់ឬបាត់ខ្លួនតែងតែលួចមកជួបលោកនៅពេលយប់ ដោយនាំមកជាមួយនូវម្ហូបអាហារប្រគេនលោក

ដើម្បីបង្សុកូលឧទ្ទិសកុសលផលបុណ្យដល់អ្នកទាំងនោះ ។ តារ៉ស់ ដែលជាអ្នកសម្លាប់មនុស្សប្រចាំតំបន់បានមកជួបលោកនៅវេលាយប់ ដោយយកសាច់គោសាច់ជ្រូកមកប្រគេនលោកផង ។ តារ៉ស់ និយាយថា គាត់មិនដឹងធ្វើយ៉ាងម៉េចទេ ពិបាកចិត្តណាស់ ចេះតែធ្វើតាមគេ បើគេបញ្ជូនមកហើយត្រូវតែសម្លាប់ ។ ប្រពន្ធរបស់ប្រធានសង្កាត់ឈ្មោះ ហៀង ក៏ធ្លាប់យកចង្ហាន់មកប្រគេនលោកដែរដើម្បីបង្សុកូលឲ្យកូនរបស់គាត់ដែលស្លាប់ទៅ ។ ប្តីប្រពន្ធមួយចំនួនដែលខ្មែរក្រហមបានរៀបការឲ្យ បាននាំគ្នាមកសុំពរជ័យពីលោកតា ប៉ែន សេន នៅវេលាយប់ ខ្លះទៀតម៉ែឪមកជំនួស ។ ទាំងប្រជាជនក៏ដូចជាកងទ័ពខ្មែរក្រហមតែងតែមកសុំពរជ័យពីព្រះអង្គមុនពេលចេញទៅធ្វើការនៅទីឆ្ងាយៗ ។ ពិធីបុណ្យភ្ជុំបិណ្ឌអាចធ្វើបាននៅថ្ងៃចុងក្រោយនៃបិណ្ឌ ប៉ុន្តែមានតែឪពុកម្តាយរបស់កម្មាភិបាលថ្នាក់ធំៗប៉ុណ្ណោះដែលអាចទៅធ្វើបុណ្យបាន ។

នៅឆ្នាំ១៩៧៦ គណៈសង្កាត់ គណៈស្រុក ត្រូវអង្គការសម្លាប់ចោលដោយចោទថាជាប់ខ្សែក្បត់ ហើយផ្លាស់ប្តូរថ្នាក់គ្រប់គ្រងថ្មីមកពីភូមិភាគនិរតី ។ កម្មាភិបាលថ្មីបានប្តឹងទៅគណៈស្រុក អំពីលោកតា ប៉ែន សេន ដែលមិនព្រមសឹក ។ គណៈស្រុកឈ្មោះ ហួយ មកពីភូមិភាគនិរតីដែលធ្លាប់បានស្តាប់ព្រះតេជគុណទេសនា កាលពីគាត់បួសជានេន និងធ្លាប់គោរពបូជាព្រះតេជគុណ បានបញ្ជាមិនឲ្យប៉ះពាល់ប្ញៃខានព្រះតេជគុណ ប៉ែន សេន ឡើយ ជាហេតុធ្វើឲ្យកម្មាភិបាលថ្នាក់ក្រោមរឹតតែគោរពលោកថែមទៀត ។

ក្រោយរបបខ្មែរក្រហមដួលរលំ អតីតព្រះសង្ឃមួយចំនួនបានបួសឡើងវិញដោយពុំមានការអនុញ្ញាតត្រឹមត្រូវតាមផ្លូវច្បាប់ ។ រដ្ឋអំណាចបានផ្សឹកព្រះសង្ឃទាំងអស់នោះវិញ ដើម្បីធ្វើពិធីបំបួសសាជាថ្មីឲ្យបានត្រឹមត្រូវតាមច្បាប់ ។ ដោយមិនបានដឹងថាព្រះតេជគុណ ប៉ែន សេន នៅតែរក្សាភាពជាបព្វជិតនៅក្នុងរបបខ្មែរក្រហម រដ្ឋអំណាចក៏បានសុំផ្សឹកលោកដែរ ប៉ុន្តែប្រជាជនរាប់រយនាក់បានផ្តិតមេដៃធ្វើជាសាក្សីថាលោកមិនបានសឹកទេនៅក្នុងរបបខ្មែរក្រហម ។ ព្រះតេជគុណ ប៉ែន សេន បានធ្វើជាចៅអធិការនៅវត្តសុវណ្ណគិរីដើងឆ្នុករហូតដល់ឆ្នាំ១៩៨៩ ទើបទទួលអនិច្ចធម្មក្នុងព្រះជន្មាយុ៩៤ព្រះវស្សា ។

**ព្រំ ផល្លា**



កូនសិស្សរបស់ព្រះតេជគុណ ប៉ែន សេន ដែលនៅរស់ដល់សព្វថ្ងៃ


210

# ច្បាប់កម្ពុជាទាក់ទងនឹងដីកាចាប់ខ្លួន

"បទបញ្ញត្តិស្តីអំពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល" អនុម័តនាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលត្រូវគេស្គាល់ជាទូទៅថាជា"ច្បាប់អ៊ុនតាក់" មានមាត្រាចំនួនពីរដែលរៀបរាប់អំពីដីកាចាប់ខ្លួននៅក្នុងប្រទេសកម្ពុជាគឺៈ

**មាត្រា១៨ៈ បទល្មើសជាក់ស្តែង**

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺថាៈ

១) បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងប្រព្រឹត្តបទឧក្រិដ្ឋឬបទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប៉ដាប់ចាប់ពកឹង ។

២) បើជនសង្ស័យត្រូវបានសាក្សីឬអ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្មឬបទល្មើសថាជាពិរុទ្ធជន ។

◆ បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋឬបទល្មើស ។

**មាត្រា១៩ៈ ការចាប់ខ្លួនដោយសំអាងលើភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់**

១) នៅក្នុងករណីផ្សេងទៀត នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបានលុះត្រាតែមានភ័ស្តុតាងជាក់ស្តែងយ៉ាងច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញឲ្យឃើញថាជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈិមមែន ។

២) បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញាឬចៅក្រមដែលនឹងត្រូវអនុវត្តដោយនគរបាលតុលាការ ។

៣) ដីកាចាប់ខ្លួនត្រូវបានបញ្ជាក់ពីអំពើនិងមូលហេតុទាំងឡាយដែលនាំឲ្យមានការចាប់ខ្លួនជនជាប់សង្ស័យ ។

៤) ដោគវាសនារបស់ជនដែលត្រូវចាប់ខ្លួន ត្រូវបានចាត់ចែងតាមលក្ខន្តិកៈនៅក្នុងមាត្រា១៣នៃបទបញ្ញត្តិនេះ ។

៥) ម្យ៉ាងទៀត តាមដីកាបង្គាប់ឲ្យឡើងសាលារបស់រដ្ឋអាជ្ញា ចៅក្រមនគរបាលអាចនាំខ្លួនជនគ្រប់រូបដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកាកោះមកបង្ហាញខ្លួនចំពោះមុខនាយនគរបាលឬ ចៅក្រម ឬរដ្ឋអាជ្ញា ។ ក្រោយពីតុលាការបានសាកសួររួចហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់លើកលែងតែក្នុងករណីមានភ័ស្តុតាងជាក់ស្តែងយ៉ាងច្បាស់លាស់ហើយស៊ីសង្វាក់គ្នាដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី១៣នៃបទបញ្ញត្តិនេះ ។

ចំណុចទី១នៃមាត្រាទី១៩ត្រូវបានបកស្រាយយ៉ាងទៀងទាត់ដោយតុលាការនៅក្នុងប្រទេសកម្ពុជាថា នៅពេលដែលមាន "ភ័ស្តុតាងជាក់ស្តែងយ៉ាងច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាដែលបង្ហាញឲ្យឃើញថាជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋឬបទមជ្ឈិមមែន" ដីកាចាប់ខ្លួនមិនត្រូវបានទាមទារឲ្យចេញដើម្បីគាំទ្រ(ផ្តល់អំណាច)ដល់ការចាប់ខ្លួនជនសង្ស័យទេ ។ នៅពេលយកមកអានដាច់ដោយឡែកមាត្រា១៩(១)ហាក់បីដូចជានាំឲ្យមានការយល់ឃើញដូច្នោះ ។ ប៉ុន្តែការបកស្រាយបែបនេះចំពោះមាត្រា១៩(១) រំលោភទៅលើវិធានជាមូលដ្ឋាននៃការបកស្រាយលក្ខន្តិកៈច្បាប់ ហើយផ្ទុយទាំងស្រុងទៅនឹងហេតុ-ផលគាំទ្រដីកាចាប់ខ្លួន ។

មាត្រាទី១៨ត្រូវបានដាក់ចំណងជើងយ៉ាងច្បាស់និងមិនស្រពេចស្រពិលថា "ការចាប់ខ្លួនដោយគ្មានដីកា" ប្រែពីច្បាប់ជាភាសាអង់គ្លេសដែលសរសេរថា (arrest without a warrant) ហើយរៀបរាប់ថា ការចាប់ខ្លួនបែបនោះអាចត្រូវធ្វើឡើងនៅពេលដែលជនសង្ស័យត្រូវបាន "ចាប់ខ្លួនក្នុងពេលកំពុងធ្វើសកម្មភាព" ឬត្រូវគេស្គាល់នៅក្នុងច្បាប់ថាជាបទល្មើសជាក់ស្តែង ។ គ្មានចំណុចណាមួយនៅក្នុងមាត្រា១៨រៀបរាប់ថា បទបញ្ញត្តិនោះមិនត្រូវបានសរសេរក្នុងគោលបំណងគ្របដណ្តប់ទៅលើគ្រប់

កាលៈទេសៈដែលការចាប់ខ្លួនដោយគ្មានដីកាអាចធ្វើបានទេ ។ ឃ្លាដំបូងនៃមាត្រាទី១៩ «នៅក្នុងករណីផ្សេងទៀតទាំងអស់» គាំទ្រទៅលើចេតនារបស់មាត្រាទី១៨បន្ថែមទៀតថាមាត្រា១៨ តែមួយប៉ុណ្ណោះដែលបកស្រាយអំពីការចាប់ខ្លួនដោយគ្មានដីកា ។

នៅក្រោមអភិបាលកិច្ចដែលផ្អែកទៅលើការបែងចែកអំណាច ការចាប់ខ្លួនដោយគ្មានដីកាត្រូវបានកំណត់ឲ្យធ្វើបានតែក្នុងករណីកំណត់មួយចំនួនដែលអាជ្ញាធរចាំបាច់ត្រូវធ្វើសកម្មភាពជាបន្ទាន់ដើម្បីឃាត់ខ្លួនជនសង្ស័យមួយរូបនៅក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋ ឬភ្លាមៗក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋ ។ ហេតុនេះច្បាប់អនុញ្ញាតឲ្យនគរបាលធ្វើសកម្មភាពដោយឯករាជ្យនិងទៅតាមជំនាញនៅក្នុងកាលៈទេសៈបន្ទាន់ដែលទាមទារឲ្យមានការធ្វើអន្តរាគមន៍ភ្លាមៗ ។ ក្នុងពេលជាមួយគ្នានោះ ច្បាប់ដាក់ដែនកំណត់ទៅលើអំណាចរបស់នគរបាលតាមរយៈការប្រើប្រាស់ការត្រួតពិនិត្យពីតុលាការ(ដូចជា ដីកាចាប់ខ្លួន) នៅក្នុងពេលណាដែលកាលៈទេសៈពិសេសទាមទារឲ្យមានការធ្វើអន្តរាគមន៍ជាបន្ទាន់មិនលេចឡើង ។ ដូច្នេះទ្រឹស្តីជុំវិញដីកាចាប់ខ្លួន ដែលជាអំណាចមួយប្រគល់ឲ្យដោយតុលាការទៅកាន់នគរបាល អនុញ្ញាតឲ្យនគរបាលចាប់ខ្លួនបុគ្គលមួយរូបនៅក្នុងករណីអវត្តមានកាលៈទេសៈបន្ទាន់ដូចមានរៀបរាប់តាមបែបសម្រាយនៅក្នុងមាត្រាទី១៨ ។ ចំណុចសំខាន់ដែលត្រូវពិចារណានោះគឺថា ការចាប់ខ្លួនដោយគ្មានដីកាជាករណីលើកលែង ហើយត្រូវបានកំណត់ដោយចេតនាឲ្យប្រើតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ។

ច្បាស់ណាស់ មាត្រាទី១៩ត្រូវបានសរសេរដោយមិនបានប្រុងប្រយ័ត្ន ។ ចំណុចទី១គួរតែរៀបរាប់ថា «ភ័ស្តុតាងជាក់ស្តែងយ៉ាងច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញឲ្យឃើញថាជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមមែន» ជាតំណាងឲ្យភ័ស្តុតាងចាំបាច់ដែលនគរបាលនឹងត្រូវទាមទារឲ្យយកទៅបង្ហាញនៅក្នុងតុលាការ ដើម្បីជាផ្លូវនៃការចេញដីកាចាប់ខ្លួន ។

គួរឲ្យសោកស្តាយណាស់ ការធ្វើសេចក្តីព្រាងដ៏ធ្វេសប្រហែសនេះបានបង្កឲ្យមានការបកស្រាយមាត្រាទី១៩មួយបែបដែលប្រគល់អំណាចមិនកំណត់ទៅឲ្យនគរបាលក្នុងការធ្វើឲ្យមានសុពលភាពនៃការចាប់ខ្លួនដោយពុំចាំបាច់មានការត្រួតពិនិត្យពីតុលាការ ។ ទោះបីជាមាត្រាទី១៩(១)ទាមទារឲ្យមានភ័ស្តុតាងក្នុងកម្រិតអប្បបរមាមួយមុនពេលការចាប់ខ្លួនត្រូវបានធ្វើឡើង នគរបាលជាអ្នកកំណត់ថាតើនៅពេលណាទើបកម្រិតអប្បបរមានោះត្រូវបានបំពេញ ។ ជាលទ្ធផល បើតាមមាត្រាទី១៩នៃច្បាប់អ៊ុនតាក់ដែលបកស្រាយដោយតុលាការកម្ពុជា ដីកាចាប់ខ្លួនមិនដែលទាមទារឲ្យមាននោះទេ ។

គួរកត់សម្គាល់ថា វិធានជាមូលដ្ឋាននៃការបកស្រាយលក្ខន្តិកៈច្បាប់ដែលចែងថា «ការបកស្រាយផ្នែកមួយនៃលក្ខន្តិកៈច្បាប់ដែលធ្វើឲ្យផ្នែកមួយទៀតនៃលក្ខន្តិកៈច្បាប់នោះគ្មានអត្ថន័យត្រូវចៀសវាង ហើយត្រូវទទួលយកការបកស្រាយមួយទៀតដែលផ្តល់ឥទ្ធិពលសមរម្យទៅឲ្យគ្រប់ផ្នែកនៃលក្ខន្តិកៈ» ត្រូវបានរំលោភបំពានដោយការបកស្រាយខាងលើទៅលើមាត្រា១៩(១) នៃច្បាប់អ៊ុនតាក់ ។ ការបកស្រាយនេះត្រូវបានយកទៅប្រើប្រាស់ដោយតុលាការកម្ពុជាដែលធ្វើឲ្យមាត្រាទី១៨និងដែនកំណត់នៃមាត្រានេះដែលផ្តល់អំណាចដល់នគរបាលក្នុងការចាប់ខ្លួនដោយគ្មានដីកា ប្រែជាគ្មានអត្ថន័យ ។

**រ៉ាមិន ចូហាន់សិន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ឆ្លើយតបទៅនឹងអត្ថបទៈ ច្បាប់កម្ពុជាទាក់ទងនឹងដីកាចាប់ខ្លួន

នេះគឺជាអ្វីដែលខ្ញុំតែងតែលើកយកមកវែកញែកនៅក្នុងតុលាការកម្ពុជាកាលពីពេលដែលខ្ញុំកំពុងបម្រើការផ្នែកច្បាប់នៅទីនោះ ប៉ុន្តែមិនដែលចេញលទ្ធផលអ្វីទេ ។ ការវែកញែករបស់ខ្ញុំត្រូវគេមិនអើពើទាំងចៅក្រមនិងព្រះរាជអាជ្ញា ។ ចៅក្រមជំនុំជម្រះក៏មិនដែលសម្រេចសេចក្តីអំពីការវែកញែកនេះ ហេតុនេះនៅទីបញ្ចប់ ខ្ញុំមិនដឹងថាហេតុផលរបស់ខ្ញុំត្រូវឬខុស ។

បើតាមអ្វីដែល ស្ទីវ ហេឌ័រ បានប្រាប់ខ្ញុំ ច្បាប់អ៊ុនតាក់ត្រូវបានព្រាងដោយចៅក្រមបារាំងម្នាក់ដែលកាលនោះគឺជាប្រធានផ្នែករដ្ឋបាលស៊ីវិលរបស់អ៊ុនតាក់ ។ ច្បាប់នេះត្រូវបានព្រាងឡើងយ៉ាងរហ័សបំផុត កន្លែងខ្លះស្រង់ទាំងស្រុងចេញពីច្បាប់ដើម ហើយបកប្រែជាភាសាខ្មែរយ៉ាងធ្វេសប្រហែស ។ នៅត្រង់ចំណុចខ្លះខ្ញុំមិនទាំងយល់ថាអ្នកបកប្រែចង់និយាយអំពីអ្វីផង ។

ដោយសារច្បាប់នេះត្រូវបានកាត់ហើយយកមកបិទពីលើដោយបទបញ្ញត្តិផ្សេងៗនៃច្បាប់បារាំងដូច្នេះ បើចង់ស្វែងយល់អំពីច្បាប់នេះ ខ្ញុំត្រូវទៅអានច្បាប់ដើមរបស់បារាំងនិងឯកសារច្បាប់ពាក់ព័ន្ធ ។ ជាក់ស្តែងមាត្រា៦៣នៃច្បាប់អ៊ុនតាក់ដែលចែងអំពី"ការបរិហារកេរ្តិ៍និងការជេរប្រមាថ" គឺជា "ការថតចម្លង" ទាំងស្រុងពីមាត្រា២៩(?)នៃច្បាប់បារាំងដែលចែងអំពីសេរីភាពសារព័ត៌មានឆ្នាំ១៨៨១ ។ (ច្បាប់ខ្មែរស្តីអំពីសារព័ត៌មានឆ្នាំ១៩៩៤ ក៏ជាការសង្ខេបចេញពីច្បាប់បារាំងឆ្នាំ១៨៨១នេះដែរ) ។ មាត្រានេះត្រូវបានប្រើប្រាស់យ៉ាងពេញលេញនិងខុសឆ្គងដោយអាជ្ញាធរខ្មែរ ។ (ថ្មីៗនេះម៉ាត់ រីត ចាងហ្វាងការសែត ឌឹ ខែមបូឌា ដេលី បានក្លាយទៅជាជនរងគ្រោះនៃមាត្រានេះ ដែលត្រូវដាក់ទោសចំពោះការនិយាយថា ស្វាយស៊ីថា គឺជាទីប្រឹក្សារបស់សម្តេច ហ៊ុន សែន នៅពេលដែលគាត់មិនមែន) ។ បារាំងលែងប្រើប្រើច្បាប់នេះតាំងពីឆ្នាំ១៩៦៩ នៅពេលដែលប្រធានាធិបតី ឌឺ ហ្គោល បានលាលែងពីតំណែង ។ ប្រហែលជាបារាំងយល់ថា ច្បាប់នោះជាគ្រោះថ្នាក់មួយចំពោះសេរីភាពស៊ីវិលនៅក្នុងសង្គមប្រជាធិបតេយ្យដូចជាប្រទេសបារាំងហើយ ។ អាជ្ញាធរខ្មែរប្រហែលជាសប្បាយចិត្តណាស់ដែលចៅក្រមបារាំងយកច្បាប់ដដែលមកអនុវត្តឡើងវិញនៅក្នុងប្រទេសកម្ពុជា ហើយមិនបានពន្យល់អំពីការប្រើប្រាស់ច្បាប់នេះនៅប្រទេសបារាំង ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៤ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការសាលាឧទ្ធរណ៍ ហង់រ៉ូ រ៉ាកេន បានផ្ញើលិខិតមួយទៅព្រះរាជអាជ្ញាតុលាការខេត្តបាត់ដំបង បន្ទាយមានជ័យ និង សៀមរាប ស្នើឲ្យព្រះរាជអាជ្ញាទាំងបីរូបចោទប្រកាន់និងចេញដីកាចាប់ខ្លួនអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបីរូបគឺ ខៀវ សំផន, នួន ជា និង អៀង សារី ដោយមូលហេតុថា មេដឹកនាំទាំងបីអាចគេចខ្លួនទៅបរទេស ។ សំណើឲ្យចោទប្រកាន់និងចេញដីកានេះ លោក ហង់រ៉ូ រ៉ាកេន ផ្អែកទៅលើមាត្រាទី១,២,៤,៥ និង ៦ នៃច្បាប់ស្តីពីការដាក់ក្រុម"កម្ពុជាប្រជាធិបតេយ្យ" ឲ្យនៅក្រៅច្បាប់ដែលអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៤ ។

ចំពោះករណី អៀង សារី លោក ហង់រ៉ូ រ៉ាកេន បានស្នើឲ្យព្រះរាជអាជ្ញាទាំងបីរូបពិនិត្យទៅលើព្រះរាជក្រឹត្យលើកលែងទោសជាមុន ។

**ឌុច ចូរ៉ា**

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០-៣ៈ៤៥នាទី តាមរយៈវិទ្យុ ១០២ MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# ការអភិវឌ្ឍន៍ដ៏ធំសម្រាប់យុត្តិធម៌អន្តរជាតិ

បើតាមមូលហេតុជាច្រើនយ៉ាងការចាប់បដិសន្ធិនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺជាការអភិវឌ្ឍន៍ថ្មីសន្ធាង ថែមទាំងជាជំហានបដិវត្តន៍មួយដែលត្រូវតែពិចារណានៅក្នុងបរិបទដ៏ត្រឹមត្រូវរបស់វាៈ ចក្ខុវិស័យនៃសហគមន៍អន្តរជាតិដែលកំពុងលេចចេញ ។

ជាទូទៅគេទទួលស្គាល់ថាមានទម្រង់ពីរនៃទំនាក់ទំនងច្បាប់អន្តរជាតិៈ ទម្រង់បែបប្រពៃណី ដែលគេឲ្យឈ្មោះថា «ហ្គ្រូធៀន» (តាមឈ្មោះរបស់បញ្ញាជនជាតិហុល្លង់នាសតវត្សរ៍ទី១៧ ហ៊ូហ្គូ ហ្គ្រូធៀន) និងទម្រង់ថ្មីមួយដែលអាចហៅថា«កាន់ធៀន» (ឈ្មោះទាំងនេះមានទម្រង់ជាអក្សរកាត់ ដែលស្របទៅតាមចំណាត់ថ្នាក់តាំងពីយូរមកដែលប្រើប្រាស់ដោយអ្នកវិទ្យាសាស្ត្រនយោបាយ) ។ ទម្រង់ទាំងពីរកំពុងប្រជែងគ្នាយកឧត្តមភាពនៅក្នុងសហគមន៍អន្តរជាតិ ។

## ប្រព័ន្ធមួយដែលពឹងផ្អែកទៅលើរដ្ឋ

ទម្រង់«ហ្គ្រូធៀន»ពឹងផ្អែកទៅលើទ្រឹស្តីទូទៅមួយចំនួន ។ ទី១) រដ្ឋគឺជាតួអង្គផ្ទាល់មុខឬស៊ើរតែផ្ទាល់មុខនៅលើឆាកអន្តរជាតិ ។ ជាទូទៅសមាសភាពអរូបីទាំងនេះមានទំហំធំជានិមិត្តរូបនិងបង្ហាញយ៉ាងច្បាស់លាស់នូវគោលគំនិតជាក់លាក់របស់រដ្ឋ ដែលជួនកាលមិនមានលក្ខណៈស្រដៀងគ្នាទៅនឹងបុគ្គលទាំងឡាយដែលរដ្ឋទាំងនោះជួសមុខឲ្យទេ ។ រដ្ឋគឺជាអន្តរការីនៅក្នុងអន្តរការណ៍អន្តរជាតិ ។ ទី២) ការគោរពចំពោះអធិបតេយ្យភាព រដ្ឋគឺជាចំណុចសំខាន់នៃរាល់ទំនាក់ទំនងអន្តរជាតិទាំងអស់ ។ ទី៣) ការផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ។ ទស្សនៈដែលថារាល់ទំនាក់ទំនងអន្តររដ្ឋគឺពឹងផ្អែកទៅលើចំណូលចិត្ត(សេចក្តីត្រូវការ)ផ្ទាល់ខ្លួន ហើយថារដ្ឋចូលរួមនៅក្នុងការពិភាក្សាផ្នែកច្បាប់ជាអន្តរជាតិជាចម្បងដើម្បីជំរុញដល់ការសម្រេចវត្ថុបំណងផ្ទាល់ខ្លួនតាមរយៈការសម្របសម្រួលបំណងទាំងនោះទៅនឹងបំណងរបស់រដ្ឋផ្សេងដែលចង់ទាក់ទងជាមួយ ។

លុះត្រាតែការចង់បានរបស់រដ្ឋជាច្រើនប្រសព្វគ្នាទើបបទដ្ឋានច្បាប់ទូទៅនោះលេចរូបរាងឡើងគឺបទដ្ឋានដែលសមស្របចំពោះរដ្ឋទាំងអស់ ។ ឧទាហរណ៍នៃច្បាប់ទូទៅបែបនោះមានដូចជាច្បាប់ស្តីអំពីទំនាក់ទំនងការទូតឬកុងស៊ុលស្តីអំពីសន្ធិសញ្ញាអន្តរជាតិសេរីភាពនៅលើសមុទ្រអន្តរជាតិ ដែនសមុទ្រជាប់ទ្វីប ការប្លន់តាមសមុទ្រ ។ល ។ ដោយសារបំណងមិនស្របគ្នារបស់រដ្ឋទាំងឡាយបានរារាំងដល់ការបង្កើតស្ថាប័នរួម ដែលត្រូវបានប្រគល់តួនាទីតាមទម្លាប់ចំនួនបីដែលរដ្ឋនីមួយៗខំប្រឹងបំពេញនៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួន(ការធ្វើច្បាប់ ការដោះស្រាយជម្លោះក្នុងតុលាការនិងការជំរុញឲ្យបំពេញតាមបទដ្ឋានច្បាប់) ការបំពេញតួនាទីទាំងនេះត្រូវបានប្រគល់ឲ្យសមាជិកនីមួយៗនៃសហគមន៍អន្តរជាតិ ។

ជាលទ្ធផល ឯកតោភាគីនិយមក៏លេចឡើង ។ វាធ្វើឲ្យរដ្ឋនីមួយៗមាននាទីកំណត់នៅពេលដែលរដ្ឋនោះចាប់អារម្មណ៍ក្នុងការកំណត់បទដ្ឋានច្បាប់ថ្មីវិធីដែលរដ្ឋនោះចង់ប្រើប្រាស់ដើម្បីដោះស្រាយជម្លោះជាមួយរដ្ឋផ្សេង ហើយថាតើត្រូវប្រើកម្លាំងទ័ពឬក៏អត់ ដើម្បីធានាថាវត្ថុបំណងរបស់ខ្លួនត្រូវបានបំពេញ ។

## ទម្រង់ថ្មីនៃសហគមន៍អន្តរជាតិ

ផ្ទុយទៅវិញ ទម្រង់«កាន់ធៀន»ពឹងផ្អែកទៅលើការសន្និដ្ឋានមួយចំនួនប្លែកពីគេ ។ ទីមួយគឺសញ្ញាណដែលថា ទោះបីជារដ្ឋនៅតែជាតួអង្គសំខាន់នៅលើឆាកអន្តរជាតិ បុគ្គលទាំងឡាយគឺជាការចាប់អារម្មណ៍នៃទំនាក់ទំនងអន្តរជាតិកាន់តែខ្លាំងឡើង ។ មានន័យថារដ្ឋគួរតែដើរតួពិសេសជាតំណាងរបស់បុគ្គល ។ ពីមុនបុគ្គលអាចចូលរួមនៅក្នុងទំនាក់ទំនងអន្តររដ្ឋបានតាមរយៈរដ្ឋ ។ បច្ចុប្បន្នបុគ្គលបានក្លាយជាប្រធានបទនៃការចរចាអន្តរជាតិ ដោយផ្ទាល់ដោយមានការរួមចំណែកកាន់តែច្រើនអំពីការប្រព្រឹត្តទៅនៃការចរចា ។ លក្ខណៈទីពីរនៃទម្រង់«កាន់ធៀន»គឺជាការជឿជាក់ទៅលើមូលដ្ឋាននៃតម្លៃជាសកល (សន្តិភាពការគោរពសិទ្ធិមនុស្សការសម្រេចចិត្តដោយខ្លួនឯងរបស់មនុស្ស) ដែលសមាជិកទាំងអស់

នៃសហគមន៍អន្តរជាតិត្រូវតែគោរព ។ ម្យ៉ាងវិញទៀត ជាមួយនឹងការចាប់អារម្មណ៍របស់ជាតិនិងទំនាក់ទំនងផ្តល់ផលប្រយោជន៍ទៅឲ្យគ្នាទៅវិញទៅមករវាងរដ្ឋ ក៏មានចង់បាននិងព្រួយបារម្ភរួមដែលខ្ពស់ហួសពីសមត្ថភាពឈោងចាប់របស់រដ្ឋនីមួយៗ ហើយបង្រួបបង្រួមមនុស្សជាតិទាំងមូល ។ ជាក់ស្តែង តម្រូវការឲ្យទទួលស្គាល់ការចង់បាននិងការព្រួយបារម្ភទាំងអស់នេះ បានធ្វើឲ្យលេចឡើងនូវទស្សនៈនៃកាតព្វកិច្ចសហគមន៍និងសិទ្ធិសហគមន៍ ។ ទាំងនេះជាកាតព្វកិច្ច (ឧទាហរណ៍ មិនវាយប្រហារទៅលើរដ្ឋផ្សេង មិនជាន់ឈ្លីទៅលើសិទ្ធិជាមូលដ្ឋាននៃបុគ្គលមិនជិះជាន់ប្រជាជន) ដែលរដ្ឋនីមួយៗមានចំពោះគ្នាទៅវិញទៅមក ។ ដោយមូលហេតុដូចគ្នារដ្ឋនីមួយៗត្រូវបានផ្តល់ឲ្យនូវសិទ្ធិទាមទារថារដ្ឋទាំងអស់ផ្សេងទៀតគោរពកាតព្វកិច្ចទាំងនេះ និងតម្លៃជាមូលដ្ឋានដែលរដ្ឋទាំងនេះមានបំណងការពារ ទោះជាបុព្វហេតុផ្ទាល់ខ្លួននៃជាតិនីមួយៗមានទម្រង់បែបណាក៏ដោយ ។

ការលេចមុខឡើងនៅក្នុងសហគមន៍អន្តរជាតិនូវតម្លៃជាមូលដ្ឋានមួយសំណុំដែលរដ្ឋណាមួយឬនរណាម្នាក់មិនគោរពតាមបានធ្វើឲ្យកើតឡើងនៅក្នុងកម្រិតអន្តរជាតិនូវបាតុភូតមួយដែលមានភាពសាមញ្ញចំពោះរាល់ប្រព័ន្ធច្បាប់ជាតិតាំងពីមុនប្រវត្តិ-សាស្ត្រ នោះគឺឋានានុក្រមនៃបទដ្ឋានច្បាប់ ដែលតាមរយៈច្បាប់ទូទៅខ្លះ (ដែលត្រូវគេស្គាល់ថាជាបទដ្ឋានដាច់អហង្ការ) មានសារសំខាន់ធំធេងរហូតដល់រដ្ឋទាំងឡាយមិនត្រូវបានអនុញ្ញាតឲ្យងាកចេញពីច្បាប់ទាំងនេះនៅក្នុងការពិភាក្សាក្នុងកម្រិតផ្ទាល់ខ្លួន ។

តាមរយៈទម្រង់ការថ្មីនេះ ការចាប់អារម្មណ៍ជាសាធារណៈកំពុងតែលេចរូបរាងបន្តិចម្តងៗ ហើយតែងតែមានអាទិភាពទៅលើការចាប់អារម្មណ៍ឯកជន ។ សញ្ញាណបែបនេះក៏ធ្វើឲ្យពហុភាគីនិយមមានអត្ថិភាព ។ រដ្ឋលែងមានសេរីភាព ដែលគ្មានដែនកំណត់ក្នុងការសម្រេចទំនាក់ទំនងរបស់ខ្លួនតទៅទៀតហើយ ។ ពេលនេះបទដ្ឋានដាច់អហង្ការបានក្លាយទៅជាឧបសគ្គដ៏ធំមួយចំពោះសេរីភាពនោះ ។ ជាពិសេសជាងនេះទៅទៀត រដ្ឋមិនត្រូវបានអនុញ្ញាតឲ្យធ្វើការសម្រេចចិត្តជាឯកតោភាគីតទៅទៀតអំពីការឆ្លើយតបទៅនឹងការរំលោភទៅលើបទដ្ឋានច្បាប់ដោយរដ្ឋផ្សេងៗ ។ លើសពីនេះ រដ្ឋមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំ (ឧទាហរណ៍ ការឆ្លើយតបដោយកម្លាំងទ័ព) សម្រាប់ការបង្ខំឲ្យគោរពតាមបទដ្ឋានច្បាប់ទាំងនោះ ។

## ការរួមរស់ជាមួយគ្នាមិនសុខស្រួល

ទម្រង់"កាន់ធៀន"ថ្មីកាន់តែមានឥទ្ធិពលបន្តិចម្តងៗ ប៉ុន្តែវាមិនទាន់ក្លាយខ្លួនជាប្រព័ន្ធពេញលេញនិងទៀងទាត់នៃទំនាក់ទំនងអន្តរជាតិនៅឡើយទេ ។ ទស្សនៈចាស់នៅតែប្រឆាំងនិងបន្តឲ្យមានការលំបាកដល់គំនិតថ្មីទាំងនេះ ។ ភាពស៊ិតស្វាញនៃស្ថាប័នច្បាប់ចាស់ ព្រមទាំងមនោគមវិជ្ជានិងទស្សនវិស័យគាំទ្រពីក្រោយស្ថាប័នទាំងនេះ រួមផ្សំជាមួយភាពទន់ខ្សោយនៃទម្រង់ការថ្មីមានន័យថាប្រព័ន្ធថ្មីទាំងពីរដែលខ្ញុំបានរៀបរាប់ ធ្វើដំណើរទៅមុខជាមួយគ្នាមិនរលូន ។ ពិសេសយន្តការកណ្តាលនៃការធ្វើច្បាប់ឬការដាក់ឲ្យគោរពច្បាប់គឺនៅតែខ្វះខាតដដែល ។

ពិតណាស់ មានវេទិកាពហុភាគីជាច្រើនដែលរដ្ឋទាំងឡាយអាចពិភាក្សាជាសាធារណៈ និងព្យាយាមសម្របសម្រួលវត្ថុបំណងរបស់ខ្លួន ។ ប៉ុន្តែវេទិកាទាំងនេះនៅខ្វះលក្ខណៈសម្បត្តិជាច្រើន ក្នុងការធ្វើជាស្ថាប័នមជ្ឈិមសម្រាប់សហគមន៍អន្តរជាតិ ។ ការព្យាយាមដើម្បីប្រគល់ដល់អង្គភាពមជ្ឈិមមួយ គឺក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនូវភារកិច្ចក្នុងការធានាឲ្យបាននូវការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ តាមរយៈការប្រើប្រាស់កម្លាំងទ័ពក្នុងករណីចាំបាច់ គឺគ្រាន់តែជាជោគជ័យមួយផ្នែកប៉ុណ្ណោះ ។ លើសពីនេះ សេចក្តីប្រកាសអំពីសិទ្ធិមនុស្សមិនទាន់ត្រូវបានធ្វើឲ្យសមស្របតាមការបង្កើតស្ថាប័នជាសកលណាមួយដែលមានលទ្ធភាពធានាថា រដ្ឋទាំងឡាយឆ្លើយតបទៅនឹងបទដ្ឋានដែលត្រូវបានដាក់ឲ្យរដ្ឋទាំងនោះសង្កេតមើលនោះទេ ។

យន្តការបែបនោះកើតមានតែនៅក្នុងថ្នាក់តំបន់ប៉ុណ្ណោះ (នៅទ្វីបអឺរ៉ុបនិងអាមេរិកឡាទីន) ហើយនៅតែត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយប្រព័ន្ធច្បាប់ជាតិដដែល ។ ជាក់ស្តែង ការសម្រេចចិត្តរបស់"តុលាការសិទ្ធិមនុស្សអឺរ៉ុប" និង "តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង" អាចត្រូវបានធ្វើឲ្យដំណើរការដោយបុគ្គលទាំងឡាយនិងដាក់ឲ្យរដ្ឋគោរពតាម ។ ទោះជាយ៉ាងណា តុលាការទាំងពីរនេះមិនបង្កឲ្យមានឥទ្ធិពលផ្នែកច្បាប់ដោយផ្ទាល់និងភ្លាមៗនៅក្នុងក្របខ័ណ្ឌប្រព័ន្ធច្បាប់ជាតិនៃរដ្ឋពាក់ព័ន្ធទេ ។

សេចក្តីសម្រេចអន្តរជាតិ ទោះជាអាចមិនត្រូវបានធ្វើឡើងឬបង្កឲ្យកើតមានដោយបុគ្គល មិនបានទៅដល់បុគ្គលដោយផ្ទាល់ទេ តែនៅទើរត្រឹមកម្រិតរដ្ឋ?

នៅក្នុងប្រធានបទផ្សេងក្រៅពីសិទ្ធិមនុស្ស សិទ្ធិសហគមន៍ត្រូវបានប្រកាស ប៉ុន្តែគ្មានយន្តការអន្តរជាតិណាមួយត្រូវបានបង្កើតឡើងសម្រាប់ការយកសិទ្ធិសហគមន៍ទៅអនុវត្តនៅឡើយទេ (សូមពិចារណាអំពីការការពារជាអន្តរជាតិទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានសុពលភាពនៅក្នុងពេលមានជម្លោះ) ។ ការបកស្រាយអំពីសិទ្ធិទាំងនេះត្រូវបានប្រគល់ឲ្យរដ្ឋនីមួយៗ ជាអ្នកធ្វើដែលត្រូវសង្ឃឹមថាទទួលការលើកទឹកចិត្តពីការចាប់អារម្មណ៍របស់សហគមន៍តែជាជោគអាក្រក់នៅតែកំណត់ដោយការចាប់អារម្មណ៍ផ្ទាល់ខ្លួន ហើយហេតុនេះមិនមានឆន្ទៈក្នុងការធ្វើសកម្មភាពផ្អែកទៅលើតម្លៃជាសកលទេ ។

ច្បាស់ណាស់ថា ឧបករណ៍ច្បាប់មានពីមុនមក ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងការពាររដ្ឋអធិបតេយ្យពីការស៊ើបអង្កេតខាងក្រៅ នៅតែមានឥទ្ធិពលទោះបីជាដែនកំណត់នៃវិសាលភាពនៃឧបករណ៍ទាំងនេះកំពុងតែលេចឡើងក៏ដោយ ។ ត្រង់ចំណុចនេះ ខ្ញុំចង់សំដៅទៅលើទស្សនៈនៃការមិនឋិតនៅក្នុងយុត្តាធិការតុលាការបរទេសនៃរដ្ឋនិងសំដៅទៅលើទស្សនៈដែលថាភ្នាក់ងាររដ្ឋ ដែលដើរតួទៅតាមកាតព្វកិច្ចជាផ្លូវការអាចមិនត្រូវបានដាក់ឲ្យទទួលខុសត្រូវជាបុគ្គលនៅលើវេទិកាបរទេសឬអន្តរជាតិ សម្រាប់ការរំលោភទៅលើច្បាប់អន្តរជាតិដែលរដ្ឋនីមួយៗអាចប្រព្រឹត្តឡើង ។

ហេតុនេះសហគមន៍អន្តរជាតិក៏ឋិតនៅក្នុងអន្តរកាលមួយដែលទស្សនៈថ្មីប្រកួតប្រជែងជាមួយទស្សនៈចាស់ដែលចាក់ឫសគល់យ៉ាងរឹងមាំ ។ នៅក្នុងបរិបទនេះហើយដែលរដ្ឋនិងបុគ្គលត្រូវតែវាយតម្លៃអំពីសារប្រយោជន៍ និងសក្តានុពលភាពដ៏ធំធេងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

## ផ្តល់ដល់បុគ្គលនូវតួនាទីដ៏សមស្រប

ឧក្រិដ្ឋកម្មអន្តរជាតិតែងតែត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលដែលភាគច្រើនមានឋានៈជាភ្នាក់ងារនៃរដ្ឋមួយ ដូចជាមេទ័ព អ្នកបម្រើការងារក្នុងកងទ័ព មន្ត្រីប៉ូលិស រដ្ឋមន្ត្រី និងរដ្ឋាភិបាលជាដើម ។ គ្មានយន្តការជំរុញឲ្យគោរពច្បាប់ថ្នាក់មជ្ឈិមមួយនៅក្នុងសហគមន៍ពិភពលោក ហើយដោយហេតុផលថាយ៉ាងហោចណាស់ការរំលោភយ៉ាងច្បាស់ក្រឡែតបំផុតទៅលើច្បាប់អន្តរជាតិត្រូវតែដាក់ទណ្ឌកម្មតុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានកោះហៅឲ្យធានាថា សហគមន៍អន្តរជាតិទាំងមូលឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មទាំងនោះយ៉ាងមានប្រសិទ្ធភាព ។ តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានផ្តល់អំណាចឲ្យឆ្លើយតបមិនមែនតាមរយៈការវាយប្រហារទៅលើរដ្ឋទេ តែតាមរយៈការដោះស្រាយជាមួយបុគ្គលដែលជាប់ពាក់ព័ន្ធ គឺថាតុលាការនេះនាំខ្លួនជនដែលត្រូវបានចោទប្រកាន់ថារំលោភច្បាប់ឡើងតុលាការ ។ ហេតុនេះ តម្លៃជាអន្តរជាតិដ៏សំខាន់បំផុតមួយចំនួន (ដូចជាការគោរពចំពោះសិទ្ធិមនុស្ស) គឺត្រូវបានទ្រទ្រង់យ៉ាងមានប្រសិទ្ធភាព ហើយដោយសារមូលហេតុដូចគ្នាសិទ្ធិសហគមន៍ត្រូវបានលើកតម្កើង ។

តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងដើម្បីផ្តល់តម្លៃទៅឲ្យនិងធ្វើឲ្យមានសុពលភាពនូវបទដ្ឋានដាច់អហង្ការនៃច្បាប់អន្តរជាតិដែលការពារតម្លៃជាមូលដ្ឋានទាំងឡាយ ដូចជាសេចក្តីថ្លៃថ្នូរនៃមនុស្ស ការគោរពចំពោះអាយុជីវិតនៃជនគ្មានកំហុស និងការការពារក្រុមជាតិពន្ធ សាសនា និងជនជាតិ ។ លើសពីនេះ បុគ្គលមានតួនាទីចម្បងដែលស័ក្តិសម គឺបុគ្គលនោះហើយជាជនល្មើស ជនរងគ្រោះ ឬជាសាក្សី ។ ហេតុនេះ ជនរងគ្រោះនិងជនដែលដល់ត្រូវបានសហគមន៍អន្តរជាតិដឹងឮ ។

និយាយឲ្យខ្លី តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានធ្វើឡើងដើម្បីជំរុញ និងនាំឲ្យមានផ្លែផ្កានូវគំរូ«កាន់ធៀន»ថ្មីនៃសហគមន៍អន្តរជាតិ ។ វាដើរតួជាអ្នកអនុវត្តជាក់ស្តែង និងជានិមិត្តរូបនៃទម្រង់ការនោះ និងជាកម្លាំងចលករដ៏ធំធ្វើឲ្យទម្រង់ការនេះក្លាយទៅជាការពិត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានធ្វើឡើងដើម្បីគាំទ្រគំនិតដែលថាការប្រើប្រាស់កម្លាំងទ័ពត្រូវតែកាត់បន្ថយឲ្យបានច្រើនដូចដែលអាចធ្វើទៅបានទាំងនៅក្នុងទំនាក់ទំនងអន្តរជាតិនិងទំនាក់ទំនងជាតិ ។ ហេតុនេះនៅពេលណាដែលបុគ្គលម្នាក់ប្រើប្រាស់អំពើហិង្សា ដែលផ្ទុយទៅនឹងបទដ្ឋានច្បាប់ជាមូលដ្ឋាននៃសហគមន៍ពិភពលោក ជននោះត្រូវតែដាក់ឲ្យទទួលខុសត្រូវ ។

ពីមុន សហគមន៍អន្តរជាតិប្រកាន់ជាមូលដ្ឋាននូវគំនិតនៃការបំពេញជាឯកតោភាគីនូវបុព្វហេតុដោយរដ្ឋនីមួយៗ ឯតុលាការព្រហ្មទណ្ឌអន្តរជាតិមានបំណងជាស់តឿន គាំទ្រ និងជំរុញដល់គោលបំណងជាសាធារណៈនិងជារួមនៃការទប់ស្កាត់ការរំលោភបទដ្ឋាននៃការប្រព្រឹត្តដែលត្រូវបានទទួលស្គាល់ជាទូទៅ ។

គួរកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានការជឿនលឿនជាងតុលាការសិទ្ធិមនុស្សអឺរ៉ុបនិងអន្តរអាមេរិកាំងដែលបានរៀបរាប់ខាងលើ ។ ខុសពីតុលាការទាំងពីរដែលមានលក្ខណៈជាតំបន់ តុលាការព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈជាសកល (ឬយ៉ាងហោចណាស់មានលទ្ធភាពអាចក្លាយជាតុលាការថ្នាក់សកល) ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ បង្ហាញអំពីអត្តចរិតរដ្ឋ ។ ដោយមូលហេតុនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិលាតសន្ធឹងទៅដល់បុគ្គល ទោះជាជនដៃដល់ ជនរងគ្រោះ ឬជាសាក្សីក្តី ។ ម្យ៉ាងវិញទៀត លក្ខន្តិកៈច្បាប់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានចាត់ចេញនូវរាល់អភ័យឯកសិទ្ធិជាប្រពៃណីទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ (ដោយមូលហេតុផ្ទាល់ខ្លួននិងមូលហេតុការងារ) ដែលធ្វើឡើងក្នុងបំណងការពារមន្ត្រីជួរការរបស់រដ្ឋពីការស៊ើបអង្កេតនិងកាត់ទោសពីខាងក្រៅ ។ ឥឡូវនេះ មន្ត្រីជួរការទាំងនេះត្រូវដាក់នៅក្រោមការត្រួតពិនិត្យពីអន្តរជាតិយ៉ាងចំហ ដែលកើតឡើងនៅលើតុលាការច្បាប់ជាអន្តរជាតិមួយ ។

ការលុបបំបាត់នូវអភ័យឯកសិទ្ធិនិងសញ្ញាណនៃ “ការទទួលខុសត្រូវរបស់មេបញ្ជាការ” (ដែលក្នុងនោះអាជ្ញាធរយោធាឬយោធាស៊ីវិលកំពូលនៃរដ្ឋមួយអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវតាមបែបព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងដោយមនុស្សក្រោមបង្គាប់ ប្រសិនបើមេបញ្ជាការមិនបានការពារឬទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនោះ) ជាតឹកតាងបញ្ជាក់ពីទីបញ្ចប់នៃវប្បធម៌នៃភាពរួចទោស ។ ជាការពិត ដោយសារជំហានដ៏ថ្មីនិងសំខាន់នេះហើយដែលបន្ទាចរដ្ឋជាច្រើនមិនឲ្យផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

## តុល្យភាពរវាងជាតិនិងសកលលោក

ចំណុចពិសេសនិងគួរចាប់អារម្មណ៍មួយទៀតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺថា តុលាការនេះត្រូវបានបង្កើតឡើងជាឧបករណ៍សម្រាប់សម្របសម្រួលដល់យុត្តិធម៌ព្រហ្មទណ្ឌជាតិនិងអន្តរជាតិ (នេះជាលើកទីមួយហើយដែលតុលាការព្រហ្មទណ្ឌអន្តរជាតិមួយត្រូវបានធ្វើឡើងបែបនេះ ទោះបីជាតុលាការសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ជា“សាខា”នៃតុលាការជាតិដូចគ្នា) ។ ការកាត់ទោសនិងការដាក់ទណ្ឌកម្មទៅលើបទល្មើសធ្ងន់ធ្ងរប្រឆាំងនឹងភាពថ្លៃថ្នូរនៃមនុស្សនៅតែជាកាតព្វកិច្ចរបស់រដ្ឋ ។ តំបន់និងជាតិនៅតែជាទស្សនៈជាមូលដ្ឋាននៅក្នុងសហគមន៍អន្តរជាតិ ទោះបីជាទស្សនៈទាំងនេះគាំទ្រដល់គំនិតចាស់ៗក៏ដោយៈ ចំណងនៃឈាមនិងតំបន់ ។

ទោះជាយ៉ាងណា ការបង្កើតឡើងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ជាក់ថា នៅពេលដែលយន្តការតំបន់និងជាតិបរាជ័យក្នុងការការពារយុត្តិធម៌ សហគមន៍អន្តរជាតិទាំងមូល ត្រូវតែចាត់វិធានការតាមរយៈអង្គតុលាការមជ្ឈិមមួយ គឺតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តុលាការនេះមិនមែនជាបណ្តូលនៃតុលាការជាតិដ៏សកម្មនិងមានប្រសិទ្ធភាពនោះទេ ។ ផ្ទុយទៅវិញ តុលាការនេះបង្កើតឡើងក្នុងគោលបំណងបង្កជាការជាស់តឿនដ៏មានឥទ្ធិពលដល់តុលាការជាតិឲ្យបង្កើតនីតិវិធីច្បាប់ប្រឆាំងនឹងឧក្រិដ្ឋជនជាប់ចោទ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិលូកដៃចូលតែក្នុងពេលណាដែលតុលាការជាតិទាំងនោះមិនមានឆន្ទៈឬខ្វះសមត្ថភាពចាត់វិធានការ ។

តាមមធ្យោបាយនេះ ការកើតឡើងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិជាជំហានដ៏ធំមួយឆ្ពោះទៅមុខ ក្នុងការធ្វើឲ្យក្លាយជាការពិតនូវទស្សនៈវិស័យថ្មីនៃសហគមន៍ពិភពលោក ។ វាបង្ហាញថា បុព្វហេតុសេដ្ឋកិច្ចជាតិនិយម និងការរៀបចំផែនការជាឯកតោភាគី ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬការបកស្រាយនិងការជំរុញឲ្យអនុវត្តតាមបទដ្ឋានអន្តរជាតិដោយខ្លួនឯង លែងជាចំណុចសំខាន់នៃការពិភាក្សាជាអន្តរជាតិនៅក្នុងសហគមន៍ពិភពលោកទៀតហើយ ។ នៅពេលដែលចំណុចទាំងនេះនៅតែមានលក្ខណៈពិសេស តួនាទីនៃតម្លៃជាសកលនិងតម្រូវការជំរុញឲ្យមានការគោរពតម្លៃទាំងនោះតាមរយៈតួអង្គមជ្ឈិមមួយដែលមានលទ្ធភាពធានាយុត្តិធម៌ក្នុងតួនាទីជាសហគមន៍ទាំងមូលក៏មាន

សារសំខាន់ដូចគ្នាដែរ ។

**មធ្យោបាយល្អបំផុតដើម្បីប្រយុទ្ធនឹងអំពើឃោរឃៅ**

ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមិនលុបបំបាត់ចោលឧក្រិដ្ឋកម្មអន្តរជាតិទាំងស្រុងនោះទេ ។ សហគមន៍ពិភពលោកនឹងមិនក្លាយទៅជាទីសុខសាន្តដោយសារក្រឹត្យតុលាការនោះទេ ដោយមូលហេតុនេះទស្សនៈដែលគាំទ្រដល់អធិបតេយ្យភាពនៅតែមានឥទ្ធិពលដូចដែលបានរៀបរាប់ខាងលើ ។ មូលហេតុមួយទៀត ស្ថាប័នអន្តរជាតិថ្មីនេះនឹងត្រូវការការគាំទ្រនិងសហការពីស្ថាប័នផ្សេងទៀត ពិសេសគឺរដ្ឋដែលតុលាការនេះត្រូវបានបង្កើតឡើងដើម្បីជំនួស ។

តួនាទីតែមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាការគ្រប់គ្រាន់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដ៏រន្ធត់ នៅពេលណាដែលអាជ្ញាធររដ្ឋពាក់ព័ន្ធ "មិនមានឆន្ទៈឬមិនមានលទ្ធភាព" កាត់សេចក្តីបទឧក្រិដ្ឋទាំងនោះ ។ មុនពេលប្រកាសអំពីរឿងក្តីមួយ តុលាការព្រហ្មទណ្ឌត្រូវតែបញ្ជាក់ថា រដ្ឋនោះអាចដោះស្រាយបញ្ហាបានតែមិនខំប្រឹងស្វែងរកយុត្តិធម៌ ឬមិនអាចដោះស្រាយយុត្តិធម៌បានទាំងស្រុង ។ តុលាការព្រហ្មទណ្ឌអន្តរជាតិដំបូងត្រូវអនុម័តសេចក្តីវិនិច្ឆ័យអវិជ្ជមានមួយអំពីរដ្ឋនោះ ។ ទោះជាយ៉ាងណានៅពេលដែលតុលាការព្រហ្មទណ្ឌបានដាក់ផ្លាកអវិជ្ជមានទៅលើរដ្ឋនោះហើយ តើរដ្ឋនោះនឹងអាចរៀបចំខ្លួនបានប៉ុនណាដើម្បីសហការជាមួយតុលាការព្រហ្មទណ្ឌតាមរយៈការផ្តល់ភ័ស្តុតាង ការអនុវត្តការចុះឆែកឆេរឬរឹបអូសនិងការចាប់ខ្លួនជនជាប់ចោទ? នេះគឺគ្រាន់តែជាឧបសគ្គមួយក្នុងចំណោមឧបសគ្គជាច្រើនដែលតុលាការព្រហ្មទណ្ឌត្រូវដោះស្រាយ ហើយជាអ្វីដែលតុលាការនេះមិនអាចចៀសវាងបាន ។

នៅក្នុងសហគមន៍ពិភពលោកដែលនៅតែបែកខ្ញែក វាសមហេតុផលក្នុងការផ្តល់ដំបូងបំផុតទៅកាន់តុលាការជាតិរបស់រដ្ឋនូវអំណាច (និងករណីយកិច្ច) នាំខ្លួនឡើងតុលាការនិងដាក់ទណ្ឌកម្មជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវចំពោះការរំលោភបំពានទៅលើតម្លៃដែលគេទទួលស្គាល់ជាអន្តរជាតិ ។ ក្នុងការអនុវត្តតួនាទីនេះ តុលាការជាតិគួរតែដើរតួជា "អង្គមួយនៃសហគមន៍ពិភពលោក" ។ មានន័យថាតុលាការជាតិគួរតែប្រតិបត្តិមិនមែនដោយអំណាចផ្ទាល់ខ្លួនទេ តែក្នុងនាមជាសហគមន៍អន្តរជាតិទាំងមូល ។ ប្រាកដណាស់ ការប្រើប្រាស់តុលាការជាតិមិនមែនមានន័យថា គ្មានចំណុចខ្សោយទាំងស្រុងនោះទេប្រសិនបើតុលាការក្នុងស្រុកមានទំនោរការពារភ្នាក់ងាររដ្ឋដែលមានការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ដូចគ្នាដែរ មធ្យោបាយដែលមានស្រាប់ផ្សេងទៀត ក្នុងការឆ្លើយតបទៅនឹងអំពើឃោរឃៅនិងការរំលោភបំពានទៅលើសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចជាគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សាតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសឬចម្រុះ ឬតុលាការដែលបានប្រែឲ្យទៅជាមានលក្ខណៈអន្តរជាតិ ក៏មិនទាន់អាចផ្តល់ចម្លើយឲ្យបានច្បាស់លាស់មួយចំពោះបញ្ហាដ៏ច្រើនសន្ធឹកសន្ធាប់នៃយុត្តិធម៌អន្តរជាតិដែរ ។ ការពិតគឺថាគ្មានស្ថាប័នណាមួយដែលល្អឥតខ្ចោះនោះទេ ។

ប្រហែលជាការឆ្លើយតបប្រសើរបំផុតទៅនឹងអំពើឃោរឃៅឋិតនៅលើការរួមបញ្ចូលគ្នាដ៏ប្រុងប្រយ័ត្ននិងគិតគូរច្បាស់លាស់នៃមធ្យោបាយផ្សេងៗ ដែលត្រូវមើលឃើញថាមិនត្រឹមតែជាជម្រើស តែជាការឆ្លើយតបរួមគ្នាទៅកាន់ការឈឺចាប់វេទនាដែលយើងទាំងអស់គ្នាត្រូវដឹងឮជារៀងរាល់ថ្ងៃ ជាមួយនឹងអារម្មណ៍ឈឺចាប់ចំពោះភាពអយុត្តិធម៌ ។ យើងមិនត្រូវភ្លេចថាច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាមែកធាងមួយនៃច្បាប់ ដែលលើសពីច្បាប់ផ្សេង រៀបរាប់អំពីភាពឆ្កួតលេលារបស់មនុស្ស ភាពកំណាចរបស់មនុស្ស និងភាពឃោរឃៅរបស់មនុស្ស ។ ច្បាប់នេះចែងអំពីផ្នែកដ៏ខ្មៅងងឹតបំផុតនៃសារជាតិរបស់យើង ។ ច្បាប់នេះអាចរៀបរាប់ដែរ អំពីរបៀបដែលសង្គមរៀបចំខ្លួនដើម្បីបង្កឲ្យមានអំពើហិង្សានិងភាពកាចសាហាវឲ្យមានកម្រិតខ្ពស់បំផុត ។ ច្បាស់ណាស់ បើគិតអំពីទំហំនៃការងារនេះ គ្មានការឆ្លើយតបតែមួយមុខគត់ ណាមួយគ្រប់គ្រាន់នោះទេ ។ ជាជំនួសការឆ្លើយតបតាមវិធីច្រើនយ៉ាងដែលនីមួយៗ ធ្វើឡើងសម្រាប់ការលះទេសៈជាក់លាក់មួយជាការចាំបាច់ដើម្បីប្រយុទ្ធទល់នឹងអំពើឧក្រិដ្ឋកម្មអន្តរជាតិ ។

**អាន់តូនីញ៉ូ ខាសសេ**

# តុលាការព្រហ្មទណ្ឌអន្តរជាតិ

តុលាការព្រហ្មទណ្ឌអន្តរជាតិបានចាប់កំណើតឡើងនៅ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ។ អ្នកគាំទ្រតុលាការនេះយល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិជានិមិត្តរូបនៃការវិវិត្តន៍ជាប្រវត្តិសាស្ត្រនៃយុត្តិធម៌សកលលោក ។ អ្នកប្រឆាំងនឹងការបង្កើតតុលាការនេះបានបកស្រាយដោយសម្តីមួយបែបផ្សេងទៀត ។ រដ្ឋាភិបាលរបស់ប្រធានាធិបតី ប៊ូស ព្រួយបារម្ភថា តុលាការព្រហ្មទណ្ឌអាចធ្វើឲ្យមានការកាត់ទោសបម្រើផលប្រយោជន៍នយោបាយទៅលើប្រជាពលពលរដ្ឋអាមេរិក ។ រដ្ឋាភិបាលនេះបានបង្កើតយុទ្ធនាការទូទាំងពិភពលោកដើម្បីបង្កើតកិច្ចព្រមព្រៀងស្តីពីអភ័យឯកសិទ្ធិប្រទេសផ្សេងទៀត (ធ្វើឲ្យប្រទេសទាំងនេះឋិតនៅក្រៅសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ) ហើយដកហូតជំនួយយោធាពីប្រទេសណាដែលបដិសេធ ។ នៅក្នុងអនាគតកាលដ៏ខ្លីខាងមុខ ឥទ្ធិពលរបស់តុលាការព្រហ្មទណ្ឌអាចមានកម្រិតតិចជាងការប៉ាន់ស្មានរបស់អ្នកជ្រោមជ្រែងនិងអ្នករិះគន់ ។ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិជាទស្សនីយភាពប្លែកនៃព្រឹត្តិការណ៍មួយដែលមានអត្ថន័យជានិមិត្តរូបដ៏ធំធេង ។ ប៉ុន្តែឥទ្ធិពលជាក់ស្តែងរបស់តុលាការព្រហ្មទណ្ឌទំនងជាមានកម្រិតមធ្យម យ៉ាងហោចណាស់សម្រាប់អនាគតដ៏ខ្លីខាងមុខ ។

គំនិតនៃការចង់បង្កើតតុលាការអចិន្ត្រៃយ៍មួយដែលអាចដាក់បុគ្គលទាំងឡាយឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអន្តរជាតិដ៏ឃោរឃៅបំផុតត្រូវបានលើកយកទៅពិភាក្សាអស់រយៈពេលជាយូរមកហើយ ។ គំនិតបែបនេះត្រូវបានស្នើឡើងជាលើកដំបូងនៅចុងសតវត្សរ៍ទី១៩ ក្នុងពេលដំណាលគ្នានឹងការសរសេរច្បាប់សង្គ្រាមសម័យទំនើបដំបូងបំផុត ។ គំនិតដដែលនេះត្រូវបានពិនិត្យឡើងវិញ នៅក្រោយសង្គ្រាមលោកលើកទីពីរ ប៉ុន្តែក៏ស្ងប់ស្ងាត់ទៅវិញដោយសារសង្គ្រាមត្រជាក់ ។ ក្រោយមកនៅទសវត្សរ៍ឆ្នាំ១៩៩០ គំនិតនេះត្រូវបានពិភាក្សាឡើងវិញដោយមានការផ្តើមគំនិតពីប្រទេសទ្រីនីដាតនិងតូបាហ្គោដែលយល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិអាចត្រូវបានប្រើប្រាស់ដើម្បីកាត់ទោសជនរត់ពន្ធគ្រឿងញៀន ។ ផ្ទុយទៅវិញ ការទទួលឥទ្ធិពលពីបទពិសោធន៍ផ្នែកច្បាប់នៃតុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា វាបានវិវត្តន៍ទៅជាវិទ្យាស្ថានមួយដែលមានវត្តមានក្នុងពេលបច្ចុប្បន្ន នោះគឺជាតុលាការមួយដែលមានយុត្តាធិការលើបទឧក្រិដ្ឋសង្គ្រាម បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងក្នុងគោលបំណងរារាំងឬដាក់ទណ្ឌកម្មដល់ឧក្រិដ្ឋកម្មទាំងឡាយដែលនឹងកើតឡើងក្នុងពេលអនាគត ។ តុលាការមិនអាចកាត់ទោសមនុស្សពីបទឧក្រិដ្ឋទាំងឡាយដែលបានធ្វើឡើងមុនពេលដែលតុលាការត្រូវបានបង្កើតនោះទេ ។ ប៉ុន្តែសមត្ថភាពរបស់តុលាការក្នុងការដាក់ឲ្យមនុស្សទទួលខុសត្រូវចំពោះបទឧក្រិដ្ឋមានទំហំត្រឹមតែអ្វីដែលមានចែងនៅក្នុងយុត្តាធិការរបស់តុលាការប៉ុណ្ណោះ ហើយចំណុចនេះមានកម្រិតកំណត់សំខាន់មួយ ។ ជាទូទៅត្រូវបានទទួលស្គាល់តាំងពីដំណាក់កាលដំបូងថា តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងជាអង្គភាពមួយដែលផ្អែកលើសន្ធិសញ្ញា មានន័យថារដ្ឋទាំងឡាយត្រូវក្លាយទៅជាភាគីរដ្ឋនៃតុលាការតាមរយៈការផ្តល់សច្ចានុម័តទៅឲ្យលក្ខន្តិកៈច្បាប់របស់តុលាការ (លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម) ។ ប្រទេសទាំងឡាយដែលមិនបានចុះឈ្មោះជាសមាជិករបស់តុលាការ មិនមានកាតព្វកិច្ចសហការជាមួយតុលាការទេ ហើយឧក្រិដ្ឋកម្មភាគច្រើនដែលកើតឡើងនៅក្នុងប្រទេសទាំងនេះនឹងឋិតនៅក្រៅអំណាចរបស់តុលាការ ។ មកទល់នឹងខែវិច្ឆិកា ឆ្នាំ២០០៣ ប្រទេសចំនួន៩២បានក្លាយទៅជាសមាជិករបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រទេសដែលមិនមែនជាសមាជិកមាន អាល់ហ្សេរី ប៊ូរុនឌី ចិន អេហ្ស៊ីប ឥណ្ឌា អ៊ីរ៉ង់ អ៊ីរ៉ាក់ អ៊ីស្រាអែល លីបេរី លីបប្យា កូរ៉េខាងជើង ប៉ាគីស្ថាន

រុស្ស៊ី រ៉្វាន់ដា ស៊ូដង់ ស៊ីរី សហរដ្ឋអាមេរិក អ៊ូបេគីស្ថាន និង ហ្ស៊ីមបាវេ ។ ច្បាស់ណាស់ ពិភពលោកនៅមានផ្លូវដ៏វែងឆ្ងាយមុខ ដែលត្រូវដើរមុននឹងទៅដល់ការបង្កើតតុលាការសកលលោក មួយដែលអាចកាត់សេចក្តីទៅលើរាល់អំពើឃោរឃៅនៅក្នុងពិភព លោក ។

## ដែនកំណត់ទៅលើអធិបតេយ្យភាព

ទោះបីជាយ៉ាងណា តុលាការព្រហ្មទណ្ឌអន្តរជាតិមាន អំណាចជាច្រើនដែលមានកម្រិតធំជាងអ្វីដែលរដ្ឋខ្វល់ពីអធិបតេយ្យ ភាពភាគច្រើនសង្ឃឹមថាអាចដាក់កម្រិតទៅលើអំណាចរបស់ តុលាការ ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ច មិនត្រឹមតែទៅលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយប្រជា-ជនមកពីរដ្ឋដែលជាសមាជិកនៃតុលាការទេ ប៉ុន្តែថែមទាំងមាន សមត្ថកិច្ចទៅលើបទឧក្រិដ្ឋទាំងឡាយណាដែលបានប្រព្រឹត្តឡើង នៅលើទឹកដីសមាជិករបស់តុលាការ ។ តាមមធ្យោបាយនេះ ពលរដ្ឋនៃប្រទេសដែលមិនបានចូលរួមក្នុងតុលាការអាចត្រូវនាំ ខ្លួនយកទៅកាត់ទោសនៅចំពោះមុខតុលាការបានដែរ ប្រសិនបើ ពលរដ្ឋទាំងនេះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាមនៅក្នុង ប្រទេសមួយដែលជាសមាជិកនៃតុលាការ ។ ហេតុនេះ ទោះបីជា សហរដ្ឋអាមេរិកមិនបានផ្តល់សច្ចានុម័តទៅឲ្យលក្ខន្តិកៈទីក្រុងរ៉ូម ក៏ដោយ ក៏ពលរដ្ឋអាមេរិកាំងអាចត្រូវបានចោទប្រកាន់ពីបទ ឧក្រិដ្ឋទាំងឡាយណាដែលពលរដ្ឋទាំងនេះប្រព្រឹត្តនៅក្នុងប្រទេស អាហ្វហ្គានីស្ថាន ឬ ប៉ូស្នៀ ។

អំណាចដាក់លាក់មួយទៀតដែលតុលាការទទួលបាននៅ ក្នុងដំណើរការចរចា (មិនបានរៀបរាប់នៅក្នុងសេចក្តីព្រាងទីមួយ នៃលក្ខន្តិកៈ រៀបចំដោយគណៈកម្មការច្បាប់អន្តរជាតិរបស់ អង្គការសហប្រជាជាតិ) គឺព្រះរាជអាជ្ញាត្រូវបានផ្តល់ឲ្យនូវសិទ្ធិ បើកការស៊ើបអង្កេតរឿងក្តីទាំងឡាយដែលស្ថិតនៅក្រោមអំណាច របស់ខ្លួន ។ រដ្ឋដែលជាសមាជិករបស់តុលាការឬក្រុមប្រឹក្សា សន្តិសុខអង្គការសហប្រជាជាតិ អាចប្តឹងទៅតុលាការព្រហ្មទណ្ឌ អន្តរជាតិ ប៉ុន្តែការផ្តល់ឲ្យព្រះរាជអាជ្ញានូវអំណាចក្នុងដំណើរការ ក្តីដោយខ្លួនឯង ធ្វើឲ្យតុលាការមិនឋិតនៅក្រោមឥទ្ធិពល"នយោ-បាយអំណាច"អន្តរជាតិ ហើយអាចបង្កជាមូលដ្ឋានគ្រឹះនៃ ប្រព័ន្ធច្បាប់អន្តរជាតិថ្មីមួយ ។ ព្រះរាជអាជ្ញាឯករាជ្យមួយរូបអាច ធ្វើពាក្យបណ្តឹងទល់នឹងពលរដ្ឋម្នាក់នៃប្រទេសមហាអំណាចដោយ ងាយ ប៉ុន្តែរដ្ឋាភិបាលនៃប្រទេសមួយទៀតមិនងាយធ្វើដូច្នោះទេ ពីព្រោះការធ្វើបែបនោះអាចបង្កឲ្យមានការវាយបកវិញខាង ផ្នែកសេដ្ឋកិច្ច ឬការទូត (ឬផ្នែកយោធាផងក៏ថាបាន) ។

សំណួរចុងក្រោយដែលបានលើកឡើងយ៉ាងច្បាស់ក្រឡែត នៅក្នុងការចរចាអំពីលក្ខន្តិកៈរបស់តុលាការគឺអំពីទំនាក់ទំនងរវាង តុលាការព្រហ្មទណ្ឌអន្តរជាតិជាមួយក្រុមប្រឹក្សាសន្តិសុខអង្គការ សហប្រជាជាតិ ។ សហរដ្ឋអាមេរិកបានស្នើឡើងថាក្រុមប្រឹក្សា សន្តិសុខគួរតែពិនិត្យរាល់ការកាត់ទោសទាំងអស់មុនពេលចាប់ ផ្តើមដំណើរការ ។ ការធ្វើដូចនេះច្បាស់ជានឹងផ្តល់ឲ្យសមាជិក អចិន្ត្រៃយ៍ទាំងប្រាំរបស់ក្រុមប្រឹក្សាសន្តិសុខ (រួមទាំងសហរដ្ឋ អាមេរិក រុស្ស៊ី និង ចិន) នូវលទ្ធភាពបញ្ឈប់ការកាត់ទោសមួយ មិនឲ្យដំណើរការទៅមុខបាន និងដើម្បីធានាយ៉ាងប្រាកដថា គ្មាន ជនណាម្នាក់មកពីប្រទេសទាំងប្រាំនេះត្រូវទទួលការកាត់ទោសនៅ ក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិឡើយ ។ សន្និសីទការទូតដែល មានបន្ទុកបង្អាក់ការសរសេរលក្ខន្តិកៈ បានបដិសេធចោលសំណើ នេះ ហើយបានបង្កើតដំណោះស្រាយសម្របសម្រួលមួយ ។ ក្រុមប្រឹក្សាសន្តិសុខមានសិទ្ធិបញ្ឈប់រាល់ការកាត់ទោសទាំងអស់ សម្រាប់រយៈពេលមួយឆ្នាំម្តង ប្រសិនបើក្រុមប្រឹក្សាសន្តិសុខ យល់ឃើញថា ការកាត់ទោសនឹងប៉ះពាល់ដល់សន្តិភាពនិងសន្តិសុខ អន្តរជាតិ ។ ការធ្វើដូចនេះមានន័យថា ក្រុមប្រឹក្សាសន្តិសុខរក្សា បាននូវអំណាចដាច់ខាតខាងផ្នែកសន្តិភាពនិងសន្តិសុខ ប៉ុន្តែធានា ថាគ្មានប្រទេសណាមួយអាចបង្អាក់សកម្មភាពរបស់តុលាការ ដោយឯកតោភាគីនោះទេ ។ បច្ចុប្បន្នដើម្បីពន្យារទុកការស៊ើប អង្កេតឬការកាត់ទោសមួយចាំបាច់ត្រូវមានការបោះឆ្នោតគាំទ្រ ពីសមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាសន្តិសុខ ។

តុលាការព្រហ្មទណ្ឌអន្តរជាតិជានិមិត្តរូបនៃជំហានទៅមុខ មួយទៀតទៅកាន់ប្រព័ន្ធច្បាប់អន្តរជាតិមួយដែលមានអំណាច ធំធេងជាងអធិបតេយ្យភាពរដ្ឋ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាតឹកតាងបញ្ជាក់ពីការចង់បានរបស់មនុស្សជាតិនូវទ្រឹស្តីមួយ ដែលថា ជនទាំងឡាយណាដែលប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ

ធ្ងន់ធ្ងរបំផុតត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។ តាមការពិត កត្តាដ៏ធំមួយក្នុងការធ្វើឲ្យតុលាការក្លាយទៅជាមានអំណាចដូចពេលបច្ចុប្បន្នគឺជាការលេចឡើងនៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនដែលតាមដានដំណើរការចរចាបង្កឲ្យមានការបញ្ចេញយោបល់ជាសាធារណៈ និងជួយអូសទាញឲ្យមានការបញ្ចូលវិធានការផ្សេងៗដែលអង្គការទាំងនោះយល់ថាសំខាន់ ។ ក្រុមនោះគឺ "សង្គមស៊ីវិលអន្តរជាតិ" អាចជាតំណាងនៃសង្គមអន្តរជាតិដែលតុលាការព្រហ្មទណ្ឌអន្តរជាតិហាក់មានកាតព្វកិច្ចឆ្លើយតប ។ ក្នុងពេលជាមួយគ្នាសង្គមស៊ីវិលក៏ជាឥទ្ធិពលដ៏ធំមួយនៅក្នុងការជំរុញឲ្យតុលាការវិវត្តទៅមុខនៅក្នុងទិសដៅអន្តរជាតិនិយម ។

## បទឧក្រិដ្ឋនៅក្រៅសមត្ថកិច្ចតុលាការព្រហ្មទណ្ឌអន្តរជាតិ

ទោះបីជាយ៉ាងណា តុលាការព្រហ្មទណ្ឌអន្តរជាតិមិនទាន់ក្លាយទៅជាអង្គភាពសកលមួយដែលមានអំណាចជាទូទៅនៅឡើយ ។ ទី១ មួយភាគធំនៃបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរនៅលើពិភពលោកត្រូវបានប្រព្រឹត្តឡើងដោយរដ្ឋាភិបាលទៅលើប្រជាពលរដ្ឋខ្លួនឯង (ដូចករណីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា) ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិគ្មានអំណាចអ្វីទាំងអស់ក្នុងការដោះស្រាយរឿងក្តីនេះ ។ ពលរដ្ឋនៃប្រទេសទាំងឡាយដែលមិនបានផ្តល់សច្ចាប័នទៅឲ្យលក្ខន្តិកៈច្បាប់របស់តុលាការមិនអាចត្រូវបានកាត់ទោសចំពោះអំពើដែលប្រជាពលរដ្ឋទាំងនោះបានប្រព្រឹត្តនៅក្នុងប្រទេសរបស់ខ្លួនបានឡើយ លើកលែងតែក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបោះឆ្នោតផ្តល់សិទ្ធិទៅឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ភាគច្រើននៃប្រទេសទាំងឡាយដែលបានចូលរួមគាំទ្រតុលាការជាប្រទេសដែលឲ្យតម្លៃនិងគោរពធម្មាធិបតេយ្យ ។ ការចាត់ទុកតុលាការនេះជាស្ថាប័នសម្រាប់បម្រើអ្នកមានគុណធម៌មិនត្រឹមត្រូវទាំងស្រុងទេ ប៉ុន្តែក៏មានការពិតខ្លះនៅក្នុងការបរិយាយបែបនេះ ។

ហេតុនេះ បណ្តឹងដំបូងៗភាគច្រើនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចមានប្រភពមកពីប្រទេសទាំងឡាយដែលរដ្ឋាភិបាលរបស់ខ្លួនគាំទ្រនិងឲ្យតម្លៃចំពោះឧត្តមគតិនៃច្បាប់អន្តរជាតិ ប៉ុន្តែជារដ្ឋាភិបាលដែលពុំមានការគ្រប់គ្រងពេញលេញទៅលើទឹកដីរបស់ខ្លួន ។ ប្រទេសទាំងនោះមានដូចជា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ អាហ្វហ្គានីស្ថាន ឬ កូឡុំប៊ី ។ ក្នុងករណីនេះរដ្ឋាភិបាលទាំងនោះអាចចូលរួមតុលាការព្រហ្មទណ្ឌជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងស្តារធម្មាធិបតេយ្យនៅក្នុងស្រុកដែលសឹងតែជាការប្រកាសអំពីតម្លៃដែលប្រទេសទាំងនេះសង្ឃឹមថានឹងលេចឡើងនៅក្នុងរដ្ឋាភិបាលរបស់ខ្លួន ។ ស្ថានភាពនៅក្នុងប្រទេសកូឡុំប៊ីកាន់តែស្មុគស្មាញឡើង ដោយសារការផ្លាស់ប្តូររបបដឹកនាំនិងដោយការជំទាស់ជាបន្តបន្ទាប់អំពីវិសាលភាពស្របច្បាប់នៃកិច្ចព្រមព្រៀងលើកលែងទោស (ដូចរៀបរាប់ខាងក្រោម) ។

នៅក្នុងគ្រប់ករណី ទោះបីជានៅពេលតុលាការព្រហ្មទណ្ឌអាចដាក់ពាក្យបណ្តឹងទល់នឹងជនសង្ស័យមួយរូប តុលាការព្រហ្មទណ្ឌគ្មានអំណាចដោយខ្លួនឯងក្នុងការចាប់ខ្លួនជននោះទេ ។ តុលាការព្រហ្មទណ្ឌពឹងផ្អែកទៅលើការគាំទ្ររបស់រដ្ឋាភិបាលជាតិក្នុងការប្រគល់ខ្លួនជនជាប់ចោទ ឬប្រើប្រាស់កងកម្លាំងប៉ូលិស ឬយោធាដើម្បីចាប់ខ្លួនជនជាប់ចោទប៉ុណ្ណោះ ។ ដូចតុលាការឧក្រិដ្ឋកម្មសង្គ្រាមសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបង្ហាញ ការណ៍នេះមិនអាចមើលស្រាលបានឡើយ ។ ជនជាប់ចោទពីររូបក្នុងចំណោមជនជាប់ចោទផ្សេងទៀតដែលគេប្រកាសចាប់ខ្លួនក្រោយពីទទួលការចោទប្រកាន់ពីតុលាការយូហ្គោស្លាវី គឺរ៉ាដូវ៉ាន់ការ៉ាដហ្ស៊ីក និងឧត្តមសេនីយ៍ រ៉ាត់កូ ម្លាឌីក មានសេរីភាពនៅក្រៅច្បាប់អស់រយៈពេល៨ឆ្នាំទោះបីជាមានវត្តមានទាហានរបស់អង្គការណាតូរាប់ម៉ឺននាក់ឈរជើងនៅតំបន់ដែលជនមួយរូបក្នុងចំណោមជនទាំងពីរខាងលើលាក់ខ្លួនក៏ដោយ ។

## តុលាការនៃជម្រើសចុងក្រោយ

លក្ខណៈសំខាន់មួយទៀតរបស់តុលាការព្រហ្មទណ្ឌអន្តរ-ជាតិគឺថា តុលាការព្រហ្មទណ្ឌមិនមានអាទិភាពទៅលើតុលាការជាតិទេ (តុលាការយូហ្គោស្លាវីនិងរ៉្វាន់ដា) ហើយអាចត្រឹមតែដោះស្រាយរឿងក្តីណាដែលប្រទេសជាសមាជិកពុំមានលទ្ធភាពដោះស្រាយ ។ ទ្រឹស្តីនេះ ដែលត្រូវគេស្គាល់ជាពាក្យបច្ចេកទេសថា "ការបំពេញឲ្យ" ធ្វើឲ្យតុលាការព្រហ្មទណ្ឌក្លាយទៅជាជម្រើសចុងក្រោយ ។ លក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមចែងថា តុលាការអាច

ចាប់ផ្ដើមដំណើរការកាត់ទោសនៅពេលដែលរដ្ឋមួយដែលមានសមត្ថកិច្ចទៅលើរឿងក្ដីនោះ (ជាទូទៅគឺជាប្រទេសកំណើតរបស់ជនជាប់ចោទ) បង្ហាញដោយខ្លួនឯងថា "មិនមានឆន្ទៈឬមិនអាចអនុវត្តការស៊ើបអង្កេតឬការកាត់ទោសយ៉ាងពិតប្រាកដ" ។ ដូចគ្នាដែរ ប្រទេសណាដែលមានប្រព័ន្ធច្បាប់គួរឲ្យទុកចិត្តបាន និងមានដំណើរការធម្មតា នឹងត្រូវផ្ដល់ឱកាសឲ្យបង្ហាញថាខ្លួនកំពុងតែពិនិត្យទៅលើការចោទប្រកាន់ដោយខ្លួនឯង ហើយនៅក្រោមកាលៈទេសៈបែបនោះ តុលាការព្រហ្មទណ្ឌនឹងមិនកាត់ទោសពីរឿងក្ដីនោះទេ ។

ជាការពិតណាស់ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងសម្រេចចិត្តថាតើប្រទេសពាក់ព័ន្ធកំពុងតែធ្វើការស៊ើបអង្កេតទៅលើរឿងក្ដីមួយយ៉ាងពិតប្រាកដឬទេ ។ លក្ខន្តិកៈទីក្រុងរ៉ូមដាក់លក្ខខណ្ឌយ៉ាងច្រើនសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បដិសេធការសម្រេចចិត្តរបស់តុលាការជាតិដោយចែងថា ការដោះស្រាយរឿងក្ដីរបស់ប្រទេសមួយត្រូវតែធ្វើឡើងក្នុង "គោលបំណងការពារជនជាប់ពាក់ព័ន្ធកុំឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ" ។ តុលាការព្រហ្មទណ្ឌមិនមែនបង្កើតដើម្បីទស្សន៍ទាយទុកនូវសាលក្រមនៃការស៊ើបអង្កេតជាតិដ៏ត្រឹមត្រូវនោះទេ គឺដើម្បីទទួលយករឿងក្ដីទាំងនោះមកដោះស្រាយ នៅពេលដែលអាជ្ញាធរជាតិរំលោភទៅលើបទដ្ឋានច្បាប់ដោយឥតលាក់លៀម ។

បទបញ្ញត្តិនៃ"ការបំពេញឲ្យ"ហាក់ដូចជាផ្ដល់ឱកាសឲ្យរដ្ឋមួយចំនួនសម្រេចចិត្តមិនកាត់ទោសបុគ្គលឬមនុស្សមួយក្រុមដោយសារមូលហេតុនៃការផ្សះផ្សាជាតិ ដូចដែលប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើតាមរយៈគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា ។ ប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិ ហ្វីលីពខឺស្ស បានថ្លែងសុន្ទរកថាមួយទៅកាន់ព្រះរាជវិទ្យាស្ថាននៃកិច្ចការអន្តរជាតិនៅទីក្រុងឡុងដ៍ថា "ការលើកលែងទោសក្នុងកម្រិតកំណត់មួយចំនួនអាចស្រប"ទៅនឹងកាតព្វកិច្ចស៊ើបអង្កេតឬកាត់ទោសយ៉ាងពិតប្រាកដនៅក្រោមលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ។ ក្នុងពេលជាមួយគ្នា តុលាការព្រហ្មទណ្ឌអាចមិនទទួលស្គាល់បទបញ្ញត្តិ
១ នៃការលើកលែងទោសទូទៅដែលបង្កើតឡើងដោយរបបប្រព្រឹត្តខ្រិដ្ឋកម្មក្នុងគោលបំណងការពារមន្ត្រីរបស់ខ្លួន ។ តុល្យភាពពិតប្រាកដនឹងលេចឡើងតាមរយៈការសម្រេចចិត្តជាក់ស្ដែងរបស់តុលាការព្រហ្មទណ្ឌអាចជាផ្នែកដែលទទួលការតាមដានយ៉ាងយកចិត្តទុកដាក់ពីតុលាការព្រហ្មទណ្ឌ ។

នេះគឺជាអ្វីដែលបានកើតឡើងនៅអាមេរិកឡាទីន ។ គ្មានតំបន់ណាមួយនៅក្នុងពិភពលោកមានការពិភាក្សាវែកញែកដ៏ក្ដៅគគុករវាងការផ្សះផ្សាជាតិនិងយុត្តិធម៌នៅពីក្រោយការកើតឡើងនៃខ្រិដ្ឋកម្មទ្រង់ទ្រាយធំដែលប្រព្រឹត្តឡើងដោយមន្ត្រីនៃរដ្ឋនោះទេ ។ ប្រទេសភាគច្រើននៅអាមេរិកឡាទីន មិនទាន់បានដាក់ឲ្យខ្រិដ្ឋជនទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម ការចាប់ពង្រត់ និងការកាប់សម្លាប់ ដែលបង្កឡើងដោយមន្ត្រីសាធារណៈនៅក្នុងឆ្នាំកន្លងទៅថ្មីៗនៅឡើយទេ ។ ការលេចឡើងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអាចជួយប្រទេសទាំងនេះឲ្យខិតកាន់តែជិតទៅនឹងបទដ្ឋានអន្តរជាតិនៅថ្ងៃមុខ ។ បញ្ហាធំបំផុតគឺ នៅប្រទេសកូឡុំប៊ី ដែលមានជម្លោះប្រដាប់អាវុធដ៏ហិង្សាកំពុងតែកើតឡើង ហើយជាប្រទេសដែលរដ្ឋាភិបាលថ្មីបានជ្រើសយកការលើកលែងទោសជាមធ្យោបាយដើម្បីបញ្ឈប់ការបាញ់គ្នា ។

## តើតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងបម្រើផលប្រយោជន៍នយោបាយឬ?

តុលាការព្រហ្មទណ្ឌអន្តរជាតិជានិមិត្តរូបនៃការស្រុះស្រួលគ្នារវាងគំនិតពីរៈ ប្រទេសទាំងអស់គួរតែទទួលខុសត្រូវជាចម្បងចំពោះការគ្រប់គ្រងការអនុវត្តវិធាននៃច្បាប់នៅក្នុងទឹកដីរបស់ខ្លួន ហើយការដាក់ឲ្យខ្រិដ្ឋជនឲ្យទទួលខុសត្រូវចំពោះខ្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅក្រោមច្បាប់អន្តរជាតិគឺជាការចាប់អារម្មណ៍របស់ជាតិនិងអន្តរជាតិ ។ មានវិធានការមួយចំនួនសម្រាប់ការពារតុលាការព្រហ្មទណ្ឌពីការកេងបន្លំ និងសម្រាប់ទប់ស្កាត់មិនឲ្យព្រះរាជអាជ្ញាប្ដឹងផ្ដល់ដើម្បីផលប្រយោជន៍នយោបាយជាជាងគោលបំណងច្បាប់ ។ ទីមួយ មុនពេលព្រះរាជអាជ្ញាអាចបើកការស៊ើបអង្កេតព្រះរាជអាជ្ញាត្រូវតែពន្យល់គណៈកម្មការបុរេជំនុំជម្រះដែលមានចៅក្រមបីរូបថា មានរឿងក្ដីដែលត្រូវឆ្លើយតប ។ បន្ទាប់មកព្រះរាជអាជ្ញានោះត្រូវបញ្ជាក់ប្រាប់ប្រទេសដែលមានសមត្ថកិច្ចទៅលើរឿងក្ដីដែលព្រះរាជអាជ្ញាកំពុងត្រួតពិនិត្យ ហើយផ្ដល់ដល់ប្រទេសនោះនូវឱកាសស៊ើបអង្កេតដោយខ្លួន

៦៨។ ប្រសិនបើព្រះរាជអាជ្ញាជឿជាក់ថា ប្រទេសនោះមិនស៊ើបអង្កេតទៅលើរឿងក្តីនោះដោយជាក់ស្តែង ព្រះរាជអាជ្ញាត្រូវត្រឡប់ទៅកាន់អង្គបុរេជំនុំជម្រះ ហើយបកស្រាយឲ្យគណៈកម្មការនេះគាំទ្រការសម្រេចចិត្តរបស់ព្រះរាជអាជ្ញា។ ប្រទេសដែលជាប់ពាក់ព័ន្ធអាចធ្វើពាក្យបណ្តឹងឧទ្ធរណ៍ ចំពោះការសម្រេចចិត្តនេះទៅកាន់សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

ជាការពិត ការការពារដែលផ្តល់ដោយបញ្ញត្តិទាំងនេះត្រូវពឹងផ្អែកទៅលើលក្ខណៈសម្បត្តិរបស់បុគ្គលដែលត្រូវបានជ្រើសរើសមកបំពេញការងារជាព្រះរាជអាជ្ញានិងចៅក្រម។ ប៉ុន្តែ ការជ្រើសរើសត្រូវបានធ្វើឡើងដោយប្រទេសដែលជាសមាជិកនៃតុលាការព្រហ្មទណ្ឌ ហើយប្រទេសទាំងនេះជាទូទៅជាអ្នកគោរពច្បាប់។ ក្រុមទីមួយនៃចៅក្រមនិងអគ្គព្រះរាជអាជ្ញាត្រូវបានជ្រើសរើស ហើយជាក្រុមដែលមើលទៅគួរឲ្យទុកចិត្តបាន។ ជាក់ស្តែង ចៅក្រមជាន់ខ្ពស់ (ប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិ)គឺលោក ហ្វីលីព ខឺស្ស ជាមេធាវីអន្តរជាតិ សញ្ជាតិកាណាដា ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការងាររៀបចំតុលាការនេះ។ អគ្គព្រះរាជអាជ្ញាគឺលោក លូីស ម៉ូរេណូ អូខេមប៉ូ មេធាវីជនជាតិអាហ្សង់ទីន ដែលបានចូលរួមនៅក្នុងរឿងក្តីសិទ្ធិមនុស្សធំៗប្រឆាំងនឹងមេដឹកនាំយោធានៅក្នុងប្រទេសរបស់លោក។ ថ្មីៗនេះលោកបានធ្វើជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យនីតិសាស្ត្រហាវើត។

ទោះជាយ៉ាងណាក៏ដោយ សហរដ្ឋអាមេរិកជឿជាក់ថាតុលាការព្រហ្មទណ្ឌអន្តរជាតិជាឧបសគ្គចំពោះនយោបាយរបស់ខ្លួន។ រដ្ឋាភិបាលប្រធានាធិបតី គ្លីនតុន បានពន្យារពេលមួយឆ្នាំកន្លះមុននឹងចុះហត្ថលេខាទៅលើលក្ខន្តិកៈទីក្រុងរ៉ូម បន្ទាប់មកមិនបានព្យាយាមជំរុញឲ្យព្រឹទ្ធសភាផ្តល់សច្ចានុម័ត។ រដ្ឋាភិបាលប្រធានាធិបតី ប៊ូស ថែមទាំងបានបញ្ជាក់ប្រាប់ជាផ្លូវការទៅកាន់អង្គការសហប្រជាជាតិថាអាមេរិកមិនបានព្យាយាមផ្តល់សច្ចានុម័តដល់លក្ខន្តិកៈទេ។ ដោយសារមូលហេតុនេះ សហរដ្ឋអាមេរិកមិនចាំបាច់បំពេញតាមការទាមទារមិនឲ្យចាត់វិធានការផ្ទុយទៅនឹងគោលគំនិតរបស់លក្ខន្តិកៈ។ សហរដ្ឋអាមេរិកបានចាប់ផ្តើមអនុវត្តយុទ្ធនាការជុំវិញពិភពលោក ដើម្បីចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសផ្សេងៗឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ កិច្ចព្រមព្រៀងនោះទាមទារឲ្យប្រទេសទាំងនេះ មិនប្រគល់ខ្លួនពលរដ្ឋអាមេរិកដែលតុលាការព្រហ្មទណ្ឌអន្តរជាតិតាមចាប់នោះទេ ផ្ទុយទៅវិញ បែរជាឲ្យបញ្ជូនជនទាំងនោះទៅសហរដ្ឋអាមេរិក។ នៅពាក់កណ្តាលខែវិច្ឆិកា ប្រទេសចំនួន៦៦បានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងបែបនោះ រួមទាំងប្រទេសមួយចំនួនដែលទទួលជំនួយយោធាសំខាន់ៗពីអាមេរិកផង។

កិច្ចព្រមព្រៀងដែលមានឈ្មោះថា «កិច្ចព្រមព្រៀងអភ័យឯកសិទ្ធិទ្វេភាគី» ពេលខ្លះហៅថា «កិច្ចព្រមព្រៀងមាត្រាទី៩៨» (នៅក្នុងលក្ខន្តិកៈច្បាប់តុលាការ) អាចមិនផ្តល់ការការពារគ្រប់គ្រាន់ដូចដែលសហរដ្ឋអាមេរិករំពឹងទុក។ លក្ខន្តិកៈទីក្រុងរ៉ូមបានអនុញ្ញាតឲ្យមានកិច្ចព្រមព្រៀងអភ័យឯកសិទ្ធិ ប៉ុន្តែច្បាប់បានចែងយ៉ាងច្បាស់ថា ការអនុញ្ញាតនេះត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងដែលរៀបរាប់ថា «ការបញ្ជូនខ្លួនជនមួយរូបទៅកាន់តុលាការទាមទារឲ្យមានការយល់ព្រមពីរដ្ឋ»។ ប្រែជាភាសាសាមញ្ញ ឃ្លានេះហាក់មានន័យថា តុលាការព្រហ្មទណ្ឌនឹងទទួលស្គាល់តែកិច្ចព្រមព្រៀងណាដែលធ្វើឡើងចំពោះជនដែលត្រូវបានបញ្ជូនទៅបរទេសដោយបុព្វហេតុផ្លូវការ ដូចជា បុគ្គលិក យោធា ឬអ្នកការទូត តែមិនមែនជាមន្ត្រីរដ្ឋាភិបាលដែលចូលនិវត្តន៍ ឬមន្ត្រីយោធាដែលធ្វើដំណើរដោយមូលហេតុផ្ទាល់ខ្លួននោះទេ។

ផ្ទុយទៅវិញ កិច្ចព្រមព្រៀងដែលសហរដ្ឋអាមេរិកបានចុះហត្ថលេខា ត្រូវបានធ្វើឡើងដើម្បីគ្របដណ្តប់ទៅលើពលរដ្ឋអាមេរិកទាំងអស់។ នៅក្នុងករណីពលរដ្ឋសាមញ្ញ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចសម្រេចថាលក្ខន្តិកៈរបស់តុលាការមិនបានទាមទារឲ្យតុលាការគោរពតាមកិច្ចព្រមព្រៀងទាំងនេះទេ ហើយអាចដាក់ចេញនូវសំណើមួយទាមទារឲ្យជននោះត្រូវបញ្ជូនទៅតុលាការ។ នៅក្រោមច្បាប់អន្តរជាតិ ប្រទេសដែលស្ថិតនៅក្នុងល្បែងទាញព្រ័ត្រនេះត្រូវឲ្យតម្លៃទៅលើកាតព្វកិច្ចរបស់ខ្លួនចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាជាងកិច្ចសន្យាទ្វេភាគីជាមួយសហរដ្ឋអាមេរិក ហើយប្រគល់ខ្លួនជនជាប់ពាក់ព័ន្ធ។

ទោះបីជាយ៉ាងណា ព្រឹត្តិការណ៍បែបនោះមិនងាយនឹង

កើតឡើងទេ ។ សំណួរសំខាន់គឺថា តើការជំទាស់របស់សហរដ្ឋអាមេរិកចំពោះតុលាការព្រហ្មទណ្ឌមានមូលដ្ឋានការពិតដែរឬទេ តើមានក្តីសង្ឃឹមខ្លះទេថាសហរដ្ឋអាមេរិកអាចចូលរួមនាពេលណាមួយ ។ បេក្ខជនប្រធានាធិបតីប្រជាធិបតេយ្យនាំមុខមួយចំនួនបានរិះគន់រដ្ឋាភិបាលប្រធានាធិបតី ប៊ូស ចំពោះការប្រឆាំងនឹងតុលាការព្រហ្មទណ្ឌហួសពេក ។ ជាក់ស្តែងឧត្តមសេនីយ៍ វើសស្លឹក បានពោលថា «យើងត្រូវតែរកមធ្យោបាយធ្វើការជាមួយតុលាការនេះ និងកែប្រែនូវអ្វីដែលចាំបាច់» ។ ចៅហ្វាយក្រុងហាវ៉ាត ដៀន ទាញហេតុផលនៅដើមឆ្នាំនេះថា សហរដ្ឋអាមេរិកគួរតែ«ព្យាយាមសរសេរសាជាថ្មី»នូវលក្ខន្តិកៈទីក្រុងរ៉ូមជៀសវាង«ដើរចេញ»ពីលក្ខន្តិកៈនេះ ។ ព្រឹទ្ធបុរស ចន កែរី បាននិយាយថា«ខ្ញុំគាំទ្រការចូលរួមរបស់សហរដ្ឋអាមេរិកនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ តែខ្ញុំក៏ជឿជាក់ថាមន្ត្រីអាមេរិករួមទាំងទាហានធម្មតា គួរតែត្រូវបានផ្តល់ការការពារពីការកាត់ទោសដែលបម្រើផលប្រយោជន៍នយោបាយ» ។

លោក ប៉ូល ខាន់ បានវិភាគទៅលើមូលហេតុដែលនាំឲ្យមានការជំទាស់ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងសហរដ្ឋអាមេរិក ។ ប៉ូល ខាន់ ទាញហេតុផលថា ការជំទាស់នេះមិនអាចយល់បានដោយគ្រាន់តែពឹងទៅលើការទាញហេតុផលជំទាស់របស់រដ្ឋាភិបាលបច្ចុប្បន្ននោះទេ ។ ប៉ូល ខាន់ ស្នើឡើងថា ការប្រឆាំងរបស់សហរដ្ឋអាមេរិកចំពោះតុលាការមិនត្រូវបានជំរុញដោយការគំរាមកំហែងជាក់ស្តែងរបស់តុលាការទេ វាជាអ្វីដែលតុលាការនេះតាងឲ្យប៉ុណ្ណោះ ។ តុលាការព្រហ្មទណ្ឌជាតំណាងនៃគំនិតដែលថា ការយកច្បាប់ជាធំគឺពឹងផ្អែកទៅលើមូលហេតុទូទៅជាសកលមិនមែនតម្លៃនៅក្នុងសង្គមជាតិណាមួយទេ ។ ប៉ុន្តែនៅសហរដ្ឋអាមេរិក ធម្មាធិបតេយ្យត្រូវបានមើលឃើញថាជាតឹកតាងនៃអធិបតេយ្យភាពប្រជាជនដូចដែលបានបញ្ចូលនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ។ ហេតុផលរបស់ ខាន់ បញ្ជាក់ថា ការជំទាស់របស់សហរដ្ឋអាមេរិកមិនងាយនឹងប្រែប្រួលទៅតាមការទាញហេតុផលជាក់ស្តែងមួយមុខទេ វាទាមទារឲ្យមានការពិភាក្សាវែកញែកទូលំទូលាយជាងនេះអំពីអត្ថន័យនៃធម្មាធិបតេយ្យនៅក្នុងបរិបទអន្តរជាតិ ។

## តើតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវធ្វើយ៉ាងដូចម្តេច?

នយោបាយសហរដ្ឋអាមេរិកចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិអាចទទួលឥទ្ធិពលពីសកម្មភាពរបស់តុលាការព្រហ្មទណ្ឌនៅក្នុងឆ្នាំដំបូងនៃដំណើរការ ។ ហ៊ីលីព ខីស្ស បានបញ្ជាក់ប្រាប់ព្រះរាជវិទ្យាស្ថាននៃកិច្ចការអន្តរជាតិថា កិច្ចការចម្បងរបស់លោកគឺបង្កើតឲ្យមានការជឿជាក់ទៅលើតុលាការក្នុងការងារជាក់ស្តែងតាមរយៈការបង្ហាញនូវ «ភាពយុត្តិធម៌ និងប្រសិទ្ធភាពនៃនីតិវិធីតុលាការ» ។ ខីស្ស ក៏បានបន្ថែមថា ការបើកចំហរបស់តុលាការចំពោះជនរងគ្រោះគឺជាផ្នែកមួយសំខាន់បំផុតនៃការងាររបស់តុលាការ ហើយតុលាការព្រហ្មទណ្ឌនឹងពិចារណាការដាក់


គណៈប្រតិភូទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង(ស-

ទីតាំងនៅក្នុងប្រទេសដែលអំពើឧក្រិដ្ឋបានកើតឡើង(បើអាចធ្វើទៅបាន) ដើម្បីស្វែងរកយុត្តិធម៌ប្រជាជនដែលទទួលឥទ្ធិពលដោយផ្ទាល់ ។ (រៀបរាប់នៅក្នុងមាត្រាទី៣នៃលក្ខន្តិកៈ) ។

ក្នុងពេលជាមួយគ្នា អគ្គព្រះរាជអាជ្ញារបស់តុលាការ លុីស ម៉ូរេណូ អូកាំប៉ូ ដែលឡើងកាន់តំណែងនៅខែមិថុនា បានប្រកាសថាគាត់កំពុងតែពិនិត្យទៅលើសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលអាចជាប្រទេសសម្រាប់ការស៊ើបអង្កេតផ្លូវការទីមួយរបស់គាត់ ។ អូកាំប៉ូ ទទួលបន្ទុកជាអ្នកកំណត់ថា រឿងក្តីប្រភេទណាគួរនាំឡើងតុលាការ ។ អូកាំប៉ូ ទាមទារឲ្យមានការកាត់ទោសជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលធ្លាក់ចូលទៅក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌ ទាំងអ្នកធ្វើការសម្រេចចិត្តនយោបាយនិងយោធា និងជនដែលគាំទ្រឧក្រិដ្ឋកម្មតាមវិធីផ្គត់ផ្គង់ថវិកាឬចូលរួមនៅក្នុងការជួញដូរល្មើសច្បាប់ ។




នៅក្នុងដំណើរការរយៈពេលយូរ បញ្ហាមួយទៀតដែលតុលាការនឹងត្រូវប្រឈមមុខគឺការឆ្លើយតបរបស់តុលាការទៅនឹង“អំពើបង្កជម្លោះ” ។ នៅក្នុងការកាត់ក្តីនៅនូរឹមប៊ឺក “អំពើបង្កជម្លោះ”ត្រូវបានរួមបញ្ចូលទៅក្នុងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មចំពោះមេដឹកនាំរបស់របបណាហ្ស៊ី ។ តាមការពិត នៅក្នុងក្រសែភ្នែករបស់រដ្ឋាភិបាលអាមេរិក អំពើបង្កជម្លោះជាផ្នែកមួយសំខាន់បំផុតនៃការកាត់ក្តី ។ តាំងពីពេលនោះ អំពើបង្កជម្លោះមិនមែនជាប្រធានបទសំខាន់នៅក្នុងវិវត្តន៍នៃនីតិព្រហ្មទណ្ឌអន្តរជាតិទេ ។ អំពើបង្កជម្លោះ មិនត្រូវបានរាប់បញ្ចូលនៅក្នុងបញ្ជីបទឧក្រិដ្ឋនៃតុលាការ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដាឡើយ ។ នៅក្រោមលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិពិតជាមានយុត្តាធិការទៅលើអំពើបង្កជម្លោះ ប៉ុន្តែដោយមានដាក់លក្ខខណ្ឌថា វាមានឥទ្ធិពលបានតែក្នុងករណីបន្ទាប់ពីបានធ្វើវិសោធនកម្មទៅលើលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូម ដែលកំណត់និយមន័យនៃអំពើបង្កជម្លោះ ហើយបង្កើតលក្ខខណ្ឌ ដែលតុលាការអាចកាត់ទោសពីបទនេះ ។ (លក្ខន្តិកៈច្បាប់ចែងថា វិសោធនកម្មអាចអនុម័តបានតែក្នុងករណីដែលតុលាការបានចេញជារូបរាងរយៈពេល៧ឆ្នាំ) ។ នៅក្នុងលក្ខន្តិកៈព្រាងដំបូងសម្រាប់តុលាការអំពើបង្កជម្លោះអាចកាត់ទោសបានក្រោយពីមានការរកឃើញដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ នេះជារូបមន្តមួយដែលអាចទទួលស្គាល់សម្រាប់តុលាការដោយខ្លួនឯង ។

ហេតុនេះ មានហេតុផលជាច្រើនដែលត្រូវវាយតម្លៃទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ បញ្ហាជាច្រើនប្រែប្រួលទៅតាមការវិវត្តន៍របស់តុលាការដោយខ្លួនឯង អាកប្បកិរិយារបស់សហរដ្ឋអាមេរិកនិងតួនាទីរបស់នីតិព្រហ្មទណ្ឌអន្តរជាតិនៅក្នុងនយោបាយពិភពលោក ។

**អាន់តូនី ដកឃីន**

# ការលំបាកក្នុងការកសាងសន្តិភាពនៅកម្ពុជា និងតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល

## តើធ្វើយ៉ាងដូចម្តេចដើម្បីឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យ ក្លាយជាកម្មសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា?

**(តចប់)**

នៅក្នុងការសិក្សាស្រាវជ្រាវមួយស្តីអំពីការកសាងសន្តិភាពនៅកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្នាក់តំបន់របស់អង្គការសហប្រជាជាតិបានពន្យល់ថា សន្តិសុខមនុស្សជាតិនឹងត្រូវបានគេយល់ថា ជាបុព្វលក្ខខណ្ឌនៃការអភិវឌ្ឍន៍មនុស្សជាតិ ពិសេសជាងនេះទៅទៀត ជាមធ្យោបាយមួយ «ក្នុងការរំដោះប្រជាជនឲ្យផុតពីការពឹងផ្អែក» ដែលអនុញ្ញាតឲ្យបុគ្គលម្នាក់ៗចូលរួម «ដោយសុវត្ថិភាពនិងដោយសេរី» នៅក្នុងដំណើរការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ ។

នៅក្នុងស្នាដៃនិពន្ធដែលមានចំណងជើងថា «សន្តិភាព អំណាច និង ការតស៊ូនៅកម្ពុជា» ឡៃហ្សុី ផ្តល់ហេតុផលថា បទនិពន្ធនានាអំពីដំណោះស្រាយជម្លោះ ត្រូវការជាចាំបាច់ឲ្យមានការសរសេរភ្ជាប់គ្នាជាមួយ «វាក្យស័ព្ទនយោបាយថ្មី» ដើម្បីកែប្រែសារជាតិជម្លោះដែលលេចឡើងជាលក្ខណៈសង្គមហើយប្រែក្លាយទៅជានយោបាយអហិង្សា ។ នៅក្នុងសំណេរមួយទៀតរបស់ ឡៃហ្សុី ដែលមានចំណងជើងថា «សន្តិសុខមនុស្សជាតិនៅក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា» អ្នកនិពន្ធបានរុករកនូវលទ្ធភាពនានាដែលផ្តល់ដោយសទ្ទានុក្រមនៃពាក្យ «សន្តិសុខមនុស្សជាតិ» នៅប្រទេសវៀតណាម ឡាវ និងកម្ពុជា ។ ឡៃហ្សុី ផ្តល់ជាយោបល់ថា «ដើម្បីគាំទ្រជាកម្លាំងឲ្យបានទូលំទូលាយដល់ការកែប្រែសង្គមដែលអ្នកប្រឆាំងនយោបាយយកសិទ្ធិជាមូលដ្ឋាននៅកម្ពុជាត្រូវតែបង្កើតនោះ ការនិយាយអំពីសន្តិសុខមនុស្សជាតិក៏ជាការជួយមួយដែរ ពីព្រោះវារកឃើញតាមរយៈរបៀបវារៈផ្នែកបញ្ហានិងសង្គម នូវគោលបំណងមួយចំនួនដែលត្រូវតែទទួលបាននៅក្នុងបរិបទនេះ» ។

តើអ្វីទៅជា «របៀបវារៈផ្នែកបញ្ហានិងសង្គម» នៃសន្តិសុខមនុស្សជាតិ? ហើយអ្វីទៅជាការប្រើប្រាស់នូវគំនិតកសាងសន្តិភាពនៅកម្ពុជា? និយាយឲ្យខ្លី សន្តិសុខមនុស្សជាតិគឺជាសកម្មភាពទាំងឡាយដែលយកប្រជាជនជាធំ ហើយការកសាងសន្តិភាពតម្រូវឲ្យមានយុទ្ធសាស្ត្រនានាដែល «កសាងស្ពាន» ភ្ជាប់រវាងប្រជាជនសាមញ្ញនិងអ្នកថ្នាក់លើ ។ ដូចនេះ សន្តិសុខមនុស្សជាតិអាចផ្តល់នូវលក្ខខណ្ឌចាំបាច់នានាសម្រាប់ការបង្កើតនូវលទ្ធិប្រជាធិបតេយ្យ ។ នៅពេលឆ្លុះបញ្ចាំងអំពីការអនុវត្តដ៏សំខាន់នៃសន្តិសុខមនុស្សជាតិនៅភូមិភាគអាស៊ី-អាគ្នេយ៍ ឡៃហ្សុី បញ្ជាក់ច្បាស់អំពីទំនាក់ទំនងរវាងសន្តិសុខមនុស្សជាតិនិងការកសាងជាស្ថាប័ន ។ មានការផ្តល់និយមន័យផ្សេងៗគ្នាទៅលើពាក្យថាសន្តិសុខមនុស្សជាតិ ទោះជានិយមន័យទាំងនោះមានធាតុសំខាន់រួមគ្នាតែមួយគត់ក៏ដោយ ។ និយមន័យមួយគឺថា គឺការផ្តោតសំខាន់ទៅលើតម្រូវការចាំបាច់ក្នុងការគាំពារបុគ្គលឯកត្តជន ពីព្រោះថា មានតែពេលដែលបុគ្គលផុតភ័យទើបស្ថាប័នជាតិនិងស្ថាប័នអន្តរជាតិអាចមានលក្ខណៈស្របច្បាប់និងផុតភ័យ ។

បន្ទាប់ពីទស្សនកថារបស់ ឡៃហ្សុី មានការទាញហេតុផលថា «ការកែប្រែសង្គមត្រូវការជាចាំបាច់នៅក្នុងប្រទេសកម្ពុជាដើម្បីឲ្យប្រព័ន្ធប្រជាធិបតេយ្យជ្រួតជ្រាបនៅក្នុងសង្គមកម្ពុជាខ្លួនឯងផ្ទាល់ ។ អ្វីដែលសំខាន់ចំពោះសង្គមកម្ពុជាគឺប្រព័ន្ធនៃការ

លូនក្រាបដូចដែល លីនសាយ ហ្វ្រែង បានពិពណ៌នាថា «អំណាចនយោបាយនិងការគ្រប់គ្រងនយោបាយជាប្រពៃណីពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ជាមួយអ្នកជំនួយការ និយោជិត និងអ្នកស្មោះស្ម័គ្រនឹងខ្លួន ដែលផ្តល់នូវការគាំទ្រប្តូរជាមួយនឹងការគាំពារ និងជំនួយតាមទម្រង់ផ្សេងៗ» ។ ឃើតធីស ក៏បានកត់សម្គាល់ដែរថា «ទិកាសនិយមបែបនេះ ក៏មាននៅក្នុងសង្គមខ្មែរក្រោយសម័យអ៊ុនតាក់ដែរ» ។ ឧទាហរណ៍ គេអាចគិតដល់ការអនុវត្តជាក់ស្តែងដែលគណបក្សប្រជាជននិងគណបក្សហ៊្វុនស៊ិនប៉ិចនៅពេលរៀបចំការបោះឆ្នោតឆ្នាំ១៩៩៣និង ឆ្នាំ១៩៩៨ ដែលកាលនោះ គ្រឿងចានឆ្នាំងនិងឧបករណ៍ប្រើប្រាស់ជាច្រើនគោន ត្រូវបានយកទៅចែកដោយថ្នាក់ដឹកនាំគណបក្សក្នុងនាមជា«អំណោយផ្ទាល់ខ្លួន» ដែលនេះជាការបង្ហាញយ៉ាងប្រត្យក្សថាទិដ្ឋភាពលូនក្រាបនៃវប្បធម៌ខ្មែរនៅតែបន្តមានរហូត ។ ដោយផ្អែកលើការចុះស្រាវជ្រាវតាមមូលដ្ឋាន ហិនទ្រីកសៀន សង្កេតឃើញថា «ការអភិវឌ្ឍន៍នយោបាយកម្ពុជាត្រូវបានរារាំងដោយលក្ខខណ្ឌវប្បធម៌និងលក្ខខណ្ឌស្ថាប័នទាំងនេះ» ។

លីនសាយ ហ្វ្រែង ពន្យល់ថា ការលូនក្រាបនិយមត្រូវបានលើកកម្ពស់ដោយភាពខុសគ្នាច្រើនពេកនៃទ្រព្យសម្បត្តិ ឋានៈ អំណាច និង «សន្តិសុខផ្ទាល់ខ្លួន» ។ ជាការច្បាស់ណាស់ ដើម្បីលុបបំបាត់ភាពលូនក្រាបនិយម និងដើម្បីបណ្តុះបទដ្ឋានប្រជាធិបតេយ្យ ដំបូងឡើយគេត្រូវគិតថាសន្តិសុខអាចត្រូវបានផ្តល់ជាលក្ខណៈប្រជាធិបតេយ្យបាន ។ ការប្រើប្រាស់នូវទស្សនៈសន្តិសុខមនុស្សជាតិគឺស្ថិតនៅត្រង់ការចាប់យកនូវការគំរាមកំហែងច្រើនយ៉ាងដែលជាមូលហេតុសំខាន់នៃការគង់វង្សនៃប្រព័ន្ធលូនក្រាបនិយមនៅកម្ពុជា ។ ហេតុដូចនេះ ការផ្តល់នូវសន្តិសុខស្មើគ្នាចំពោះមនុស្សជាតិអាចដើរទន្ទឹមនឹងការលុបបំបាត់ប្រព័ន្ធលូនក្រាបនិយម ហើយបណ្តោយឲ្យ «សន្តិភាពតាមបែបប្រជាធិបតេយ្យ» ដុះពន្លកឡើង ។ ទោះបីជាមិនបាននិយាយយោងដល់ «សន្តិសុខមនុស្សជាតិ» ខ្លួនវាផ្ទាល់ក៏ដោយ ម៉ៃឃើល ដូឡេ បញ្ជាក់ច្បាស់ថា «យើងគួរតែចាត់ទុកសន្តិភាពជាវិសាលគមដែលមានចម្រុះទាំងសន្តិសុខនិងអសន្តិសុខ» ។

ជាការគួរឲ្យចាប់អារម្មណ៍ សេចក្តីថ្លែងការណ៍ឆ្នាំ២០០២ របស់អង្គការមិនមែនរដ្ឋាភិបាលនិយាយយោងដល់ «សន្តិសុខមនុស្សជាតិ» តែម្តងគត់ នៅក្នុងជំពូកមួយដែលនិយាយអំពី «ការកាត់បន្ថយនិងការគ្រប់គ្រងអាវុធធុនតូច» ។

ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលចង់ប្រើភាសា «សន្តិសុខមនុស្សជាតិ» អង្គការទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការផ្ចាញ់បាវចនាជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រដែលនិយាយថា «ការកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ធានានូវនិរន្តរភាពបរិស្ថាននិងសមធម៌ក្នុងសង្គម» ។ ដូចដែលបានគូសបញ្ជាក់ដោយ ថេយល័រ អូវិន កំណើនសេដ្ឋកិច្ចដែលអ្នកប្រឆាំងនឹងសន្តិសុខមនុស្សជាតិអាចទាញហេតុផលនឹងមិនដោះស្រាយបានច្រើននូវកត្តាទាំងឡាយដែលពិតជាកំពុងមានផលប៉ះពាល់ដល់ប្រជាជនកម្ពុជា ដូចជាជំងឺឆ្លង (គ្រុនចាញ់ អេដស៍ របេង គ្រុនឈាម និងជំងឺខ្វះឈាមក្រហម) ដែលកំពុងតែគំរាមកំហែងប្រជាជនរាប់រយនាក់ ទឹកជំនន់ ភាពរាំងស្ងួត និងការកាប់បំផ្លាញព្រៃឈើ (ដែលបណ្តាលឲ្យមានការខូចខាតជាដំណាំនូវផលដំណាំនិងលំនៅឋានរបស់ប្រជាជន និងបណ្តាលឲ្យមានអស្ថិរភាពសង្គម) និងការគំរាមដោយហេតុផលនយោបាយ ។ ចំពោះបញ្ហានេះ ដំណោះស្រាយសេដ្ឋកិច្ចពិបាកនឹងគ្រប់គ្រាន់ណាស់ ហើយប្រព័ន្ធលុតក្រាបនៅតែជាសំណាញ់ដ៏មានគ្រោះថ្នាក់ចំពោះលទ្ធិប្រជាធិបតេយ្យ ។

ពាក្យថា «សន្តិសុខមនុស្សជាតិ» គឺជាការផ្តល់អំណាច (ប្រហែលជាច្រើនជាងប្រជាធិបតេយ្យផងនៅក្នុងបរិបទនយោបាយកម្ពុជា) ពីព្រោះថាវាមិនត្រឹមតែផ្លាស់ប្តូរសន្តិសុខបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាដើរតួជាអ្នកធ្វើឲ្យរួចផុតពីការគំរាមកំហែងទៀតផង ។ បើចង់ឲ្យប្រជាជនសង្ឃឹមនិងទាមទារឲ្យមានតួនាទីនៅក្នុងសន្តិសុខរបស់ខ្លួនផ្ទាល់ ទំនងជាត្រូវតែធ្វើឲ្យលេចឡើងនូវចលនានយោបាយនៅក្នុងចំណោមប្រជាជនសាមញ្ញ ។ ទោះជាគេមិនបានប្រើពាក្យថា«សន្តិសុខមនុស្សជាតិ» ក៏ដោយ តាមពិតគេអាចយល់បានថា នៅក្នុងនយោបាយកាត់បន្ថយភាពក្រីក្ររបស់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាដែលជាការផ្ទុយទាំងស្រុងទៅនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល

គំនិតនេះផ្តោតសំខាន់ទៅលើកំណើនសេដ្ឋកិច្ច ។ ការកំណត់អត្តសញ្ញាណនិងមូលហេតុនៃភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាតម្រូវឲ្យមានការស្វែងយល់ទូលំទូលាយអំពីភាពក្រីក្រ មិនមែនមើលតែទៅលើប្រាក់ចំណូលមួយមុខនោះទេ ។ ការស្វែងយល់ឲ្យបានទូលំទូលាយអំពីពាក្យថាក្រីក្រ គួរតែបញ្ចូលនូវទស្សនៈនៃសិទ្ធិមនុស្ស ក៏ដូចជាការចូលរួមឲ្យបានសកម្មពីសំណាក់អ្នកក្រីក្រខ្លួនឯង ដើម្បីរកឲ្យឃើញនូវមូលហេតុអ្វីដែលបណ្តាលឲ្យគាត់ក្រនិងវិធីសាស្ត្រដែលធ្វើឲ្យគាត់អាចរើបម្រះខ្លួនពីភាពក្រីក្រ ។ មានតែតាមវិធីនេះទេទើបអង្គការមិនមែនរដ្ឋាភិបាលអាចខិតជិតការកាត់បន្ថយភាពក្រីក្រ ។

ចំណុចចុងក្រោយនិងដើម្បីជាការផ្តល់នូវកម្លាំងបន្ថែមទៀតទៅលើទស្សីករណ៍ដែលថាអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើជា "ឯកអគ្គរដ្ឋទូតនៃសន្តិសុខមនុស្សជាតិ" យកល្អគួរលើកយកសំណេររបស់ សារ៉ា ម៉ៃយើល ដែលសរសេរអំពី "តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងសន្តិសុខមនុស្សជាតិ" ។ អ្នកស្រីលើកឡើងនូវហេតុផលបីយ៉ាងដែលអង្គការមិនមែនរដ្ឋាភិបាលប្តេជ្ញាចិត្តដោះស្រាយបញ្ហាសន្តិសុខមនុស្សជាតិតាមរយៈសកម្មភាពរបស់ខ្លួន ។ មូលហេតុទីមួយគឺ ជារឿយៗ សន្តិសុខមនុស្សជាតិមានការទាក់ទងនឹងបញ្ហានានាដែលអង្គការមិនមែនរដ្ឋាភិបាលបានក្តោបយ៉ាងមាំទៅហើយ ។ ជាក់ស្តែង នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ឆ្នាំ២០០២ អង្គការទាំងនេះទទួលស្គាល់រួចជាស្រេចនូវការគំរាមកំហែងដល់សន្តិសុខមនុស្សជាតិ បើទោះជាក្រោមរូបភាពផ្សេងៗគ្នាក្តី ដូចជា "ភាពក្រីក្រ" "ការអភិវឌ្ឍន៍មិនទាន់ប្រសើរ" ជាដើម ។ល ។

មូលហេតុទីពីរ សារ៉ា ម៉ៃយើល ផ្តល់ជាយោបល់ថា "ការផ្តើមគំនិតកំណត់សេចក្តីជាសន្តិសុខមនុស្សជាតិនឹងជួយឲ្យអង្គការមិនមែនរដ្ឋាភិបាលកសាងនូវប្រព័ន្ធតំណាងនិយម ព្រមទាំងទទួលបាននូវអ្នកគាំទ្រកាន់តែច្រើន" ពីព្រោះថា វាមានប្រយោជន៍ខាងនយោបាយដល់ប្រទេសផ្តល់ជំនួយដើម្បីរៀបចំថវិកាបន្ថែមសម្រាប់ "ករណីសន្តិសុខ" ។ ដូចដែលបង្ហាញជូននៅក្នុងសេចក្តីបន្ថែមទី២ ចំនួនអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាកំពុងកើនឡើង ប៉ុន្តែទីភ្នាក់ងារជំនួយអន្តរជាតិផ្តល់ថវិកាតែចំពោះ "អង្គការក្នុងស្រុកមួយចំនួនដែលមានការរៀបចំចាត់ចែងត្រឹមត្រូវប៉ុណ្ណោះ" ។ ការទទួលយកនូវ "កម្មវិធីសន្តិសុខមនុស្សជាតិ" ដែលទទួលបានការកោតសរសើរឥតដាច់ពីមាត់តាមរយៈនយោបាយការបរទេសនិងប្រទេសដែលបានអភិវឌ្ឍន៍ នឹងជួយ "បង្កើនភាពជឿជាក់របស់គេ" ក្នុងការធានានូវហិរញ្ញប្បទានអន្តរជាតិ ។

មូលហេតុទីបី សារ៉ា ម៉ៃយើល ពន្យល់ថា ទស្សនៈសន្តិសុខមនុស្សជាតិផ្តល់ឱកាសឲ្យមានការផ្លាស់ប្តូរវិធីសាស្ត្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការ "បំពេញកិច្ចការ" ដោយផ្លាស់ប្តូរនូវវិធីសាស្ត្រសម្រាប់រយៈពេលខ្លីដើម្បីទទួលយកនូវវិធានការការពារដូចដែលតម្រូវដោយ "ភាពបន្ទាន់នៃសន្តិសុខមនុស្សជាតិ" ក្នុងការផ្តាច់នូវឫសគល់នៃអសន្តិសុខ ។ ជាក់ស្តែង ការផ្តោតយកចិត្តទុកដាក់ទៅលើការការពារ អាចបង្ខំឲ្យម្ចាស់ជំនួយផ្លាស់ប្តូរនូវការផ្តល់ហិរញ្ញប្បទានរបស់ខ្លួនពីជំនួយសម្រាប់រយៈពេលខ្លីនិងមានភ្ជាប់លក្ខខណ្ឌឲ្យទៅជាកិច្ចសន្យាច្រើនផ្នែកនិងមានរយៈពេលយូរ ។ ការផ្លាស់ប្តូរបែបនេះមានផលប្រយោជន៍យ៉ាងធំធេងដល់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាដែលតែងតែបង្ខំចិត្តកាត់បោលនូវគម្រោងកម្មវិធីរបស់ខ្លួនដោយសារតែ "មិនស៊ីគ្នា" ជាមួយកម្មវិធីរយៈពេលខ្លីរបស់ម្ចាស់ជំនួយ ។

### ខ) ភ្ជាប់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងវិមជ្ឈការដើម្បីផ្តោតទៅរកកម្មវិធីមូលដ្ឋានសម្រាប់សន្តិភាព

"សតវត្សរ៍ចុងក្រោយនេះ ប្រជាជនកម្ពុជាត្រូវបានគ្រប់គ្រងដោយរដ្ឋបាលមជ្ឈការនិងផ្តាច់ការនិយមបែបបារាំងជួនកាលគ្រប់គ្រងដោយរាជានិយមផ្តាច់ការ បន្ទាប់មក គ្រប់គ្រងដោយប្រព័ន្ធកុម្មុយនិស្តមជ្ឈការនិងផ្តាច់ការកាន់តែខ្លាំង ។ មកដល់ចុងបញ្ចប់នៃសង្គ្រាមលោកលើកទី២ មេដឹកនាំកម្ពុជាធ្លាប់យក "ប្រព័ន្ធចក្រវាឡ" មកដឹកនាំប្រទេស ។ ប្រព័ន្ធនេះគឺជាការប្រមូលផ្តុំអំណាចឲ្យស្ថិតក្នុងដៃអ្នកដឹកនាំតែម្នាក់ ហើយមិនអត់ឱនចំពោះទស្សនៈណាដែលផ្ទុយនឹងទស្សនៈរបស់ខ្លួន ។ ភូឈួយនិងមន្ត្រីអ្នកមុខអ្នកការទាំងអស់ត្រូវរណប ព្រមទាំងធ្វើជាអ្នកបម្រើឬជាឧបករណ៍ ។ ជាថ្នូរមកវិញ ភូឈួយនិងមន្ត្រីអ្នកមុខអ្នកការទាំងអស់ទទួលបាននូវអំណាចដ៏រឹងមាំនៅតាមតំបន់ដែល

ខ្លួនកាន់កាប់ ។ ប្រជាជនកម្ពុជាស្ថិតនៅក្រោមការដឹកនាំរបស់ព្រះមហាក្សត្រ និងធ្វើជាសាវ័ករបស់អ្នកកាន់អំណាចផែនដី» ។ ឡៅ ម៉ុង ហៃ

បើយោងតាម ឡៃហ្សុី មរតកបន្សល់ទុកដោយរបបផ្តាច់ការនិងអភិបាលកិច្ចនយោបាយទាំងនេះ នាំឲ្យ "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" មិនស៊ីគ្នាជាមួយឆាកនយោបាយរបស់កម្ពុជា ។ តាមការពិត នយោបាយក្រោយសម័យអ៊ុនតាក់បានបន្តគំរូ "អ្នកឈ្នះទទួលបានអ្វីៗទាំងអស់" ហើយអំណាចស្ថិតនៅក្នុងដៃរបស់ថ្នាក់ដឹកនាំមួយចំនួនតូច ។ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០២ ថ្នាក់ដឹកនាំទាំងនោះហាក់ដូចជាបន្ធូរអំណាច ។ ឱកាសក្នុងការបង្កើតប្រជាធិបតេយ្យបើកចំហយ៉ាងធំជាមួយនឹងកំណែទម្រង់បែបវិមជ្ឈការ ។ កម្មវិធីអភិបាលកិច្ចមូលដ្ឋានឈានដល់ដំណាក់កាលថ្មីនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០២ នៅពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន១៦២១រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ។ កំណែទម្រង់នេះធ្វើឡើងដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងដើម្បីជំរុញឲ្យមានការចូលរួមពីសំណាក់ប្រជាជនកម្ពុជានៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមតាមមូលដ្ឋាន ឈានទៅកាត់បន្ថយភាពក្រីក្រដូចដែលរដ្ឋាភិបាលបានលើកឡើង ។

របាយការណ៍រដ្ឋាភិបាលបន្តទៀតថា "រាជរដ្ឋាភិបាលកម្ពុជាយល់អំពីការលំបាកដ៏ធំធេងដែលខ្លួនជួបប្រទះក្នុងការបង្កើតនិងសម្រិតសម្រាំងគោលនយោបាយនិងបទបញ្ញា បានប្រមូលកៀងគរជំនួយហិរញ្ញវត្ថុក្នុងនិងក្រៅប្រទេស ដើម្បីពង្រីកការយល់ដឹងអំពីទស្សនៈនិងគោលការណ៍ទាំងនេះតាមរយៈការផ្តោតសំខាន់ទៅលើអភិបាលកិច្ចមូលដ្ឋាននិងកសាងនូវសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់និងស្ថាប័នរដ្ឋាភិបាល ដើម្បីឈានទៅអនុវត្តឲ្យមានប្រសិទ្ធភាពនូវការទទួលខុសត្រូវក្នុងអាណត្តិរបស់ខ្លួន" ។

បើទោះជាកម្មវិធីនេះស្តាប់ទៅវិសេសវិសាលយ៉ាងណាក្តីក៏នៅតែមានការប្រថុយប្រថានមួយថា រចនាសម្ព័ន្ធដែលទើបតែបង្កើតថ្មីនឹងដូចគ្នាទៅនឹងរចនាសម្ព័ន្ធលូនក្រាបដែលគ្របដណ្តប់ជីវិតនយោបាយរបស់ខ្មែរជាយូរមកហើយនោះ ។ ដូចនេះ ការសម្រេចបាននូវជោគជ័យប្រកបដោយនិរន្តរភាពចេញពីកម្មវិធីនេះមួយផ្នែកធំអាស្រ័យទៅលើភាពជាដៃគូរវាងរដ្ឋាភិបាលនិងសហគមន៍អ្នកផ្តល់ជំនួយនិងរវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល ។ ពេលវេលាមកដល់ហើយសម្រាប់អង្គការមនុស្សធម៌ព្រមទាំងអ្នកផ្តល់ហិរញ្ញប្បទានក្នុងការចូលរួមយ៉ាងម៉ឺងម៉ាត់ក្នុងសកម្មភាពអភិវឌ្ឍន៍ដែលមិនត្រឹមតែជាលក្ខណៈ "កែរោគ"ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានលក្ខណៈការពារនិងនាំឲ្យមានលទ្ធផលដល់ការផ្លាស់ប្តូរសង្គមទៀតផង ។

### ◆ ដើម្បីសម្រេចបាននូវសន្តិសុខមនុស្សជាតិត្រូវតែមានវិមជ្ឈការ

ការពិនិត្យលើរូបសណ្ឋាននៃសន្តិសុខដូចដែលស្នើឡើងនៅក្នុងហេតុផលដែលថ្លែងរួចមកហើយថា ជំហានដំបូងឆ្ពោះទៅរកសន្តិសុខមនុស្សជាតិគឺចាំបាច់ត្រូវពិនិត្យឡើងវិញអំពីនយោបាយ ។ និយាយម្យ៉ាងទៀត គ្រោងការអភិបាលកិច្ចដែលប្រតិបត្តិទៅតាមខ្សែបន្ទាត់សន្តិសុខមនុស្សជាតិ តម្រូវឲ្យមានវិមជ្ឈការជាចាំបាច់ ពីព្រោះការគំរាមកំហែងដល់សន្តិសុខមនុស្សជាតិអាចចៀសផុតបានតែកម្រិតទាបបំផុត ។ គេអាចអះអាងបានថាសន្តិសុខមនុស្សជាតិត្រូវការវិមជ្ឈការ ពីព្រោះលទ្ធផលនៃការទទួលបានកាន់តែច្រើននូវការអប់រំ សុខាភិបាល ទឹក អនាម័យព្រមទាំងការសន្យាផ្តល់នូវសន្តិភាពស្ថិរភាពសង្គមនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច នឹងមិនអាចមាននិរន្តរភាពបានទេបើគ្មានការអភិវឌ្ឍន៍សមត្ថភាពនិងស្ថាប័ននៅតាមមូលដ្ឋាន ។ ការឲ្យនិយមន័យរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍តំបន់របស់អង្គការសហប្រជាជាតិបង្ហាញច្បាស់អំពីចំណុចនេះ ។ អភិបាលកិច្ចមូលដ្ឋានត្រូវបានពិពណ៌នាថាជា "ដំណើរការដែលសហគមន៍នានាដោះស្រាយភាពចាំបាច់និងជាអាទិភាពរបស់ខ្លួនតាមរយៈរដ្ឋាភិបាលមូលដ្ឋានដែលមានលក្ខណៈឆ្លើយតបនិងមានការទទួលខុសត្រូវ" ។

ដូឡេ កត់សម្គាល់ថា ចំណុចខ្សោយមួយក្នុងចំណោមចំណុចខ្សោយមួយចំនួននៃកូនសោសន្តិភាពរបស់កម្ពុជា គឺការបែងចែកគ្នារវាងទីក្រុងនិងជនបទ ។ ទោះបីជានៅជនបទមានអសន្តិសុខធ្ងន់ធ្ងរជាងក៏ដោយ (ការវាយតម្លៃលើភាពក្រីក្រនៅកម្ពុជាឆ្នាំ១៩៩៩របស់ក្រសួងផែនការបង្ហាញថា ចំនួន

*ប្រជាជនក្រីក្រនៅតាមជនបទមានដល់ជិត៩០ភាគរយ) ក៏ភាគច្រើននៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាធ្វើប្រតិបត្តិការនៅទីក្រុងភ្នំពេញដែលអ្នកក្រីក្រតែ១,៨ភាគរយប៉ុណ្ណោះ ។*

*បើក្រឡេកមើលមួយភ្លែតទៅលើផែនទីបង្ហាញទីតាំងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ឃើញថាផ្ទុយនឹងផែនទីបញ្ជាក់អំពីស្ថានភាពក្រីក្រនៅក្នុងប្រទេសនេះ ។ ខេត្តក្របំផុត (ដូចជាខេត្តសៀមរាបដែលមានកម្រិតភាពក្រីក្រ៧៥ភាគរយ) មិនមែនជាខេត្តដែលមានចំនួនអង្គការមិនមែនរដ្ឋាភិបាលច្រើនបំផុតនោះទេ ។ មានតែអង្គការមិនមែនរដ្ឋាភិបាលពី២១-៣០ ប៉ុណ្ណោះដែលមានការិយាល័យនៅខេត្តសៀមរាប ផ្ទុយទៅវិញនៅភ្នំពេញមានទីតាំងអង្គការពី៥១-៦០ ។ និយាយអំពីការបែងចែកធនធានជំនួយវិញ អ្នកស្រី ជូឌី លិច្ឆវូដ បំភ្លឺថា “តាមការពិត ជំនួយភាគច្រើន ដូចជាទឹកប្រាក់រាប់លានដុល្លារដែលបោះក្នុងស្រុកខ្មែរសម័យអ៊ុនតាក់ មាននៅតែក្នុងទីក្រុងភ្នំពេញ ។ ក្នុងចំណោមទឹកប្រាក់២កោដិដុល្លារជាជំនួយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបានពីសហគមន៍អន្តរជាតិរវាងឆ្នាំ១៩៩៣-៩៦ មួយចំនួនធំមិនទៅណាឆ្ងាយពីរាជធានីទេ» ។ ភាពមិនស៊ីសង្វាក់គ្នារវាងតំបន់ដែលប្រជាជនចង់បានជំនួយជាចាំបាច់ និងតំបន់ដែលអង្គការមិនមែនរដ្ឋាភិបាលបោះទីតាំង ជះឥទ្ធិពលយ៉ាងខ្លាំងដល់គ្រោងការណ៍វិមជ្ឈការ ដែលក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមយ៉ាងសកម្មដើម្បីធ្វើវិមជ្ឈការរចនាសម្ព័ន្ធរបស់ខ្លួន ព្រមទាំងធ្វើឲ្យកាន់តែស៊ីគ្នាជាមួយភាពចាំបាច់ឲ្យមានសន្តិសុខមនុស្សជាតិ ។*

### ◆ ភាពជាដៃគូរវាងម្ចាស់ជំនួយនិងរដ្ឋាភិបាលៈ ការកសាងសមត្ថភាពមូលដ្ឋាន

*“ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមមុនហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាការលំបាកបំផុតសម្រាប់ការអភិវឌ្ឍន៍ ។ ម្ចាស់ជំនួយមិនអាចផ្តោតសំខាន់ខ្លាំងពេកទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងប្រទេសដែលខ្វះខ្លាំង ហើយក៏មិនអាចធ្វើមិនដឹងមិនឮចំពោះហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងប្រទេសដែលកំពុងតែឈានទៅមុខដែរ» ។ អៀន ស្មិលី*

*ប្រទេសកម្ពុជាដែលខ្វះប្រពៃណីនៃការធ្វើសេចក្តីសម្រេចជាលក្ខណៈប្រជាធិបតេយ្យ និងមានបទពិសោធន៍តិចតួចក្នុងផ្នែកអភិបាលកិច្ចនៅកម្រិតមូលដ្ឋាន ពិតជាខ្វះខាតនូវធនធានមនុស្ស ។ ការគ្រប់គ្រងគ្មានប្រសិទ្ធភាពនៅតាមមូលដ្ឋាននិងអភិបាលកិច្ចខ្សោយ បង្ហាញអំពីឧបសគ្គធ្ងន់ធ្ងរដល់សន្តិសុខមនុស្សជាតិ ព្រមទាំងរារាំងដល់ការបែងចែកផលប្រយោជន៍វិមជ្ឈការឲ្យបានស្មើគ្នា ។*

*តម្រូវការចាំបាច់ឲ្យមានជំនួយខាងសមត្ថភាពស្តែងឲ្យឃើញតាមរយៈឯកសារមួយរៀបរៀងដោយរដ្ឋាភិបាលខ្លួនឯងផ្ទាល់ មានចំណងជើងថា “កសាងភាពជាដៃគូដើម្បីការអភិវឌ្ឍន៍” ។ ឯកសារនេះរាយការណ៍ថា ទោះបីជាថ្មីៗនេះសហគមន៍អន្តរជាតិផ្តោតសំខាន់ទៅលើ“កម្មសិទ្ធិ”នៃដំណើរការអភិវឌ្ឍន៍ដោយកម្ពុជាក៏ដោយ “ក៏តាមការជាក់ស្តែង វាហាក់ដូចជាមិនទាក់ទងគ្នារវាងនយោបាយរបស់ម្ចាស់ជំនួយកម្រិតជាតិ និងវិធីសាស្ត្រដែលអនុវត្តដោយអ្នកដែលទទួលខុសត្រូវបែងចែកកម្មវិធីដែលម្ចាស់ជំនួយគាំទ្រនៅតាមមូលដ្ឋាន» ។ រដ្ឋាភិបាលពន្យល់ថាភាពមិនស្របគ្នានេះ ពិតជាបណ្តាលមកពីកម្រិតនៃសមត្ថភាពក្នុងស្រុក ។*

*ប្រសិនបើតម្រូវការដឹកនាំមូលដ្ឋានតាមបែបថ្មីដែលនឹងធ្វើការតាំងចិត្តចំពោះសន្តិសុខមនុស្សជាតិនិងកសាងសន្តិភាពនោះម្ចាស់ជំនួយគួរតែរៀបចំខ្លួនជាស្រេចដើម្បីវិនិយោគទៅលើធនធានក្នុងការកសាងសមត្ថភាពមូលដ្ឋាន ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍តំបន់របស់អង្គការសហប្រជាជាតិរិះគន់ថា កន្លងមក គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ-សង្កាត់ (ស៊ីឌីស៊ី) និងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (វីឌីស៊ី) បានបង្កើតគោលនយោបាយអភិវឌ្ឍន៍ដែលមានគោលបំណងសំខាន់ដើម្បីបង្កើនកំណើនសេដ្ឋកិច្ច “ដែលហាក់បីដូចជាថា កំណើនសេដ្ឋកិច្ចគឺគ្រាន់តែជារង្វាស់នៃការអភិវឌ្ឍន៍តែប៉ុណ្ណោះ» ។ ឡៅ ម៉ុងហៃ កត់សម្គាល់ថា “ឥឡូវនេះការផ្តោតសំខាន់ទៅលើការអប់រំ សូម្បីតែនៅថ្នាក់បឋមសិក្សាក្តីក៏ជាការអភិវឌ្ឍន៍ធនធានមនុស្សដែរ គឺសង្កត់ធ្ងន់ថាប្រជាជនកម្ពុជាជាធនធានសេដ្ឋកិច្ចជាជាងគិតថាជាពលរដ្ឋ» ។*

*គេអាចទាញហេតុផលថា ការសង្កត់ធ្ងន់ទៅលើកំណើនសេដ្ឋកិច្ចបណ្តាលមកពីទំនោររបស់ទីភ្នាក់ងារផ្តល់ជំនួយដែលធ្វើ*

ប្រតិបត្តិការយ៉ាងសំខាន់ក្នុងការកសាងសន្តិភាពតាមបែបសេដ្ឋកិច្ច ។ ហេតុដូចនេះ អ្វីជាភស្តុតាងគឺថា ទស្សនៈ "សន្តិសុខមនុស្សជាតិ" និង "ការកសាងសន្តិភាព" នៅតែមិនទាន់ជ្រួតជ្រាបនៅក្នុងប្រទេសកម្ពុជាដដែល ។ របាយការណ៍របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍តំបន់នៃអង្គការសហប្រជាជាតិសរសេរថា "រចនាសម្ព័ន្ធចាត់ចែងនិងគ្រប់គ្រង និងផ្នត់គំនិតរបស់រដ្ឋាភិបាលមូលដ្ឋាននៅមិនទាន់រឹងមាំនៅឡើយក្នុងការពុះពារជម្នះឲ្យបាននូវសន្តិសុខមនុស្សជាតិនិងការកសាងសន្តិភាព ។ គំនិតផ្តួចផ្តើមសន្តិសុខមនុស្សជាតិនិងការកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជា គួរតែពុះពារអភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ននានាដើម្បីការពារសន្តិសុខមនុស្សជាតិ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ។

### ◆ភាពជាដៃគូរវាងរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលៈ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាទារកក្នុងផ្ទៃនៃសង្គមស៊ីវិល

ខណៈដែលការអភិវឌ្ឍន៍សមត្ថភាពនៃអង្គភាពអភិបាលកិច្ចមូលដ្ឋានមានសារសំខាន់ ជោគជ័យចុងក្រោយនៃវិមជ្ឈការនឹងកាន់តែពឹងផ្អែកជាងមុនទៅលើសមត្ថភាពស្ថាប័ននៃក្រុមនានាបំពេញកិច្ចការក្នុងភូមិ ដើម្បីឲ្យក្រុមទាំងនេះអាចដឹកនាំនិងទ្រទ្រង់ដោយខ្លួនឯង ។ កន្លងមក កម្មវិធីសេដ្ឋកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាដែលជំរុញដោយម្ចាស់ជំនួយបានធ្វើឲ្យលែងជិតស្និទ្ធពីដំណើរការសង្គមវប្បធម៌និងនយោបាយនៅតាមមូលដ្ឋាន ជាពិសេសនៅក្នុងចំណោមអ្នកក្រីក្រនិងផ្នែកនានាដែលស្ថិតនៅក្រោមសង្គម ។ គម្រោងកម្មវិធីពីតូចដល់ធំបានរារាំងការដឹកនាំថ្នាក់មូលដ្ឋាន ព្រមទាំងបង្កើតជា "រោគសញ្ញាពឹងផ្អែកគ្នា" ក្នុងចំណោមសហគមន៍នានា ។ ក្នុងនាមជាអ្នកបែងចែក "អង្គការមិនមែនរដ្ឋាភិបាល" មិនបានជំរុញឲ្យសហគមន៍មានកម្មសិទ្ធិផ្តាច់មុខក្នុងការអភិវឌ្ឍន៍រយៈពេលវែងឡើយ ។

មានមតិរួមមួយក្នុងចំណោមអ្នកបម្រើការងារខាងអភិវឌ្ឍន៍ថា យកល្អ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិគួរតែនៅស្វយ័តពីរដ្ឋ ហើយធ្វើជាទារកក្នុងផ្ទៃរបស់សង្គមស៊ីវិល ។ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងហាក់ដូចជាថា គណៈកម្មាធិការអភិវឌ្ឍន៍ភូមិគឺជាឧបករណ៍នៃកម្មវិធីរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានមិនមែនជាស្ថាប័នឯករាជ្យឡើយ ។ ចន ម៉ាក អែនឌ្រូ និយាយនៅក្នុងព្រឹត្តិប័ត្រ *Cambodia Development Review* ថា "គេអាចវាយតម្លៃទៅលើការចូលរួមរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិរួមជាមួយភាពជាប់ទាក់ទិនគ្នារវាងរដ្ឋាភិបាលមូលដ្ឋាននិងសង្គមស៊ីវិល" ។ ក្នុងន័យនេះ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងនាមជា "ទីភ្នាក់ងារសម្រាប់ចងភ្ជាប់" មានសារសំខាន់ណាស់ ។

នៅពេលនិយាយអំពីវិមជ្ឈការ សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលបានប្រាប់ឲ្យដឹងជាមុនថា "តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល រួមទាំងទំនាក់ទំនងជាមួយរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ត្រូវតែកំណត់ឲ្យបានច្បាស់លាស់" ។ អង្គការមិនមែនរដ្ឋាភិបាលចាំបាច់ត្រូវក្លាយទៅជាអ្នកកសាងនិងអភិវឌ្ឍន៍សមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ក្នុងនាមជា "អ្នកសម្របសម្រួលការអភិវឌ្ឍន៍" ជាងជា "អ្នកអនុវត្ត" ។ មានតែគណៈកម្មាធិការអភិវឌ្ឍន៍ភូមិឈប់អនុវត្តកម្មវិធីអភិវឌ្ឍន៍ ហើយទុកឲ្យសមាគមប្រជាជន (ដូចជាគណៈកម្មាធិការវត្តជាដើម) ជួយខ្លួនឯង ទើបគណៈកម្មការអភិវឌ្ឍន៍ភូមិបានបំពេញសក្តានុពលរបស់ខ្លួនក្នុងនាមជាទារកក្នុងផ្ទៃនៃសង្គមស៊ីវិល ។ មានតែនៅក្នុងដៃសមាគមប្រជាជននេះទេ ទើបមានសក្តានុពលខ្លាំងបំផុតសម្រាប់កសាងនូវថ្នាក់ដឹកនាំមូលដ្ឋាន និងកសាងនូវជំនឿទុកចិត្តខាងទំនាក់ទំនង ។ បញ្ហាស្ថានភាពនៃទំនាក់ទំនងសង្គមថ្នាក់ភូមិត្រូវបានលើកឡើងនៅក្នុងសំណេរមួយដែលបញ្ជាក់ជូនក្រុមពិគ្រោះយោបល់អន្តរជាតិដែលប្រជុំនៅខែកក្កដាឆ្នាំ១៩៩៦ ស្តីអំពីបញ្ហាកម្ពុជា ។ សំណេរបាននិយាយថា "ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលអភិវឌ្ឍន៍សហគមន៍គូសបញ្ជាក់ថា បញ្ហាគឺស្ថិតនៅត្រង់កង្វះភាពស្និតល្មួតនិងការរៀបចំចាត់ចែងកង្វះនូវការចូលរួមរបស់ប្រជាជននៅក្នុងដំណាក់កាលអភិវឌ្ឍន៍ និងអសមត្ថភាពរបស់ប្រជាជនក្នុងការទទួលបាននូវធនធាននិងអភិវឌ្ឍន៍ជំនាញ" ។

ម៉ាន់ទូឡា លីអូណាត ផ្តល់នូវការបំភ្លឺជាក់ស្តែងមួយអំពីសារសំខាន់ដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវកំណត់ឲ្យបាន

ច្បាស់លាស់អំពីគំនិតផ្តួចផ្តើមរបស់ខ្លួនក្នុងការកសាងសន្តិភាព នៅក្នុង "សកម្មភាពជាក់លាក់ក្នុងការកសាងសន្តិភាព" ដូចជា "ការបណ្តុះបណ្តាលកសាងសន្តិភាព" និង "សិក្ខាសាលាស្តីអំពីជម្លោះនិងដំណោះស្រាយ" ។ អ្នកស្រីពន្យល់ថា "អ្នកធ្វើការខាងសន្តិភាពនៅតាមមូលដ្ឋានបានរកឃើញថា អ្នកក្រីក្រមិនអាចចូលរួមធ្វើលំហាត់ដោះស្រាយជម្លោះដែលចំណាយពេលយ៉ាងយូរដោយមិនបានទទួលផលប្រយោជន៍ជាក់ស្តែងចេញពីលំហាត់នេះទេ" ។ ការកសាងសន្តិភាពបែបនេះមានច្រើនណាស់នៅកម្ពុជាក្រោយឆ្នាំ១៩៩៣ ។ ដូចដែលបានរាយការណ៍ដោយ ឡៅ ម៉ុងហៃ ថា "អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិបានអនុវត្តសកម្មភាពនានា (ក្នុងនោះមានការបណ្តុះបណ្តាលផ្នែកតុលាការ ផ្នែកច្បាប់ និងសិទ្ធិមនុស្ស) ដោយបញ្ជូនពត៌មានអំពីសិទ្ធិមនុស្ស វិធាននៃច្បាប់ និងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគាំទ្រនិងពិនិត្យមើលសកម្មភាពសិទ្ធិមនុស្ស" ។ តាមដំបូន្មានរបស់ លីអូណាត ក្នុងការចងភ្ជាប់សន្តិភាពជាមួយការអភិវឌ្ឍន៍នេះ ការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលដោយផ្តល់អំណាចដល់ក្រុមជួយខ្លួនឯងឲ្យអនុវត្តកម្មវិធីនានាហាក់ដូចជាជំហានមួយឆ្ពោះទៅរកគោលដៅត្រឹមត្រូវ ។

ការពិនិត្យឡើងវិញទៅលើបទពិសោធន៍នៃការកសាងសន្តិភាពពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនៅប្រទេសកេនយ៉ា និងហ្កាតេម៉ាឡា បង្ហាញអំពីសេចក្តីសន្និដ្ឋានដូចគ្នាទាក់ទងនឹងប្រសិទ្ធភាពកាន់តែប្រសើរឡើងនៃការកសាងសន្តិភាពនៅតាមមូលដ្ឋាន ឬការកសាងសន្តិភាពតាមរយៈការងារ ដែលផ្ទុយទៅនឹងសិក្ខាសាលាអប់រំអំពីសន្តិភាព ដែលតាមការពិតប្រហែលជាមិនមែនជាបុព្វហេតុនាំឲ្យមានការកែប្រែសង្គមរយៈពេលយូរអង្វែងបានឡើយ ។ នៅក្នុងជំពូកមួយដែលមានចំណងជើងថា "កសាងសមត្ថភាពសង្គមស៊ីវិលដើម្បីសន្តិភាព" បានរាយការណ៍ថា "ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលគេពិនិត្យមើលនៅប្រទេសហ្កាតេម៉ាឡា មានតែអង្គការមួយចំនួនប៉ុណ្ណោះដែលមានអាណត្តិកសាងសន្តិភាពច្បាស់លាស់" ។ នៅពេលដែលសួរចំៗថាតើកិច្ចការរបស់ពួកគេ ចូលរួមចំណែកត្រឹមកម្រិតណាដល់ការអនុវត្តកិច្ចព្រមព្រៀងសន្តិភាព មានតែអង្គការពីរបីប៉ុណ្ណោះដែលមើលឃើញភាពចាំបាច់នៃការធ្វើទំនាក់ទំនងច្បាស់លាស់ ។ អង្គការមិនមែនរដ្ឋាភិបាលរបស់ហ្កាតេម៉ាឡាចាត់ទុកការកសាងសន្តិភាពថាជាលទ្ធផលចុងក្រោយនៃកិច្ចការរបស់ខ្លួន ជាជាងគិតថាវាជាសកម្មភាពដាច់ដោយឡែក


ការពិភាក្សាគ្នារវាងប្រជាជននិងព្រះសង្ឃ

និងជំនាញច្បាស់លាស់ ។ ការសិក្សាបានបន្តទៀតថា "ភាគច្រើននៃអន្តការទាំងនោះជំរុញកម្មវិធីផ្លាស់ប្តូរទ្រង់ទ្រាយធំ ដោយឈរលើមូលដ្ឋានកែប្រែសង្គម សេដ្ឋកិច្ច និងនយោបាយ ដែលក្បែរៗគ្នាទៅនឹងស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាព" ។

បុគ្គលិកអភិវឌ្ឍន៍កម្ពុជាមួយរូបបាននិយាយថា "បញ្ហាដំបូងគឺត្រូវបង្កើតទំនាក់ទំនង មិនមែនបង្កើតគម្រោងកម្មវិធីទេ" ។ បើចង់បញ្ចប់ទំនាក់ទំនងលូនក្រាបដើម្បីបង្កលទ្ធភាពឲ្យ"សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ចាក់ឫសនៅក្នុងជីវិតភូមិករ គំនិត



ទុកចិត្តគ្នាត្រូវតែស្តារឡើងវិញ ។ ដូចនេះ អង្គការមិនមែនរដ្ឋាភិបាលត្រូវតែធានាថា គណៈកម្មាធិការអភិវឌ្ឍន៍ភូមិត្រូវធ្វើឲ្យសមាគមប្រជាជនចូលរួមយ៉ាងពេញលេញនៅក្នុងការគ្រប់គ្រងទៅលើគម្រោងកម្មវិធីអភិវឌ្ឍន៍នៅមូលដ្ឋាន ។

**សេចក្តីសន្និដ្ឋាន**

**ការកសាងសន្តិភាពត្រូវការចាំបាច់នូវការតាំងចិត្ត**

នៅក្នុងស្នាដៃនិពន្ធដែលមានចំណងជើងថា "ការលួងលោមចិត្តកុំឲ្យស្អប់ខ្ពើម" ម៉ៃឃើល អ៊ីកណាទីហ្វ ពិពណ៌នាអំពីតម្រូវការចាំបាច់របស់ប្រទេសនានាក្រោយពីមានអន្តរាគមន៍អន្តរជាតិបែបដែនដូចជាអ៊ីរ៉ាក់ថា "សង្គមទាំងនេះត្រូវការជាចាំបាច់នូវសន្តិភាពផ្ទៃក្នុង ក្រោយមកគឺការស្តាបនាស្ថាប័ន ។ នេះគឺជាកិច្ចការដែលមិនស៊ីសង្វាក់គ្នាទាល់តែសោះចំពោះសម័យក្រោយសង្គ្រាមខណៈដែលពីការតស៊ូទើបនឹងបញ្ចប់ភ្លាមៗ ។ អ្វីដែលជាតម្រូវការចាំបាច់គឺការតាំងចិត្តរយៈពេលវែងមិនមែនជាការសម្តែងនោះទេ" ។

ការខកខានមិនបានបង្កើតនូវសន្តិភាពយូរអង្វែងនៅកម្ពុជាបញ្ជាក់ថា ការពិតបែបទំនើបនៃ "ការបញ្ចប់ភ្លាមៗ" អាចមានលក្ខណៈមិនសមស្របទៅនឹងល្បឿននៃការផ្លាស់ប្តូរសង្គមនៅមូលដ្ឋាន ប្រសិនបើជំរុញដោយគោលការណ៍នៃភាពស្វ័យសម្រេចចិត្តឬដោយតម្លៃតបស្នងខាងហិរញ្ញវត្ថុ ។ ហ៊ីជុន រ៉ូសផ្តល់យោបល់មួយដែលក្តោបក្តាសំខាន់ៗមួយចំនួនគួរឲ្យកត់សម្គាល់ដែលនាំដល់បរាជ័យនៃការកសាងសន្តិភាពនៅកម្ពុជា ។ យោបល់នោះគឺ "ដោយមិនបាច់គិតមើលអំពីផ្លូវចេញ អ្នករៀបចំផែនការគួរផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រ ។ បញ្ហាសំខាន់មិនមែនថាតើយើងចេញដោយរបៀបណានោះទេ ប៉ុន្តែថាតើធ្វើដូចម្តេចទើបដើរឲ្យទាន់ការផ្លាស់ប្តូរសង្គមដែលយើងរស់នៅ" ។

ប្រទេសកម្ពុជាក្រោយសម័យអ៊ីនតាក់គឺជាការបញ្ជាក់ថាការបោះឆ្នោតខ្លួនឯងមិនធានាថាលទ្ធិប្រជាធិបតេយ្យពិតជាចាក់ឫសនោះទេ ទោះបីវាជាជំហានសំខាន់ដំបូងនៅក្នុងដំណើរការអនុវត្តន៍ "សន្តិភាពលក្ខណៈប្រជាធិបតេយ្យ" ក៏ដោយចុះ ។ បទពិសោធន៍របស់ប្រទេសកម្ពុជាជាការផ្តាញ់ទៅលើសន្មតិអំពីល្បឿននៃការផ្លាស់ប្តូរស្ថាប័ននៅក្នុងសង្គមនានាក្រោយពីមានជម្លោះ ។ នៅក្នុងបរិបទនៃអសន្តិសុខហួសហេតុនៅជុំវិញទិដ្ឋភាពនយោបាយបច្ចុប្បន្ន ការអនុវត្តនយោបាយនិងសង្គមជាលក្ខណៈប្រពៃណីមិនអាចបង្ហោនតាមការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបានឡើយ ។ និយាយឲ្យជាក់ស្តែង កម្រិតនិងភាពស្មុគស្មាញនៃការប្រែប្រួលដែលជាការចាំបាច់ក្នុងការបង្កើតសន្តិភាពមិនត្រូវបានទទួលស្គាល់ឲ្យបានគ្រប់គ្រាន់ទេនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ។

ការណ៍នេះអាចបណ្តាលមកពីបញ្ហានៃពហុវិធីសាស្ត្រដើម្បីសន្តិភាពដែលជាពហុភាពមិនទាន់ត្រូវបានផ្សារភ្ជាប់គ្នានៅឡើយ ។ រដ្ឋម្ចាស់ជំនួយ ទីភ្នាក់ងារអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហាក់ដូចជានៅតែគ្មានលទ្ធភាពក្នុងយល់ព្រមទៅលើបញ្ហាដែលថា សន្តិភាពប្រភេទណាទើប "សមស្រប" ។ មធ្យោបាយនៃការកសាងសន្តិភាពនៅតែពេញព្រៀបទៅដោយផលប្រយោជន៍និងការឲ្យនិយមន័យប្រទាំងប្រទើសគ្នា ។ ចំពោះប្រទេសកម្ពុជា សន្តិភាពមានន័យថាជាការរក្សានូវតុល្យភាពអំណាច ។ សហគមន៍អន្តរជាតិនៅតែភ្ជាប់ខ្លួនយ៉ាងមាំទៅនឹង "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ។ សម្រាប់ប្រជាជនកម្ពុជាដែលរហូតមកទល់នឹងពេលថ្មីៗនេះបានឆ្លងកាត់បទពិសោធន៍ "សន្តិភាព" តាមរបៀបទុកការគោរពច្បាប់មួយអន្លើ និងស្វែងរកការការពារពីមេកោយ យល់ថា "សន្តិភាពជាលក្ខណៈប្រជាធិបតេយ្យ" គឺមិនមែនការធ្វើបដិវត្តន៍ឡើយ ។

សូម្បីតែអង្គការមិនមែនរដ្ឋាភិបាលដែលមានទីតាំងនៅភូមិស្រុក ក៏ហាក់ដូចជាទុកមួយអន្លើនូវគំនិតដែលបញ្ចូលសន្តិភាពជាមួយយុត្តិធម៌និងលទ្ធិប្រជាធិបតេយ្យដែរ ។ នៅក្នុងសេចក្តីថ្លែងការណ៍ របស់ក្រុមពិគ្រោះយោបល់ឆ្នាំ២០០២ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា "កន្លងមក សន្តិភាពចេះតែបន្តកើតមាននៅក្នុងប្រទេសនេះ" ។ វាគឺជា "សន្តិភាព" ដែលកើតដោយសារការថយចុះយ៉ាងគំហុកនៃអំពើឃោរឃៅតាមផ្លូវថ្នល់ ។ ក៏ប៉ុន្តែ សន្តិភាពដែលអ៊ុនតាក់ប្រមើលនៅក្នុងទម្រង់ស្ថាប័នសេរីនិយម ប្រជាធិបតេយ្យនិយមមិនទាន់លុបលើគំរូចាស់នៃអំណាចផ្តាច់ការនិងលួនក្រាបនិយមនៅឡើយទេ ។

កម្ពុជា "ឆ្លងកាត់សម័យអន្តរកាល" លឿនហួសហេតុពេក ។

របនាសម្ព័ន្ធនយោបាយបែបប្រជាធិបតេយ្យត្រូវបានយកមកគ្របលើសង្គមកម្ពុជាដោយមិនគិតអំពីផលវិបាកដែលកើតចេញពីការផ្លាស់ប្តូរសង្គមឡើយ ដែលតាមពិតបម្លាស់ប្តូរនេះត្រូវតែកើតមុនគំនិត "សន្តិភាពគឺជាលទ្ធិប្រជាធិបតេយ្យ" ។ ទីភ្នាក់ងារជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលទទួលយកគំនិត "ស្តារសន្តិភាព" ដូចគ្នាទៅនឹង "រិស្សកសន្តិភាព" របស់អង្គការសហប្រជាជាតិដែរគឺ "បែកចាយ" ឥតឈប់ឈរនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែខកខានមិនបានចូលរួមនៅក្នុងដំណើរការកែប្រែសង្គម ។ អ៊ីកណាទីហ្សង្កេតដោយយកចិត្តទុកដាក់ថា ការខកខានមិនបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់ទទួលលទ្ធិប្រជាធិបតេយ្យមានន័យថា "ជំនួយមនុស្សធម៌អន្តរជាតិបានហូរប្រោះទៅតាមខ្សាច់អស់ទៅហើយ" ។

នៅក្នុងការសិក្សាមួយដែលមានចំណងជើងថា "ជំនួយបន្ទាន់ និង ការអភិវឌ្ឍន៍ៈ តស៊ូដើម្បីបណ្តុំសកម្មភាព" អៀនស្មីលី សង្កត់ធ្ងន់ទៅលើភាពពិបាកសម្រេចនូវ "បណ្តុំសកម្មភាព" រវាងជំនួយសង្គ្រោះនិងជំនួយអភិវឌ្ឍន៍រយៈពេលវែង ហើយបានថ្កោលទោសចំពោះការតភ្ជាប់ដំណាក់កាលពីរផ្សេងគ្នា ។ ការិយាល័យមនុស្សធម៌សហគមន៍អឺរ៉ុបបានឲ្យយោបល់ថា "ការគិតអំពីដំណើរទន្ទឹមគ្នារវាងជំនួយនិងការអភិវឌ្ឍន៍" អាចមានលក្ខណៈសមស្របជាជាងទុកឲ្យមួយដើរមុនមួយដើរក្រោយរបៀប "បន្តកន្ទុយគ្នា" ។

គំនិត "ដើរទន្ទឹមគ្នា" រវាងជំនួយសង្គ្រោះនិងការអភិវឌ្ឍន៍គឺជាការបង្កើតបាននូវ "យុទ្ធសាស្ត្រសន្តិភាព" ដែលត្រូវយកមកអនុវត្តពីថ្នាក់មូលដ្ឋានឡើងទៅលើ ល្អជាងការលោតឆ័ត្រពីលើចុះក្រោមដូចជាលក្ខណៈជាក់ស្តែងនៅកម្ពុជា ។ ដើម្បីកុំឲ្យមានអ៊ុនតាក់បែបនេះជាលើកទីពីរទៀត ក៏ដូចជាដើម្បីបង្កើតនូវសន្តិភាពដែលត្រូវបាន "ប្រកាសជាផ្លូវការ" កាលពី១០ឆ្នាំមុន តួអង្គមិនមែនរដ្ឋាភិបាលចាំបាច់ត្រូវចូលរួមឲ្យបានសកម្មនៅក្នុងការធ្វើឲ្យសន្តិភាពក្លាយជាបរិបទសង្គម ។ ការផ្តល់នូវសន្តិភាពតាមរយៈជំនួយមនុស្សធម៌ នឹងផ្តល់ត្រឹមតែ "សន្តិភាពសិប្បនិម្មិតប៉ុណ្ណោះ" ពោលគឺជាជាសន្តិភាពដែលកើតចេញពីរចនាសម្ព័ន្ធប្រជាធិបតេយ្យដ៏ធំប៉ុន្តែមិនសូវប្រជុំប្រសងគ្នាក្នុងចំណោមជំនួយនិងការអភិវឌ្ឍន៍ ដែលជាការគួរឲ្យចង់សើច គឺវាគ្រាន់តែជាការចាត់ចែងតាមបែប "ពិធីការ" ឲ្យល្អមើលតែសំបកក្រៅប៉ុណ្ណោះ ។

**ម៉ារី ឡាប៊ីក**

# ជុំវិញការកាត់ទោស សាដាម ហ៊ូសេន

ភ្លាមៗក្រោយពី សាដាម ហ៊ូសេន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៣ ចេញពីបន្ទប់ក្រោមដី ជាកន្លែងដែលគាត់លាក់ខ្លួនពួនអាត្មាពីការតាមចាប់របស់កងកម្លាំងពិសេសរបស់អាមេរិក ពិភពលោកចាប់ផ្តើមពិភាក្សាថាតើត្រូវធ្វើដូចម្តេចចំពោះរូប សាដាម ហ៊ូសេន ។ ការនាំខ្លួន សាដាម ទៅកាត់ទោសនៅក្នុងតុលាការយុត្តិធម៌មួយជាការចាំបាច់ក្នុងការផ្តល់យុត្តិធម៌ឲ្យពលរដ្ឋអ៊ីរ៉ាក់ទាំងឡាយដែលបានទទួលរងការធ្វើទុក្ខបុកម្នេញពី សាដាម ។ ប៉ុន្តែមានបញ្ហាជាច្រើនពាក់ព័ន្ធនឹងវិធីសាស្ត្រក្នុងការកាត់ទោស សាដាម ។ តើសាដាមត្រូវកាត់ទោសនៅក្នុងតុលាការក្នុងស្រុកឬតុលាការអន្តរជាតិ? កាត់ទោសនៅក្នុងប្រទេសអ៊ីរ៉ាក់ ឬនៅតំបន់អព្យាក្រឹតដូចជាទីក្រុងឡាអេ? តើអង្គការសហប្រជាជាតិគួរជាអ្នកចាត់ចែងការងារកាត់ទោសនេះឬក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ជាអ្នកធ្វើ? ការកាត់ទោសចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានកើតឡើងនៅអ៊ីរ៉ាក់ដ៏មានយុត្តិធម៌និងបំពេញទៅតាមបទដ្ឋានច្បាប់អន្តរជាតិ មានសារសំខាន់ចំពោះជនរងគ្រោះ ហើយនឹងជួយពង្រឹងប្រព័ន្ធច្បាប់នៅក្នុងប្រទេសអ៊ីរ៉ាក់ ដែលជាចំណុចចាប់ផ្តើមនៃយុត្តិធម៌ដែលពុំធ្លាប់កើតមានអស់រយៈពេលបីទសវត្សរ៍មកហើយនៅក្នុងប្រទេសអ៊ីរ៉ាក់ ។ ផ្ទុយទៅវិញ ការកាត់ទោសមិនបានត្រឹមត្រូវនឹងជំរុញឲ្យមានការប្រព្រឹត្តអំពើឃោរឃៅតទៅទៀត និងរារាំងដល់ការ

កសាងធម្មាធិបតេយ្យនៅក្នុងប្រទេសអ៊ីរ៉ាក់ ។

ការដាក់ទោសដោយគ្មានតុលាការមិនមែនជាយុត្តិធម៌ទេ វាគ្រាន់តែជាការសងសឹកប៉ុណ្ណោះ ។ ការដាក់ពន្ធនាគារឬប្រហារជីវិត សាដាម ហ៊ូសេន ដោយមិនមានការកាត់ទោសប្រកបដោយយុត្តិធម៌ គឺជាការបដិសេធយុត្តិធម៌ចំពោះជនរងគ្រោះនិងចំពោះសាដាម ខ្លួនឯង ។

## ឧក្រិដ្ឋកម្មនៃរដ្ឋាភិបាលបាបុរបស់ សាដាម ហ៊ូសេន

តុលាការកាត់ទោស សាដាម ត្រូវតែក្តោបទៅលើរាល់ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរយៈពេល៣៥ឆ្នាំនៃការដឹកនាំរបស់ សាដាម ។ ឧក្រិដ្ឋកម្មទាំងនេះរួមបញ្ចូលទាំងអ្វីដែលបានកើតឡើងនៅក្នុងសង្គ្រាមអ៊ីរ៉ាក់-អ៊ីរ៉ង់ ព្រមទាំងការឈ្លានពាននិងការក្តោបក្តាប់របស់អ៊ីរ៉ាក់ទៅលើប្រទេសគុយវ៉ែត ដែលមានទម្រង់ជាឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប្រទេសអ៊ីរ៉ង់និងគុយវ៉ែតមានសិទ្ធិក្នុងការទាមទារឲ្យនាំយកសាដាមឡើងតុលាការ ប៉ុន្តែផ្នែកសំខាន់នៃការចោទប្រកាន់ សាដាម គឺអំពើឃោរឃៅរបស់ សាដាម នៅលើទឹកដីអ៊ីរ៉ាក់និងទៅលើប្រជាជនអ៊ីរ៉ាក់ ។

រដ្ឋាភិបាលប្រទេសអ៊ីរ៉ាក់ដែលដឹកនាំដោយ សាដាម ត្រូវទទួលខុសត្រូវចំពោះការស្លាប់បាត់បង់ជីវិតប្រជាជនអ៊ីរ៉ាក់ប្រមាណ១ភាគ៤លាននាក់ ។ នៅក្នុងចំណោមសាកសពដែលបានជីកកកាយចេញពីរណ្តៅសពរួមនៅក្នុងប្រទេសអ៊ីរ៉ាក់មកត្រឹមខែធ្នូ ឆ្នាំ២០០៣ មានសំណល់សពជាតិពន្ធុឃើត ចំនួនសែននាក់ដែលបានស្លាប់ដោយការបាញ់ប្រហារនឹងកាំភ្លើងយន្តនិងបំពុលដោយឧស្ម័នគីមី នៅអំឡុងឆ្នាំ១៩៨៨ក្នុងយុទ្ធនាការអាន់ហ្វាល់ ។ ជាតិពន្ធុឃើតទាំងនោះត្រូវបានសម្លាប់ក្រោយពីបានបង្ខំខ្លួនគេចេញពីផ្ទះដោយសារមានការវាយប្រហារដោយអាវុធគីមី ។ ក្នុងរណ្តៅសពរួមនោះ មានជាតិពន្ធុស៊ីតេនិងឃើតដែលត្រូវបានសម្លាប់នៅក្នុងការបះបោរឆ្នាំ១៩៩១ ក្រោយសង្គ្រាមឈូងសមុទ្រពែរ្ស មានជាតិពន្ធុស៊ីតេមួយចំនួនទៀតដែលបានសម្លាប់នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រោមការចោទប្រកាន់ថា បានគាំទ្រប្រទេសអ៊ីរ៉ង់ មានជាតិពន្ធុអារ៉ាប់នៅតំបន់លិចទឹកបានស្លាប់នៅពេលដែលរដ្ឋាភិបាលអ៊ីរ៉ាក់ដណ្តើមយកទឹកដីលិចទឹក និងបំផ្លិចបំផ្លាញចោលវប្បធម៌ដែលបានរក្សាទុកមកអស់រយៈពេលជាច្រើនសតវត្សរ៍ និងមានសាកសពប្រជាជនអ៊ីរ៉ាក់ផ្សេងទៀតដែលបានស្លាប់ដោយសារប្រឆាំងឬត្រូវគេចោទប្រកាន់ថាប្រឆាំងនឹងរដ្ឋាភិបាល សាដាម ហ៊ូសេន ។

## ប្រភេទផ្សេងៗនៃតុលាការនិងតុលាការមុនៗ

មានតុលាការបីប្រភេទដែលអាចត្រូវបានបង្កើតឡើងដើម្បីកាត់ទោសអតីតមេដឹកនាំនៃរដ្ឋាភិបាលក្នុងប្រទេសអ៊ីរ៉ាក់ ។

### ១) តុលាការជាតិចូលរួមដោយព្រះរាជអាជ្ញានិងចៅក្រមជនជាតិអ៊ីរ៉ាក់

ប្រសិនបើអាជ្ញាធរជាតិអាចរៀបចំការកាត់ទោសដែលមានប្រសិទ្ធភាពបានដោយខ្លួនឯងគឺជាករណីដ៏ប្រសើរបំផុត ។ ការកាត់ទោសក្នុងស្រុកអនុញ្ញាតឲ្យជនរងគ្រោះនិងគ្រួសារអាចចូលរួមបានដោយងាយ ។

ជាទូទៅ ការកាត់ទោសព្រហ្មទណ្ឌនៅក្នុងប្រទេសអ៊ីរ៉ាក់ច្រើនតែបានធ្វើឡើងដោយសង្ខេប មានរយៈពេលតែប៉ុន្មានម៉ោងឬយ៉ាងយូរតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។ ជួនកាល បុគ្គលដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋត្រូវបានយកទៅដាក់ពន្ធនាគារដោយមិនបានឡើងតុលាការ ។

អ្នកច្បាប់ជនជាតិអ៊ីរ៉ាក់ ដូចជាចៅក្រម ព្រះរាជអាជ្ញា មេធាវី និងបុគ្គលផ្សេងទៀតនៅក្នុងប្រព័ន្ធតុលាការ មិនមានបទពិសោធន៍ក្នុងដំណើរការក្តីដែលមានលក្ខណៈស្មុគស្មាញដូចករណី សាដាម ហ៊ូសេន និងជនផ្សេងទៀតដែលត្រូវចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរទេ ។

### ២) តុលាការអន្តរជាតិបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ

ក្រោយពីមានអំពើប្រល័យពូជសាសន៍នៅបូស្នៀ និងរ៉ាន់ដា ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចដើម្បីបង្កើត "តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី" និង "តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា" ។ តុលាការទាំងពីរនេះត្រូវបានចូលរួមមួយផ្នែកធំដោយចៅក្រមព្រះរាជអាជ្ញានិងបុគ្គលិកអន្តរជាតិ ។ ដោយមូលហេតុនយោបាយនិងសន្តិសុខ តុលាការទាំងពីរត្រូវ

បានធ្វើឡើងនៅក្រៅប្រទេសដើម ។ "តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី" ធ្វើឡើងនៅទីក្រុងឡាអេវីង"តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា"ធ្វើឡើងនៅក្នុងទីក្រុងអារូស្យាប្រទេសតង់ហ្សានី ។ ការធ្វើដូចនេះបានធ្វើឲ្យជនរងគ្រោះពិបាកចូលរួមនៅក្នុងដំណើរការកាត់ទោស ។ ជាទូទៅ តុលាការទាំងពីរបានដំណើរការយ៉ាងល្អ ប៉ុន្តែត្រូវចំណាយអស់ថវិកាច្រើននិងរយៈពេលយូរ ។

### ៣) តុលាការចម្រុះចូលរួមដោយចៅក្រមជាតិនិងអន្តរជាតិ

ឧទាហរណ៍សំខាន់សម្រាប់តុលាការប្រភេទនេះគឺ"តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន" ដែលធ្វើឲ្យមានដំណើរការដោយចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកជាតិនិងអន្តរជាតិ ។ អ្នកច្បាប់ទាំងនេះកំពុងតែពិនិត្យទៅលើការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិឬច្បាប់សង្គ្រាមធ្វើឡើងក្រោយខែវិច្ឆិកា ឆ្នាំ១៩៩៦ នៅក្នុងសង្គ្រាមស៊ីវិលដ៏រន្ធត់នៅក្នុងប្រទេសសៀរ៉ាឡេអូន ។ តុលាការនេះត្រូវបានរំពឹងថានឹងកាត់ទោសជនជាប់ចោទ២០រូបនៃភាគីធ្វើសង្គ្រាមទាំងអស់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋខាងលើ ។

នៅខែសីហា ឆ្នាំ២០០២ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានចេញដីកាចោទប្រកាន់ប្រធានាធិបតីប្រទេសលីបេរី ឆាល ថេល័រ កំពុងកាន់អំណាចក្នុងឆ្នាំនោះ សម្រាប់តួនាទីរបស់លោកនៅក្នុងជម្លោះប្រទេសសៀរ៉ាឡេអូន ។ ក្រោយមកថេល័រ បានគេចខ្លួនទៅប្រទេសនីហ្សេរីយ៉ា ដែលតាំងពីពេលនោះមកប្រទេសនេះបានបដិសេធបញ្ជូន ថេល័រ ទៅឲ្យតុលាការប្រទេសសៀរ៉ាឡេអូន ។

ទស្សនៈអ្នកច្បាប់ជុំវិញតុលាការកាត់ទោស សាដាម ហ៊ូសេន នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ ក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់បានប្រកាសអំពីការបង្កើត "តុលាការពិសេសនៃប្រទេសអ៊ីរ៉ាក់សម្រាប់បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" ដើម្បីកាត់ទោសប្រជាជនអ៊ីរ៉ាក់ទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មផ្សេងទៀតនៅក្រោមច្បាប់ប្រទេសអ៊ីរ៉ាក់ដែលបានប្រព្រឹត្តឡើងរវាងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៦៨ ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៣ ។ តុលាការនេះត្រូវបានរិះគន់ចំពោះកង្វះការចូលរួមពីសហគមន៍អន្តរជាតិ ការស៊ើបអង្កេតនិងការតែងតាំងបុគ្គលិកគ្មានតម្លាភាព ។

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៤ អង្គការសង្កេតការណ៍សិទ្ធិមនុស្សបានផ្ញើលិខិតពីរច្បាប់ទៅសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស ស្តីអំពីច្បាប់របស់ "តុលាការពិសេសនៃប្រទេសអ៊ីរ៉ាក់សម្រាប់បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" ។

អង្គការសង្កេតការណ៍សិទ្ធិមនុស្សជឿជាក់ថា លក្ខន្តិកៈច្បាប់តុលាការអ៊ីរ៉ាក់ខ្វះខាតបទបញ្ញត្តិសំខាន់ៗមួយចំនួនដើម្បីធានាថាការកាត់ក្តីនឹងត្រូវធ្វើឡើងសមស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិជាមូលដ្ឋាន ។ កង្វះខាតទាំងនោះមានដូចខាងក្រោមៈ

១) លក្ខន្តិកៈច្បាប់របស់តុលាការពិសេសមិនបានធានាឲ្យតុលាការនេះមានសមត្ថភាពគ្រប់គ្រាន់ដូចដែលបានទាមទារដោយមាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ តាមរយៈការមិនចែងថា ចៅក្រមនិងព្រះរាជអាជ្ញាត្រូវមានបទពិសោធន៍ក្នុងរឿងក្តីឧក្រិដ្ឋកម្មស្មុគស្មាញ ឬរឿងក្តីពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ លើសពីនេះ លក្ខន្តិកៈច្បាប់នេះបានហាមប្រាមមិនឲ្យមានការតែងតាំងព្រះរាជអាជ្ញាឬចៅក្រមស៊ើបអង្កេតបរទេសដែលមានបទពិសោធន៍គ្រប់គ្រាន់ឲ្យមកចូលរួមនៅក្នុងរឿងក្តីទាំងនេះទេ ។

២) លក្ខន្តិកៈច្បាប់តុលាការពិសេសមិនបានហាមប្រាមមិនឲ្យមានទោសប្រហារជីវិត ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិដូចបានចែងនៅក្នុងមាត្រាទី៦នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ គាំទ្រដល់ការលុបចោលទោសប្រហារជីវិត ។ ម្យ៉ាងវិញទៀត ការទទួលស្គាល់របស់ប្រទេសជាច្រើនថ្មីៗនេះថាទោសប្រហារជីវិតរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន បានជំរុញឲ្យមានចលនានៅជុំវិញពិភពលោកឲ្យបំបាត់ចោលទោសប្រហារជីវិត ។

៣) លក្ខន្តិកៈច្បាប់តុលាការពិសេសមិនបានធានាឲ្យបាននូវការបង្ហាញថាមានទោសដោយគ្មានវិមតិសង្ស័យ (ពិរុទ្ធត្រូវតែបកស្រាយឲ្យលើសពីការងឿងឆ្ងល់) ។ គណៈកម្មាធិការសិទ្ធិ

មនុស្សអគ្គការសហប្រជាជាតិបានថ្លែងនៅក្នុងយោបល់ទូទៅរបស់ខ្លួនទៅលើមាត្រាទី១៤ ចំណុចទី៧នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយថា "តាមហេតុផលនៃការសន្និដ្ឋានជាមុនថាគ្មានទោស ការបង្ហាញភ័ស្តុតាងគាំទ្រការចោទប្រកាន់ជាបន្ទុករបស់ភាគីដើមចោទ ហើយចុងចោទអាចទទួលប្រយោជន៍ពីការងឿងឆ្ងល់ (ប្រយោជន៍ពីភាពមិនដាច់ស្រេច) ។ គ្មានអំពើពិរុទ្ធណាមួយអាចត្រូវបានប្រកាសទេ លុះត្រាតែការចោទប្រកាន់ត្រូវបានបកស្រាយបញ្ជាក់ដោយគ្មានវិមតិសង្ស័យ" ។

៤) លក្ខន្តិកៈច្បាប់តុលាការពិសេសបានអនុញ្ញាតឲ្យយកច្បាប់និងនីតិវិធីព្រហ្មទណ្ឌអ៊ីរ៉ាក់ទៅបំពេញឲ្យទ្រឹស្តីច្បាប់ព្រហ្មទណ្ឌការទទួលខុសត្រូវរបស់បុគ្គលចំពោះបទឧក្រិដ្ឋនិងការទទួលទណ្ឌកម្ម ដែលមិនបានរៀបរាប់នៅក្នុងលក្ខន្តិកៈច្បាប់តុលាការពិសេស ។ ច្បាប់ប្រទេសអ៊ីរ៉ាក់មានបញ្ញត្តិដែលខុសនឹងបទដ្ឋានអន្តរជាតិ ឧទាហរណ៍ដូចជាការអនុញ្ញាតឲ្យមានការសារភាពដោយបង្ខំ និងការមិនឲ្យមានវត្តមានមេធាវីក្នុងពេលសួរចម្លើយនៅក្រោមកាលៈទេសៈខ្លះ ។

បញ្ញាជនមួយចំនួនពោលថា អ្វីដែលបានកើតឡើងនៅក្នុងប្រទេសអ៊ីរ៉ាក់មិនប្រាកដថាជាបញ្ហារបស់អ៊ីរ៉ាក់ ហើយត្រូវដោះស្រាយដោយច្បាប់អ៊ីរ៉ាក់តែមួយនោះទេ ។ នៅក្រោមច្បាប់អន្តរជាតិ អំពើឃោរឃៅរបស់អ៊ីរ៉ាក់ជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ រួមទាំងអំពើប្រល័យពូជសាសន៍ផងដែរ ទោះបីជាអំពើប្រល័យពូជសាសន៍ជាអំពើមួយដែលពិបាកនឹងបង្ហាញឲ្យឃើញបន្តិចតាមរយៈបទបញ្ញត្តិនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍ក៏ដោយ ។

ទោះបីជាតុលាការកាត់ទោស សាដាម មានទម្រង់យ៉ាងណាក៏ដោយ តុលាការនោះត្រូវតែមើលឃើញថាមានភាពយុត្តិធម៌និងមានតម្លាភាព ។ មានន័យថា ទោះបីតុលាការនោះត្រូវធ្វើឡើងនៅទីណានិងដោយនរណា តុលាការនោះត្រូវបង្កើតឡើងឲ្យបានត្រឹមត្រូវនិងមាននីតិវិធីបំពេញទៅតាមលក្ខខណ្ឌច្បាប់អន្តរជាតិ ។ សិទ្ធិមានដំណើរការច្បាប់ត្រឹមត្រូវរបស់បុគ្គលម្នាក់ដែលផ្តល់ដោយកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយអនុម័តឆ្នាំ១៩៦៦ ត្រូវតែគោរព ។

អ្នកខ្លះផ្តល់យោបល់ថា ការកាត់ទោស សាដាម គួរធ្វើឡើងនៅក្នុងតុលាការអន្តរជាតិ ប៉ុន្តែមិនមែនតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ពីព្រោះតុលាការនេះពុំមានសមត្ថកិច្ចកាត់ទោស ។ ប្រទេសអ៊ីរ៉ាក់មិនបានផ្តល់សច្ចានុម័តដល់លក្ខន្តិកៈច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិទេ ទោះបីជាបានផ្តល់ ក៏មាត្រាទី១១នៃលក្ខន្តិកៈនោះបានហាមប្រាមតុលាការព្រហ្មទណ្ឌអន្តរជាតិមិនឲ្យប្រើប្រាស់ច្បាប់របស់ខ្លួនកាត់ទោសឧក្រិដ្ឋកម្មទាំងឡាយដែលបានធ្វើឡើងមុនពេលលក្ខន្តិកៈនោះមានសុពលភាពកាលពីឆ្នាំ ២០០២ ។ តុលាការអន្តរជាតិផ្សេងៗទៀតក៏គ្មានសមត្ថកិច្ចដែរ ដូច្នេះតុលាការពិសេសថ្មីមួយត្រូវតែបង្កើតឡើងសម្រាប់ប្រទេសអ៊ីរ៉ាក់ ។

សហគមន៍សិទ្ធិមនុស្សអន្តរជាតិមិនគាំទ្រតុលាការដែលបង្កើតឡើងដោយប្រទេសអ៊ីរ៉ាក់ខ្លួនឯងទេដែលព្រួយបារម្ភថាវាអាចក្លាយជា"ការកាត់ទោសមានតែរូប" ហើយ សាដាម អាចត្រូវកាត់ទោសប្រហារជីវិត ។

ក្រុមប្រឹក្សាសន្តិសុខអគ្គការសហប្រជាជាតិមានអំណាចបង្កើតតុលាការថ្មីមួយសម្រាប់កាត់ទោស សាដាម តាមទម្រង់ដូចគ្នាទៅនឹងការកាត់ទោស ស្លូបូដាន់ មីឡូសឺវិក និងអតីតមេដឹកនាំអំពើប្រល័យពូជសាសន៍នៅរវ៉ាន់ដា ។ ជម្រើសនេះមានការទាក់ទាញជាងជម្រើសផ្សេង ។

មានការជំទាស់ទៅលើមតិខាងលើ ។ សាដាម ត្រូវតែទទួលការចោទប្រកាន់ដំបូងបង្អស់ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសអ៊ីរ៉ាក់ ហើយចំពោះការចោទប្រកាន់បែបនោះ ការកាត់ទោសនៅក្នុងប្រទេសមានភាពសមស្របជាង ។ តុលាការសម្រាប់ប្រទេសរវ៉ាន់ដាត្រូវទទួលការរិះគន់យ៉ាងធ្ងន់ធ្ងរចំពោះការចំណាយពេលវេលាកាត់ទោសយូរពេក ចំពោះការកាត់សេចក្តីទៅលើឧក្រិដ្ឋកម្មតែមួយផ្នែកតូចនៃអ្វីដែលបានកើតឡើងនៅក្នុងអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ និងចំពោះការទីតាំងនៅក្រៅប្រទេសដែលឆ្ងាយពីប្រជាជនរវ៉ាន់ដា ។ ហេតុនេះ ប្រសិនបើការកាត់ទោស សាដាម នឹងត្រូវធ្វើឡើងដើម្បីឲ្យមានការធូរស្បើយក្នុងអារម្មណ៍ដល់ប្រជាជនអ៊ីរ៉ាក់ ការកាត់ទោសនោះគួរតែធ្វើឡើងនៅក្នុងប្រទេសអ៊ីរ៉ាក់ប្រសិនបើអាចធ្វើទៅបាន

ប៉ុន្តែមិនមែនមានន័យថាត្រូវតែកាត់ទោសត្រឹមតែបទល្មើសដែលមានចែងនៅក្នុងច្បាប់ប្រទេសអ៊ីរ៉ាក់នោះទេ ពីព្រោះ «តុលាការពិសេសនៃប្រទេសអ៊ីរ៉ាក់សម្រាប់បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ» មានសមត្ថកិច្ចលើបទឧក្រិដ្ឋមួយចំនួនដែលមានចែងនៅក្នុងច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ចំណុចសំខាន់បំផុតដែលត្រូវពិចារណានោះគឺថា វាមិនមែនត្រឹមតែជាសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែជាការទទួលខុសត្រូវរបស់រដ្ឋនីមួយៗក្នុងការប្រើប្រាស់អំណាចព្រហ្មទណ្ឌរបស់ខ្លួនទៅលើបទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិដែលប្រព្រឹត្តឡើងដោយពលរដ្ឋរបស់ខ្លួន ។ នេះគឺជាកត្តាចម្បងនៃអធិបតេយ្យភាពជាតិ ។

ប្រាកដណាស់ ការកាត់ទោសនៅក្នុងប្រទេសអ៊ីរ៉ាក់ពិតជាមានបញ្ហា ។ ប្រព័ន្ធយុត្តិធម៌របស់ប្រទេសអ៊ីរ៉ាក់គ្មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការកាត់ទោសបែបនេះ ។ ក្រោយពីបានបង្កើតតុលាការសម្រាប់ប្រទេសរវ៉ាន់ដានិងអតីតយូហ្គោស្លាវី យើងដឹងថា ការកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចជាការងារមួយដ៏ស្មុគស្មាញដែលទាមទារឲ្យអ្នកច្បាប់ទទួលបន្ទុកមានជំនាញនិងបទពិសោធន៍ខ្ពស់ ។ ហេតុនេះ ការទាមទារឲ្យមានយុត្តិធម៌ក្នុងការកាត់ក្តីត្រូវតែធានាឲ្យបានតាមមធ្យោបាយផ្សេងដូចជាការចូលរួមពីសហគមន៍អន្តរជាតិជាដើម ។ ទោសប្រហារជីវិតដែលបានដកចេញពីច្បាប់អ៊ីរ៉ាក់ដោយអាជ្ញាធរសម្ព័ន្ធមិត្តបណ្តោះអាសន្នតែអាចអនុម័តមកវិញដោយរដ្ឋាភិបាលអ៊ីរ៉ាក់ថ្មីអាចជាបញ្ហាមួយនៃនីតិវិធីច្បាប់នៃតុលាការកាត់ទោស សាដាម ហើយអាចរារាំងមិនឲ្យរដ្ឋមួយចំនួនចូលរួម ។ ប្រសិនបើបញ្ហាទាំងប៉ុន្មានខាងលើត្រូវបានជម្នះការកាត់ទោសនៅក្នុងប្រទេសអ៊ីរ៉ាក់ នឹងនាំមកនូវយុត្តិធម៌និងផ្តល់ឱកាសឲ្យប្រទេសអ៊ីរ៉ាក់ធ្វើដំណើរទៅមុខឆ្ងាយពីអតីតកាលរបស់ខ្លួន ។

### ការវិវត្តន៍ក្រោយៗទៀត

សាឡិម ឆាឡាប៊ី អាយុ៤១ឆ្នាំត្រូវបានតែងតាំងដោយក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ឲ្យដឹកនាំការងារតុលាការ ។ ឆាឡាប៊ី ពោលថា ជនជាតិអ៊ីរ៉ាក់ប្រមាណ១០០ទៅ២០០នាក់ដែលជាសមាជិកនៃរបបផ្តាច់ការរបស់ សាដាម ដែលបានដឹកនាំប្រទេសអស់រយៈពេល៣៨ឆ្នាំ អាចត្រូវនាំឡើងតុលាការ ។ ឆាឡាប៊ីបានទទួលការអប់រំនៅសាកលវិទ្យាល័យយែលសហរដ្ឋអាមេរិកខាងផ្នែកច្បាប់មនុស្សធម៌អន្តរជាតិនិងហិរញ្ញវត្ថុ ។ ឆាឡាប៊ី ជាសមាជិកគណៈមេធាវីនៅទីក្រុងញូវយ៉ក និងជាក្មួយរបស់ អាម៉ាត់ ឆាឡាប៊ី ដែលជាសមាជិកមួយរូបនៃក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ ។

សាឡិម ឆាឡាប៊ី បានបញ្ជាក់ថា ជនសំខាន់មួយរូបដែលអាចនាំឡើងតុលាការមុនគេ គឺបងប្អូនជីដូនមួយរបស់ សាដាម ឈ្មោះ អាលី ហាស់សាន់ អាល់ម៉ាជីឌ (ហៅក្រៅថា អាលីអាវុធគីមី) ដែលបានដឹកនាំយុទ្ធនាការអាន់ហ្វាល់ឆ្នាំ១៩៨៨ ប្រឆាំងជាតិពន្ធុឃើត ដែលមានមនុស្សរាប់ពាន់នាក់បានស្លាប់ដោយសារអាវុធគីមី ។

ថវិកាសម្រាប់ចំណាយទៅលើការងារតុលាការអ៊ីរ៉ាក់មានចំនួន៧៥លានដុល្លារសម្រាប់ឆ្នាំ២០០៤-០៥ ។

ហ្សាក់ វែរហ្សែស អាយុ៨០ឆ្នាំ បានថ្លែងថា ក្មួយរបស់ សាដាម ហ៊ូសេន ឈ្មោះ អាលី អាល់ទីក្រីទី បានសរសេរសំបុត្រផ្តល់សិទ្ធិឲ្យគាត់ការពារក្តី សាដាម ហ៊ូសេន ។ មេធាវីជនជាតិបារាំងរូបនេះបានការពារក្តីឲ្យ ស្លូបូដាន់ មីឡូសវិក, ខ្មែរ បាប៊ី (មន្ត្រីណាហ្ស៊ីក្នុងសង្គ្រាមលោកលើកទីពីរ) និងមេដឹកនាំភេរវករ កាឡូស ឌឹ ចេកកាល់ ។ ហ្សាក់ ពោលថា «ប្រសិនបើមានឧក្រិដ្ឋកម្មសង្គ្រាមកើតឡើងនៅក្នុងប្រទេសអ៊ីរ៉ាក់ លោក ដូណាល់ រ៉ាំស្វែល (រដ្ឋមន្ត្រីក្រសួងការពារជាតិអាមេរិក) ក៏ពាក់ព័ន្ធដែរ ។ ដូណាល់ រ៉ាំស្វែល គួរតែនាំឡើងតុលាការដូច សាដាម ហ៊ូសេន ដែរ ។ ហ្សាក់ លើកពីសំណួរដែលពាក់ព័ន្ធសម័យមុនសង្គ្រាមឈូងសមុទ្រពែរ្សដែលមានអំពើឃោរឃៅធ្ងន់ធ្ងរជាងគេកើតឡើងក្រោមអំណាច សាដាម ហ៊ូសេនថា «នៅពេលដែលលោកខាងលិចជំរុញឲ្យ សាដាម វាយលុកចូលប្រទេសអ៊ីរ៉ង់ តើ សាដាម ទទួលអាវុធពីណាមក?»

កាលបរិច្ឆេទច្បាស់លាស់នៃការកាត់ទោសមិនទាន់ត្រូវបានកំណត់នៅឡើយទេ ។

***សំយោគចេញពីអត្ថបទសារព័ត៌មានដោយ អេង កុកថាយ***

ហ

# ស្រមោលបង

**(តចប់)**

**តំបន់បី**

ពេលនោះដោយសារអត់ឃ្លានខ្លាំងពេក ប្រជាជន១៧មេសាជាច្រើនក៏បាននាំគ្នាលួចរត់ទៅតំបន់បី ព្រោះឮថាទីនោះសម្បូរបាយហូបណាស់ (ខ្ញុំនៅតំបន់ប្រាំ) ។ ខ្លះទៅបានបី-បួនថ្ងៃក៏លួចមកប្រាប់គ្នាឯងដែលអត់ឃ្លានដូចគ្នាឲ្យរត់ទៅដែរ ។ ប្ដីនាងខ្ញុំដែលមានគំនិតចង់តែធ្វើទេសចរគ្រប់ទិសទីបានបបួលខ្ញុំរត់ទៅនឹងគេដែរ ព្រោះគាត់មានគំនិតចង់រកឪពុកម្ដាយរបស់គាត់ ។ ខ្ញុំក៏យល់ព្រមតាម ។ យប់នោះក្រោមពន្លឺខែព្រាលៗ យើងអង្គុយជុំគ្នាជាមួយអ្នកនៅក្នុងផ្ទះទាំងអស់គ្នា ។ បងស្រីម៉ែអាទូនិងប្អូនស្រី សូដា បានឲ្យពរជ័យដល់គ្រួសារខ្ញុំជាលើកចុងក្រោយ ។ ប្អូនស្រីសូដា ដែលជាមនុស្សមិនសូវនិយាយស្ដីតែមានចិត្តរឹងដូចថ្មបាននិយាយថា «បងហួត និង បងណាង ថ្ងៃណាមួយយើងនឹងជួបគ្នានៅភ្នំពេញម្ដងទៀតមែនទេ?» ។ ខ្ញុំងក់ក្បាលទាំងរលីងរលោងទឹកភ្នែក ។ យប់នោះយើងអង្គុយជជែកគ្នាចង់ទល់ភ្លឺ ។ ព្រលឹមស្រាង មេឃមិនទាន់ភ្លឺមែនទែន ប្ដីប្រពន្ធខ្ញុំនិងកូនបានចេញដំណើរ ។ បងស្រី ម៉ែអាទូ បានឱបខ្ញុំនិងកូនភ័ក្រ្ដខ្ញុំយំ ហើយនិយាយថា «យើងជួបគ្នាទៀតមែនទេ?» ខ្ញុំឱបអ្នកទាំងអស់គ្នាទាំងមិនអស់ចិត្ត ។ ប្ដីខ្ញុំលីចបដែលគាត់ស្រលាញ់ជាងអ្វីទាំងអស់ ខ្ញុំទូលកញ្ជើដាក់ខោអាវចាស់ៗពីរ-បីកំប្លេ ហើយចេញដំណើរបន្ទំជាមួយគេចេញទៅលើកទំនប់ដែរ ។ (នៅឆ្នាំ១៩៨២ខ្ញុំបានជួបបងស្រី ម៉ែអាទូ ។ គាត់ធ្វើការនៅក្រសួងជាមួយ ។ កូនប្រុសទាំងពីររបស់គាត់ជិតពេញកម្លោះហើយ ។ វាមានរូបរាងសាច់ឈាមស្រស់ថ្លាល្អណាស់ ពុំដូចកាលនៅក្នុងរបបអាវខ្មៅទេ ។ បងស្រីបាននិយាយដោយសើចផងថា «មានគេចង់បានខ្ញុំច្រើនណាស់ តែអាប្ដីពីរនាក់នេះ (កូនប្រុសទាំងពីររបស់គាត់) វាឃាឃាំងខ្ញុំជាប់ ។» គាត់ច្រៀងបទ «សំបុត្រក្រោមខ្នើយ» ឲ្យខ្ញុំស្ដាប់ ។ ឥឡូវខ្ញុំពុំដែលបានជួបគាត់ទេ ប្រហែលជាគាត់ចេញទៅក្រៅបាត់ហើយ ។)

គ្រួសារខ្ញុំដើរបានប្រហែលពីរគីឡូម៉ែត្រពីភូមិក៏មកដល់ស្ទឹងមួយ ។ យើងឆ្លងស្ទឹងនោះដែលមានជម្រៅត្រឹមក្បាលជង្គង់ប៉ុណ្ណោះ (ក្នុងខែប្រាំង) ។ មកដល់តំបន់បីហើយ ។ នៅទីនោះដើមឈើដើមព្រៃស្រស់ញញឹមល្អណាស់ សូម្បីតែវាលស្មៅក៏ខៀវស្រងាត់ដែរ ។ ខ្ញុំស្ទើរតែពុំហ៊ានដើរជាន់វាលស្មៅអស់នោះ ព្រោះវាមានត្រកួននិងផ្ទីល្អពេក ដែលនៅតំបន់ខ្ញុំពុំសូវមានសោះ ។

ថ្ងៃជិតត្រង់ទៅហើយ គ្រួសារខ្ញុំដើរដល់ភូមិមួយ ។ កូនប្រុសខ្ញុំចង់យំព្រោះវាឃ្លានបាយពេក ។ ខ្ញុំដាច់ចិត្តចូលទៅភូមិនោះ ហើយសំដៅទៅរោងបាយសុំបាយគេបានមួយចានស្រួបសម្លប្រហើរហើយជាស្រេច ។ យើងក៏ញាំម្នាក់មួយស្លាបព្រាហើយសល់ប៉ុន្មានហុចឲ្យកូនប្រុសខ្ញុំ ។

គ្រួសារខ្ញុំបានចូលទៅសុំគេជ្រកនៅក្នុងភូមិនោះតែម្ដងតែគេមិនទទួល ព្រោះគេថាបួន-ប្រាំថ្ងៃមុនគេទទួលជប់គ្រួសារហើយទៅមុខទៀតទៅ ។ គ្រួសារខ្ញុំក៏បន្តដំណើរទៅមុខទៀតទៅដល់ភូមិណាក៏គេមិនទទួល ព្រោះគ្រប់ចំនួនហើយ ។ យើងចូលដល់ភូមិទីប្រាំពេលល្ងាចជិតយប់ទៅហើយ ។ ប្រធានភូមិមើលយើងលើ-ក្រោមៗ ហើយក៏ព្រមទទួលឲ្យនៅ ហើយប្រាប់ថាខំប្រឹងធ្វើការណា៎ ។

ចូលដល់ក្នុងភូមិ គេប្រគល់កូនខ្ទមស្លឹកមួយឲ្យនៅ ហើយស្អែកឡើងយើងក៏ត្រូវចេញទៅលើកទំនប់នៅក្រៅភូមិភ្លាម ។ អ្នកស្រុកភូមិអស់នោះគេមានសាច់ឈាមល្អណាស់ ។ ពួកគេមើលយើងដោយការអាណិតអាសូរ ព្រោះយើងមានក្បាលជង្គង់ធំជាងខ្លួន ហើយមានទឹកមុខស្លេកស្លាំងរកឈាមគ្មាន ។ នាងខ្ញុំនិងអ្នកមកដល់ថ្មីទាំងអស់ខំធ្វើការណាស់ ។ យើងបានហូបឆ្អែតមានកម្លាំង អ្នកមូលដ្ឋានក៏ចិត្តល្អនឹងយើង ។ មានបងស្រីអ្នក

មូលដ្ឋានម្នាក់រាងស្គមខ្ពស់ ទឹកមុខរួសរាយ លួចខ្សឹបប្រាប់ខ្ញុំថា នៅទីនេះគេមិនធ្វើបាបប្រជាជនអីទេ គេគ្រាន់តែយកទៅរៀនសូត្រប៉ុណ្ណោះចំពោះអ្នកខ្ជិលនិងអ្នកប៉ិនតវ៉ា ។ ទៅទីណាខ្ញុំឮសូរពាក្យ“រៀនសូត្រ”ខ្ញុំព្រឺក្បាលខ្វាក ។

ប្តីសម្លាញ់និងកូនប្រុសខ្ញុំក៏មានសាច់ឈាមស្រស់វិញ ។ កូនប្រុសខ្ញុំអាចរត់លេងប្រឡែងនឹងក្មេងដទៃទៀតសើចឮៗបាន ដែលខ្ញុំមិនដែលបានឃើញសោះតាំងពីមុនមក ។ គ្រួសារខ្ញុំនៅទីនោះ បានមួយខែគត់ពេញដោយសេចក្តីសុខបរិបូណ៌ ។ ថ្ងៃនេះពេលហូបបាយល្ងាចទៅហើយ សមមិត្តនារីម្នាក់អាយុប្រហែល ៣០ឆ្នាំបានប្រាប់ពួកយើងថា “បងប្អូនអ្នកថ្មីទាំងអស់ហូបបាយហើយទៅប្រជុំនៅជិតផ្ទះបងប្រធានភូមិ” ។ បាយរួចនាងខ្ញុំនិងអ្នកថ្មីទាំងអស់ ប្រហែល២០គ្រួសារបានដើរទៅផ្ទះប្រធានភូមិដែលនៅជិតរោងបាយ ។ ចំណែកឯប្តីខ្ញុំគាត់គ្រុនបី-បួនថ្ងៃហើយពុំបានមកហូបបាយទេ ។ ខ្ញុំបានសុំបាយគេយកទៅជូនគាត់ ។ ពួកយើងទាំងអស់គ្នាអង្គុយផ្ទាល់ដីមុខផ្ទះប្រធានភូមិ ។ ប្រធានភូមិគឺសមមិត្ត កាន ដែលមានសម្បុរខ្មៅឃ្មឹក សក់រួញភ្នែកធំៗ ចាប់ផ្តើមបើកអង្គប្រជុំ ។ ជាដំបូងសមមិត្តបានថ្លែងអំណរគុណដល់ពួកយើងអ្នកថ្មីដែលបានមកជួយបង្កបង្កើនផលដល់ភូមិនេះ (ខ្ញុំភ្លេចឈ្មោះភូមិទៅហើយ) ។ ពួកយើងបុកពោះគ្រប់គ្នាយល់ថាមានហេតុមិនល្អហើយ ។ “សមមិត្តដែលនៅភូមិចាស់របស់បងប្អូនទាំងអស់គ្នាបានមកស្នើសុំយកបងប្អូនទាំងអស់ត្រឡប់ទៅជួយធ្វើស្រែនៅខាងណោះវិញ ព្រោះមិត្តរត់ចោលភូមិឡើងស្ងាត់អស់” ។ ពួកយើងទាំងអស់គ្នាស្ទុះដង្ហើមគ្រប់ៗគ្នាឡើងបែកញើសជោកខ្លួនទាំងមេឃត្រជាក់ល្ហឹម ។ ប្រធានភូមិបន្តថា “ហេតុនេះបងប្អូនរៀបចំអីវ៉ាន់ឲ្យហើយទៅស្អែកឡានគេមកដឹកទៅវិញ ហើយគេមិនឲ្យដើរទៅវិញទេ” ។

ខ្ញុំបានមកខ្ទមវិញហើយនិយាយរឿងនេះប្រាប់ប្តីខ្ញុំ ។ គាត់ថា គេមិនមែនឲ្យយើងទៅនៅកន្លែងដដែលវិញទេ ។ ស្អែកឡើងពួកយើងលាអ្នកភូមិចាស់ទាំងអស់ ហើយខ្ញុំរែកអីវ៉ាន់ដែលមានភួយមុងជារបស់ដែលអ្នកមូលដ្ឋានចាស់ៗគេឲ្យពេលមកដល់ភ្លាម ។ ចំណែកប្តីខ្ញុំវិញដើរយោងតែអាត្មាពុំចង់រួចផង ព្រោះគាត់គ្រុនប៉ុន្មានថ្ងៃហូបបាយពុំបាន គាត់លីតែចបមួយពុំចង់រួច ។ ពួកយើងអ្នកថ្មីទាំងអស់គេប្រមូលឲ្យទៅវិញមានចំនួនច្រើនគួរសមដែរ ។ យើងដើរប្រហែលកន្លះគីឡូម៉ែត្រក៏មកដល់ផ្លូវធំហើយមានឡានកាំមីញ៉ុងប្រហែល១០ឡាននៅចាំយើងជាស្រេច ។ ខ្ញុំដើរលឿនៗប្រញាប់មុនគេន្ទាលនឹងទៅរកកន្លែងល្អអង្គុយ ចំណែកប្តីខ្ញុំដើររញីរញ៉ូរមិនទាន់មកដល់ ។ មិត្តផលប្រធានក្រុមខ្ញុំដែលស្គាល់ខ្ញុំច្បាស់ បានស្តីឲ្យខ្ញុំថា មិត្តណាងឯងប្រញាប់ទៅណា? មិនឃើញមិត្តហួត (ប្តីខ្ញុំ) កំពុងតែឈឺទេឬ? នៅចាំក្នុងផ្ទះគំរូនេះហើយ ចាំឡានត្រឡប់មកវិញមួយជើងទៀតទៅ ។ ខ្ញុំក៏ចូលសម្រាកក្នុងផ្ទះគំរូនៅចិញ្ចើមផ្លូវដែលគេធ្វើដូចៗគ្នា ។ ប្តីខ្ញុំទម្លាក់ខ្លួនសម្រាកក្នុងផ្ទះគំរូ ហើយរអ៊ូដាក់ខ្ញុំថា “ដឹងជាប្រញាប់អី ខ្ញុំឈឺក្បាលចង់ងាប់” ។ ខ្ញុំលូកយកថ្នាំឲ្យគាត់លេប គឺគ្មានអ៊ីក្រៅពីថ្នាំអាចម៍ទន្សាយទេ ។

យើងទាំងអស់ គ្នានៅចាំរហូតដល់ម៉ោងពីរថ្ងៃ ទើបឡានត្រឡប់មកយកពួកយើងមួយជើងក្រោយទៀត ។ យើងជិះនៅលើឡានឃ្លានបាយគ្រប់ៗគ្នា ។ មិត្តឈ្លបក្មេងៗពីរនាក់ឈរនៅជិតខ្ញុំក្នុងឡានបាននិយាយប្រាប់ពួកយើងថា “មិត្តដឹងទេ ពួកទៅព្រឹកមិញយើងយកទៅទ្រាប់គល់ជញ្ជ្រាំងអស់ហើយ” ។ កាលនោះខ្ញុំមិនបានចាប់អារម្មណ៍នឹងពាក្យនេះ ស្មានតែភូមិគេឈ្មោះគល់ជញ្ជ្រាំង ។ ដឹងអីគឺគេយកទៅវាយចោលសោះ (ក្រោយមកទើបខ្ញុំដឹង) ។ ប្រហែលម៉ោងប្រាំល្ងាច ឡានបានដឹកពួកយើងយកមកដល់សិរីសោភ័ណ ។ ផ្ទះរាប់សិបល្វែងស្ងាត់ឈឹងនៅទំនេរគ្មានមនុស្សនៅ ។ គេប្រាប់ឲ្យពួកយើងចូលសម្រាកផ្ទះណាក៏បាន ចាំបន្តិចទៀតគេហៅទៅហូបបាយ ។ ផ្ទះធំល្វឹងល្វើយគ្មានមនុស្សនៅ គ្មានតុទូអ្វីទាំងអស់មានតែក្រង់ស្បូវនៅពេញផ្ទះ ពួកយើងអង្គុយអាណោចអាធ័មដល់ម្ចាស់ផ្ទះ (ទាំងអស់នេះមានវាសនាដូចពួកយើងដែរក៏មិនដឹង) ។ ក្រុមខ្លះជជែកគ្នាថា ពុំដឹងគេយកពួកយើងទៅប្រឡាក់ងៀតអីទេដែលនាំគ្នារត់ចោលស្រុកដូច្នេះ ។ ល្ងាចងងឹតបន្តិច ហើយមានសមមិត្តស្រី-ប្រុសពីរ-បីនាក់បានដើរហៅពួកយើងទៅហូបបាយ ។ ក្នុងរោងបាយឈើប្រក់ស័ង្កសីក្រោមពន្លឺចង្កៀងមុាំងសុងដែលយើងខានឃើញជាយូរមកហើយ ។ បាយអង្ករសក្បុសដូចសំឡី សម្លម្ជូរដើមចេកឆ្ងាញ់អើយសែនឆ្ងាញ់ ។ ណាអត់បាយតាំងពីព្រឹកម្ល៉េះ ម្នាក់ៗកាយ

យកៗម៉ាចាស់ដៃ ម៉ាណែនក្រពះ បំណាច់ឃ្លានយូរហើយ ។ ក្រោយពេលបាយរួច គេអនុញ្ញាតឲ្យពួកយើងដួសបាយយក ស្រេចតែចិត្តប្រកបូលកូនឆ្នាំង កូនធុងយួរតូចៗ ដើម្បីទុកហូបតាមផ្លូវនៅវេលាព្រឹកស្អែក ។ មកដល់កន្លែងវិញ យើងចេះតែពិចារណាថា ប្រហែលបានហូបឆ្អាញ់ជាចុងក្រោយក៏មិនដឹង ។

## ទឹកដោរ អន្លង់មរណៈប្ដីខ្ញុំ

ព្រឹកព្រលឹមឡើង មេឃភ្លឺព្រាលៗឯចុងស្រែ សន្សើមនៅធ្លាក់នៅឡើយ ។ យើងត្រូវគេបញ្ជាឲ្យឡើងឡានដដែលពីម្សិលមិញទៀតដោយប្រញាប់ប្រញាល់ ។ ឡានបរទៅហើយតាមផ្លូវកៅស៊ូ យើងពុំដឹងថាជាផ្លូវណាទៅផ្លូវណាទេ ។ មានតែបងប្រុសម្នាក់គត់ស្រែកថា ដល់ផ្លូវបត់ចូលភូមិចាស់យើងហើយ តែឡាននៅតែបន្តដំណើរទៅមុខទៀត ។ លាហើយភូមិដើងវត្តស្រុកព្រះនេត្រព្រះ ពុំដឹងជាគេយកពួកយើងទៅដល់ណាទេ ។ រហូតដល់ថ្ងៃត្រង់ទើបឡានឈប់ត្រង់ផ្លូវលំតូចមួយ ។ សមមិត្តក្មេងៗប្រុស-ស្រីប៉ុន្មាននាក់បញ្ជាឲ្យពួកយើងចុះ ។ ខ្លះរែក ខ្លះទូលដើរសំដៅទៅភូមិមួយមានចម្ងាយ១០០ម៉ែត្រ ដែលយើងមើលឃើញតាំងពីផ្លូវធំទៅម្ល៉េះ ។ ខ្ញុំត្រូវរែកអីវ៉ាន់បន្តិចបន្តួចជំនួសប្ដីខ្ញុំដែលគ្មានកម្លាំងកំហែងបន្តិចសោះក្នុងខ្លួន ។ កូនប្រុសខ្ញុំដើរតាមពីក្រោយដោយយួរកូនឆ្នាំងដាក់បាយផង ។ ណាដងរែកវ៉ាកប់ស្មាខ្ញុំឈឺពេករែកបណ្ដើរខ្ញុំយំបណ្ដើរ ។ ប្ដីខ្ញុំមួម៉ៅក្នុងចិត្តណាស់ពេលឃើញខ្ញុំយំ ។ គាត់រអ៊ូថា "យំស្អីមិនទាន់ព្រាត់ប្រាសគ្នាផង" ខ្ញុំរឹតតែយំខ្លាំងឡើង ហើយដូចជាមានប្រផ្នូលក្នុងចិត្តថាមិនស្រួល ព្រោះរស់នៅកម្សត់កម្រនឹងគ្នាជិតបីឆ្នាំហើយគាត់ពុំដែលមានពាក្យទ្រគោះបោះបោកឲ្យខ្ញុំដូចពេលនេះសោះ ។ យើងទាំងអស់គ្នាដើរដល់ភូមិមួយ គេឲ្យយើងចូលសម្រាកក្នុងសាលាសំណាក់មួយ ។ ប្រហែលកន្លះម៉ោងក្រោយមក មានសមមិត្តប្រុសៗពីរ-បីនាក់ដើរចូលមក ។ សមមិត្តម្នាក់អាយុប្រហែលហាសិបឆ្នាំ សក់ល្បាយអាចម៍ខ្លា ភ្នែកធំ បៀមបារីស្លឹកសង្កែ ហើយមានមិត្តនារីក្មេងៗបួនប្រាំនាក់ទៀតដើរអមមកជាមួយ ។ យើងអង្គុយតម្រៀបគ្នាដើម្បីស្ដាប់សមមិត្តអាយុជាង៥០ឆ្នាំនេះនិយាយ ។

សមមិត្តនិយាយដោយទឹកមុខមាំថា "បងប្អូនទាំងអស់គ្នាត្រូវមកនៅទីនេះ ទីនេះឈ្មោះភូមិទឹកដោរ ។ បងប្អូនត្រូវកសាងខ្លួន រៀបចំសតិអារម្មណ៍ឲ្យបានល្អឡើងវិញឲ្យអង្គការឃើញ ព្រោះបងប្អូនមានកំហុសធ្ងន់ណាស់ដែលហ៊ានរត់ចោលស្រុក ។ បើបងប្អូនមិនព្រមកែខ្លួនទេ ហើយហ៊ានរត់ជាលើកទីពីរទៀតនោះ ភ្នំជញ្ជាំងគឺជាកន្លែងចុងក្រោយរបស់បងប្អូនទាំងអស់គ្នាហើយ" ។ ពួកយើងព្រឺក្បាលខ្លាក ។ សមមិត្តនិយាយដោយលើកដៃចង្អុលទៅភ្នំមួយដែលយើងមើលទៅឃើញនៅមិនឆ្ងាយពីភូមិនោះដែរ ។ ក្រោយមក ខ្ញុំឮអ្នកមូលដ្ឋានម្នាក់លួចនិយាយប្រាប់ខ្ញុំថា "ភ្នំជញ្ជាំងនេះជាកន្លែងសម្រាប់ដាក់អ្នកទោសធ្ងន់ៗ ។ អ្នកទោសហូបតែបាយក្រៀមទេ ពេលធ្វើការគឺគេដាក់ច្រវាក់ជើងព្រោះខ្លាចអ្នកទោសរត់" ។

បន្ទាប់ពីព្រមានយើងហើយមួយស្របក់ សមមិត្តនារីម្នាក់បានដើរមកហៅយើងទៅហូបបបរ ។ ខំគេចពីបបរ ឥឡូវមកជួបបបរទៀត ។ ប្ដីខ្ញុំឲ្យខ្ញុំទៅហូបជាមួយកូនប្រុសភ័ក្ត្រខ្ញុំចុះគាត់មិនឃ្លានទេ បើសុំគេបានក៏សុំបន្តិចមក ។ ខ្ញុំក៏លូកយកស្លាបព្រាពីរនៅក្នុងបង្វេចដាក់ខោអាវ ពួកយើងទាំងបីនាក់មានតែស្លាបព្រាប៉ុណ្ណោះគ្មានចានទេ ។ ខ្ញុំដើរសំដៅមាត់ស៊ុងដែលនៅជិតរោងបាយ ដើម្បីលាងស្លាបព្រាមុនទៅហូបបបរ ។ គ្រាន់តែលូកដៃស្លាបព្រាជ្រុះចូលក្នុងទឹកភ្លាមដូចមានដែកឆក់អ៊ីទាញយកស្លាប-ព្រាពីក្នុងដៃខ្ញុំទៅបាត់ ។ ខ្ញុំយល់ថាកាន់តែឲ្យហេតុមិនស្រួលហើយ ប្រហែលមានពីរនាក់ត្រូវរបូតក៏មិនដឹង ។ ខ្ញុំបន់ស្រន់លោកតាព្រៃភ្នំម្ចាស់ទឹកម្ចាស់ដី សូមជួយគ្រួសារខ្ញុំនិងបងប្អូន១៧មេសាទាំងអស់បានរួចរស់ជីវិតផង ។

អង្គការឲ្យគ្រួសារខ្ញុំរស់នៅក្នុងផ្ទះល្វែងៗជាប់គ្នាបីបន្ទប់ ។ កន្លែងនោះពីដើមជាជង្រុកស្រូវ តែឥឡូវអស់ស្រូវហើយគេឲ្យមនុស្សនៅម្ដង ។ ពួកយើងទៅចំពេលភ្លៀងធ្លាក់ល្មម ហេតុនេះក៏ដល់ពេលធ្វើស្រែដែរហើយ ។ ព្រឹកនេះតាំងពីព្រលឹម សមមិត្តនារីម្នាក់រាងចំណាស់បន្តិចបានដើរមកហៅពួកយើងទៅដកស្ទូងនៅស្រែឆ្ងាយពីភូមិប្រហែលមួយគីឡូម៉ែត្រ ។ គេឲ្យយើងយកចានឆ្នាំងនិងស្លាបព្រាទៅជាមួយផង (គឺចានហូបបាយ តែសម្រាប់យើងអ្នករត់នេះចានឆ្នាំង) ។ ខ្ញុំសុំច្បាប់គេឲ្យប្ដីខ្ញុំទម្រាំតែបានគេអនុញ្ញាតឲ្យឈប់បី-បួនថ្ងៃ គេស្ដីឲ្យដូចសត្វធាតុ ។ សមមិត្តកាន

អាយុ៥០ឆ្នាំ ជាប្រធានភូមិដែលពួកយើងជួបពីដំបូង ស្តីឲ្យប្តីខ្ញុំថា "សុទ្ធតែពួកសតិអារម្មណ៍មកដល់មិនទាន់បានធ្វើអ្វីផង ក៏ឈឺទៅហើយ បានតែកុំឲ្យហូប" ។ នៅក្នុងស្រែពួកយើងធ្វើការសឹងតែមិនបាន ព្រោះតែកែវភ្នែកសម្លក់សម្លឹងរបស់ពួកអ្នកមូលដ្ឋានគ្រប់គ្នាដែលមើលមកយើងដោយគ្នាន់ក្នាញ់សឹងតែចង់ស៊ីសាច់ពួកយើង ។

## សម្លម្ជូរព្រ័ត្រគោ

ពេលវេលាកន្លងទៅប្រហែលកន្លះខែហើយ ប្តីសម្លាញ់ខ្ញុំក៏បានជាស្រួលបួលពុំដឹងជាដោយសារថ្នាំអាចម៍ទន្សាយឬក៏ជាដោយសារអ្វីទេ ។ គាត់ត្រូវគេបញ្ជាឲ្យចេញភ្ជួរជាមួយគេឯង ព្រោះជាកម្លាំងទីមួយ ។ នៅភូមិទឹកជោរនេះមានគ្រួសារចាមប្រហែល១០គ្រួសារដែរ ។ ពួកបងប្អូនចាមយើងត្រូវគេធ្វើបាបស្ទើរស្លាប់ស្ទើររស់នៅពេលមានសាច់ជ្រូកហូបម្តងៗ ។ ប្អូនស្រីប្រាហ៊ីម អាយុប្រហែល២៤-២៥ឆ្នាំ បានលួចនិយាយប្រាប់ខ្ញុំដោយទឹកភ្នែកថា "ពួកនាងក្រុមចាមនេះមកនៅភូមិនេះប្រហែលមួយឆ្នាំហើយ ហូបតែបបរទេខួបប្រាំងខួបវស្សា ។ យូរៗគេមានសម្លសាច់ជ្រូកឲ្យហូបម្តង ប៉ុន្តែពុំដែលឃើញសាច់ទេ ឃើញតែខ្លាញ់អណ្តែតត្រា ។ គេបង្ខំឲ្យម្តាយនាងហូបសម្លហ្នឹង ទោះជាគាត់សុំតែអំបិលគេពីរ-បីគ្រាប់ជំនួសក៏មិនបានដែរ ។ ក្រោយមកពីរ-បីខែ ម្តាយនាងក៏ស្លាប់ទៅពុំដឹងជាឈឺអី ។

នៅជាប់បន្ទប់ដែលខ្ញុំរស់នៅមានគ្រួសារចាមមួយ ។ បន្ទប់ក្រង់ស្រូវខ្ញុំធ្វើពីដីភក់លាយនឹងអាចម៍គោនិងចំបើង (វែងជាមួយបន្ទះឬស្សី) ។ អ៊ំសាឡេះ គាត់មានប្រពន្ធនិងកូន៥នាក់ តែឥឡូវនៅសល់តែកូនពីរប៉ុណ្ណោះ ។ គាត់ជាមនុស្សមានអធ្យាស្រ័យល្អណាស់ ។ គាត់អាណិតស្រលាញ់គ្រួសារខ្ញុំណាស់ ហើយគាត់ក៏ភ្ជួររាស់ជាមួយប្តីខ្ញុំដែរ ។ គាត់តែងប្រាប់ប្តីខ្ញុំឲ្យប្រយ័ត្នមាត់កកុំនិយាយផ្តេសផ្តាស កុំធ្វើឫកពាអ្វីមិនសមរម្យឲ្យសោះ ។ ឈ្លបនៅទីនេះក្មេងៗទេ ប៉ុន្តែសាហាវឃោរឃៅណាស់ ។

នៅស្រុកនោះពុំគ្រាន់តែអត់ទេ គឺខ្វះថែមទៀត ។ សូម្បីតែខសក៏ពិបាករកដុតដែរ គឺមានតែឫស្សីដែលយើងត្រូវចូលទៅទាញយកដោយពិបាក ។ ដូនឃើញទំពាំងក៏ដឹកយកតែម្តងតែពេលចេញមកវិញអាវខ្ញុំក៏ត្រូវរហែករយ៉ែអស់អាវមួយទទេ ។ ចំណែកអ្នកមូលដ្ឋានវិញ ទោះហូបបបរតែគេក៏ចេះតែមានអង្ករខ្លះៗដែលមិនដឹងបានមកពីណាអាចធ្វើនំអំបែងផ្អែមញាំ គឺយកអង្ករកិនឲ្យម៉ដ្ត ហើយលាយទឹកនិងស្ករត្នោតចាក់លើខ្ទះដាបន្ទះស្តើងៗក៏គ្រាន់ហូបដែរ ។ ឬដូនកាលគេចាក់ជាបាញ់ឆែវដាក់ស្ងួលសាច់ត្រី ហើយផ្ទាប់ជាមួយស្លឹកឈើព្រៃឬត្រួយល្ងៀងដែលអាចហូបបានជ្រលក់ទឹកអំបិលជូរអែមក៏គ្រាន់ហូបដែរ ។ នៅពេលដែលគេកំពុងតែហូប ប្រសិនបើយើងដើរទៅឃើញគេក៏ហៅយើងហូបដែរ តែកុំប្រទ្បាំគឺហៅក្នុងការគួរសមប៉ុណ្ណោះតែក្នុងពោះវិញគឺភ័យអ៊ូចៗខ្លាចយើងហូបមែន គេនឹកក្នុងពោះថាស៊ីឲ្យអស់ឲ្យខានអញទៅ ។

នៅក្នុងភូមិនេះទៀតសោត គ្មានស្លឹកឈើស្លឹកព្រៃដូចជាស្លឹកបាស ត្រកួន ជ្វីអ៊ី ដើម្បីយកស្ងោរហុតក៏គ្មានដែរ ។ ប្រសិនបើដើមត្របែកវិញមានតែមែកនិងស្លឹកចាស់ៗប៉ុណ្ណោះ ។ គេហាមមិនឲ្យជនភៀសខ្លួនមានកម្មសិទ្ធិសួនតួអ្វីទេ ហាមដាំបាយ ធ្វើម្ហូបនៅផ្ទះ គឺអាចដាំតែទឹកប៉ុណ្ណោះ ។ អ្នកមូលដ្ឋានទាំងថ្មីទាំងចាស់តែងនាំគ្នាដំណាលថា ចម្លែកណាស់ ឃើញមានអាចម៍នៅតាមគុម្ពឈើដូចអាចម៍ជ្រូក តែដានជើងគឺដានជើងមនុស្សទៅវិញ ។ មិនប្លែកទេ ព្រោះចំណីអាហារមិនដល់ ម៉្លោះហើយអាចម៍មនុស្សដូចអាចម៍ជ្រូក ។ ហ្នឹងហើយរបបបងពតមហាលោតផ្លោះមហាអស្ចារ្យ ។

ល្ងាចនេះ ក្រោយពីហូបបបរហើយ អ៊ំសាឡេះ បានស្រែកសួរខ្ញុំថា "មិត្តណាងៗ មានអំបិលទេ ឲ្យខ្ញុំមួយស្លាបព្រាមក ខ្ញុំកំពុងតែស្លម្ជូរសាច់គោវាខ្វះអំបិល ហើយចាំមួយស្របក់ទៀតវាផុយចាំខ្ញុំជូនឲ្យមួយចាន" ។ ខ្ញុំឮដូច្នេះអរណាស់ ក៏យកអំបិលឲ្យគាត់ហើយនឹកក្នុងចិត្តថា ច្បាស់ជាបានឆ្ងាញ់មាត់ហើយ ។ ប្រហែលជាពាក់កណ្តាលយប់ទៅហើយ គ្រួសារខ្ញុំអង្គុយចាំសម្លម្ជូរសាច់គោទាល់តែគេងលក់ទាំងអស់គ្នា ។ ខ្ញុំក៏ភ្ញាក់ឡើងដោយឮសំឡេងខ្សឹបៗហៅនៅមាត់ទ្វារថា "មិត្តណាងៗ យកសម្លឆ្អិនហើយ" ។ ផ្ទះក្នុងរបបនោះគ្មានសន្លឹកទ្វារ គឺបើកចំហដើម្បីឲ្យអង្គការមើលឃើញតើយើងកំពុងធ្វើអ្វីខ្លះ ។

ខ្ញុំដាស់ប្តីហើយនិងកូនប្រុសខ្ញុំឲ្យភ្ញាក់ឡើងដើម្បីហូបសម្លសាច់គោ ។ ខ្ញុំហុតមួយម៉ាត់ទៅជូរជ្រះរបស់គេគ្រាន់បើ គឺស្លឹក

អំពិលចាស់ៗដាក់ធ្វើម្ជូរ ។ ខ្ញុំដួសសាច់គោមួយដុំមកទំពារ ពុំទ្រាំចង់បាក់ធ្មេញ សាច់ស្វិតគេក៏ដូចថ្មដូច្នេះ? ខ្ញុំអើតទៅសួរអ៊ីសាឡេះ តិចៗថា “អ៊ីៗ សាច់គោអីក៏រឹងម៉្លេះ សាច់ក្របីទេឬ?” អ៊ីសាឡេះ ឆ្លើយមកវិញថា “ហូបទៅ គឺព្រ័ត្រគោហ្នឹងណា៎ អ៊ីលួចពីរទេះគោផង កុំមាត់ប្រយ័ត្នគេដឹងរឿងធំហើយ” ។ ហេតុនេះទើបខ្ញុំស្គាល់ព្រ័ត្រគោតាំងពីពេលនោះមក ។ អ្នកបរទេះទាំងអស់ត្រូវប្រយ័ត្នរឿងព្រ័ត្រគោ បើបាត់ព្រ័ត្រគោគឺអ្នកមើលគោត្រូវទទួលខុសត្រូវ ។ ជួនបាត់ខ្លួនរហូតក៏មាន ។ ក្នុងគ្រាដ៏សែនលំបាកវេទនានោះ ជីវិតពួកយើងប្រៀបបានដូចទឹកមួយតំណក់នៅលើស្លឹកឈូកប៉ែលប៉ោលកណ្តាលព្យុះសង្ឃរា រេរាចុះឡើងដោយកម្លាំងព្យុះបក់បោករង់ចាំតែថ្ងៃមរណាប៉ុណ្ណោះ ។ ម្នាក់ៗបើដើរទៅធ្វើការសឹងតែរកកម្លាំងកំហែងគ្មាន ខ្លះគ្រាន់តែត្រឡប់មកពីដកស្ទូងវិញដើរតាមភ្លឺស្រែក្រោមតំណក់ទឹកភ្លៀងតិចៗ គ្រាន់តែដួលក៏ស្លាប់នៅក្នុងស្រែតែម្តងទៅ ព្រោះតែដាច់ជាតិបាយយូរពេកក៏មិនដឹង ។

ពីមួយថ្ងៃទៅមួយថ្ងៃ ពួកយើងកាន់តែរលស់បាត់ទៅៗ ។ ជួនកាលគ្រួសារខ្លះក្រោយពីមកហូបបបរល្ងាចហើយរៀបចូលសម្រាក ក៏មានឈ្លបក្មេងៗពីរ-បីនាក់ហៅទៅជួយធ្វើការនៅរោងបាយមួយភ្លែត តែក៏បាត់សូន្យរហូតទៅក៏មានដែរ ។

## គ្រូបង្រៀន សាយ ត្រូវគេតាមចាប់ខ្លួន

នៅក្នុងស្រែកន្លែងភ្ជួររាស់ ប្តីខ្ញុំគាត់ស្គាល់មិត្តភក្តិជាច្រើនដែលជាអ្នក១៧មេសាដូចគ្នា ហើយនៅភូមិជិតនេះដែរ តែមកភ្ជួរនៅជិតគ្នា ។ ពេលសម្រាកពីការងារ ពួកគាត់តែងអង្គុយជជែកគ្នាលេង ហើយចែកថ្នាំគ្នាជក់មូរស្លឹកសង្កែម្នាក់បន្តិចៗ ។ ក្នុងចំណោមនោះ ប្តីខ្ញុំស្គាល់មិត្តម្នាក់ឈ្មោះ សាយ ជាអតីតគ្រូបង្រៀន ។ បងសាយ មានអាយុប្រហែល៣០ឆ្នាំប៉ុណ្ណោះ ។ មុខគាត់ស្លឹងគម្រាំង ស្បែកមុខជ្រីវជ្រួញ ថ្ពាល់ផត ក្រហូង ភ្នែកល្អក់ស្រអាប់ សក់កន្ទ្រើងដូចមិនដែលស្គាល់កន្ត្រៃ សាច់ខ្មៅឡើងជ្រួញដូចតាចាស់អាយុ៥០ឆ្នាំ ។ បងសាយ ខស្សរាហ៍លួចថ្ងូរប្រាប់ប្តីខ្ញុំថា គាត់ប្រហែលជារស់មិនបានយូរទេ ព្រោះគេចេះតែសង្ស័យគាត់ថាជាអ្នកធ្វើការ ។ យប់ដែលគាត់បារម្ភក៏មកដល់ ។ យប់នោះម៉ោងប្រហែល៨-៩ យប់ទៅហើយ គ្រូសាយ ក៏មកដល់ផ្ទះខ្ញុំទាំងទឹកមុខភ័យព្រួយពាក់អាវខ្មៅរហែកខ្ទេចខ្ទី មានបង់កក្រមាកញ្ចាស់មួយផង ។ គ្រាន់តែមកដល់ផ្ទះខ្ញុំភ្លាម គ្រូសាយក៏ទៅអង្គុយនៅកន្លៀតជញ្ជាំង ហើយខ្សឹបសួរប្តីខ្ញុំថា “ប្អូនហួតរត់ទៅជាមួយគ្នាឬទេ?” គាត់បន្ថែមដោយដង្ហក់ថា “ខ្ញុំត្រូវគេតាមរកចាប់ខ្លួនហើយ យប់មិញបាត់អស់គ្នាខ្ញុំពីរនាក់ ហើយយប់នេះប្រហែលជាដល់វេនខ្ញុំក៏មិនដឹង” ។ ប្តីខ្ញុំឡិនឡង់ងាកមើលមុខខ្ញុំ និងកូនប្រុសខ្ញុំទាំងមិនដឹងឆ្លើយយ៉ាងម៉េច ។ ប្តីសម្លាញ់ខ្ញុំឆ្លើយថា គាត់មិនដាច់ចិត្តចោលប្រពន្ធកូនទេ ។ ពួកយើងអាណិតបងសាយ ណាស់ ហើយមិនដាច់ចិត្តឲ្យគាត់ទៅដោយគ្មានអ្វីទ្រាប់ពោះមួយគ្រាប់ដូចនេះសោះ ។ ជាសំណាងល្អ ប៉ុន្មានថ្ងៃមុនប្តីខ្ញុំបានអង្ករពីរកំប៉ុងដែរ ។ ខ្ញុំបានដាក់ដាំបបរក្នុងកំសៀវទឹកជូនបងសាយ ហូបទាំងភ័យព្រួយ ។ បបរដាក់ទឹករាវកក្តុក យើងចែកគ្នាហុតទាំងអស់គ្នា តែយើងឲ្យ បងសាយ ហូបច្រើនជាងគេ ។ ខ្ញុំបានយកអង្ករកន្លះកំប៉ុងទៀតលីងឲ្យឆ្អិនដើម្បីទុកឲ្យគាត់ហូបតាមផ្លូវ ។ ពួកយើងសម្រាកលើគ្រែឬស្សីមួយជាមួយគ្នា ។ ប្តីខ្ញុំនិងបងសាយនិយាយខ្សឹបខ្សៀវគ្នាចង់ទល់ភ្លឺ ។ មាន់រងាវម្តងបងសាយ វេចអង្កររលីងនៅជាយក្រមា ហើយលាពួកយើងដោយសំឡេងអួលអាក់ថា “ប្អូនប្រុសប្អូនស្រីទាំងពីរ អង្កររលីងកន្លះកំប៉ុងនេះ បងគ្មានថ្ងៃភ្លេចបានទេ បើថ្ងៃក្រោយបងមានវាសនាល្អបានជួបគ្នាទៀត បងនឹងសងគុណប្អូនទាំងពីរឲ្យអស់ពីចិត្តពីថ្លើម” ។ ប្តីប្រពន្ធខ្ញុំរលីងរលោងទឹកភ្នែក ហើយជូនពរបងសាយ បានសេចក្តីសុខជារៀងរហូត ។ បងសាយ លាយើងទៅហើយ គាត់មានវាសនាយ៉ាងម៉េចក៏យើងមិនដឹង ។

## ក្លាយជាបដាចាទីពីរដោយមិនដឹងខ្លួន

យើងហើមដើងដាបណ្តើរៗ ទាំងកូនប្រុសភ័ក្រ្តខ្ញុំក៏ដូច្នេះដែរ ។ នេះគឺទណ្ឌកម្ម គឺគុកគ្មានជញ្ជាំងដែលយើងមើលមិនឃើញ ដែលគេដាក់ទោសពួកយើង ។ ដែលហៅថាភូមិទឹកដោរ គឺស្ទូងថ្ងៃនេះស្អែកឡើងដោរលិចស្រូវសន្ទូងអស់ ។ ធ្វើហើយធ្វើទៀត ធ្វើមិនចេះរួច ។ ព្រឹកនេះខ្ញុំរៀបចេញទៅស្រែ ប្តីខ្ញុំក៏រៀបទៅភ្ជួរដែរ សមមិត្តកាន ជាប្រធានភូមិ មានឈ្លបក្មេងៗពីរ-បីនាក់ដើរមកជាមួយ ។ សមមិត្តកាន និយាយជាមួយប្តីខ្ញុំដោយទឹកមុខមាំថា “ស្នើមិត្តហួត ទៅជួយភ្ជួរស្រែនៅភូមិខាង

ដើងបានពីរ-បីថ្ងៃ នៅសម្រាកទីនោះតែម្តង» ។ ប្តីខ្ញុំក៏ប្រញាប់ប្រញាល់ទាញក្រមាមកបង់ក ហើយដើរទៅជាមួយមិត្តកាន ។ ដើរបានពីរជំហានមិនដឹងគាត់នឹកឃើញយ៉ាងម៉េចក៏ងាកមកខ្ញុំ ហើយលូកហោប៉ៅអាវយកដែកកេះដែលប្រើគហុចមកឲ្យខ្ញុំ ក្រែងត្រូវការបង្កាត់ភ្លើងយប់ព្រលប់ ។ ខ្ញុំមិនទទួលហើយប្រាប់ថា «យកទុកប្រើទៅក្រែងនៅកណ្តាលវាលស្រែពិបាករកភ្លើងជក់បារី» ។ ដែកកេះនោះរុញទៅរុញមកទម្រាំតែប្តីខ្ញុំដាច់ចិត្តដាក់ហោប៉ៅយកទៅ ហាក់ដូចជាការលាគ្នាជាចុងក្រោយដូច្នេះ ។ ព្រឹកនោះដដែល នៅក្នុងស្រែ ខ្ញុំកំពុងតែស្ទូង មានឈ្លបក្មេងម្នាក់បានដើរមកស្ទូងជិតខ្ញុំ ហើយសួរខ្ញុំថា «មិត្តឯងអាយុប៉ុន្មានហើយ?» ខ្ញុំឆ្លើយថា «ខ្ញុំអាយុ២៧ឆ្នាំហើយមិត្ត» ។ ឈ្លបនោះសើចហើយនិយាយថា «អាណិតណាស់មេម៉ាយនៅក្មេងពេក» ។ ខ្ញុំប្រញាប់ឆ្លើយភ្លាមថា «មិត្តប្អូនឯងប្រឡំទេដឹង គ្រួសារខ្ញុំនៅរស់ទេតើ» ។ ឈ្លបនោះសើចហើយដើរចេញទៅ ។ យប់នោះខ្ញុំមិនដឹងថាជាថ្ងៃអី ខែអី ឆ្នាំអីទេតែខ្ញុំចាំថាជាយប់ខែរះពេញបូរមី ។ ខ្ញុំរសាប់រសល់គេងមិនលក់សោះ ខ្ញុំអង្គុយមើលលោកខែនៅមាត់ទ្វារ ហើយក៏លង់លក់ទាំងអង្គុយនោះទៅ ។ យប់នោះខ្ញុំយល់សប្តិឃើញបាក់កូនកាំបិតនៅសល់តែមួយដែលខ្ញុំខំរក្សាទុកតាំងពីចេញពីភ្នំពេញទៅម្ល៉េះ ។ ខ្ញុំភ្ញាក់ឡើងញ័រខ្លួនដូចកូនសត្វ ។ នឹកដល់ប្តីសម្លាញ់ នឹកដល់សំណួរដែលឈ្លបក្មេងសួរខ្ញុំពីថ្ងៃ ខ្ញុំស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ ខ្ញុំលើកដៃសំពះទេវតាម្ចាស់ទឹកម្ចាស់ដី សូមលោកជួយថែរក្សាប្តីសម្លាញ់របស់ខ្ញុំកុំឲ្យគាត់មានគ្រោះថ្នាក់អ្វីឲ្យសោះ ។ នាគ្រានោះ ខ្ញុំតម្អូញទូញថ្ងូរដោយមិនដឹងខ្លួន÷

-បងសម្លាញ់ បងកុំកើតអីឲ្យសោះ បងកុំទៅចោលប្រពន្ធនិងកូនឲ្យនៅកណ្តាលសមុទ្រឈាមនេះអី ។

-សំឡេងយំសោករបស់ខ្ញុំបានឮដល់ អ៊ំសាឡេះ ដែលនៅជាប់ជញ្ជាំងផ្ទះខ្ញុំ ។ អ៊ំសាឡេះ អើតមកបន្ទប់ខ្ញុំហើយនិយាយខ្សឹបៗថា÷

-មិត្តណាងអើយ កុំយំឮពេកប្រយ័ត្នគេឮ ។

នាងខ្ញុំសរសេរដល់ត្រង់ណេះខ្ញុំអួលដើមក នឹកដល់គ្រាដ៏សែនមហាកម្សត់នេះណាស់ ។ ជីវិតពួកយើងទាំងអស់គ្នាហាក់ផុយស្រួយរកទីបំផុតគ្មាន ។ ពោលៈ ក្នុងគ្រាកម្សត់ពួកយើងមិនដែលក្បត់គ្នាសោះឡើយ ទោះបីមានអ្វីញ៉ាំមួយម៉ាត់មួយកក៏នឹកភ្នកៈរកគ្នាគ្រប់ដង្ហើម ។ ទៅលួចវេចខ្ចប់យ៉ាងណាស្រវាឲ្យតែបានដល់ផ្ទះនឹងអាលស្រាយចែកគ្នាញ៉ាំភ្លាម ។ នឹកឃើញកាលគ្រាមួយនោះណា៎ រូបប្រុសវៀមរ៉ាចេញរកម្ហូបត្រឡប់មកវិញបានជួបក្រុមឈ្លបត្រូវគេពិន័យឲ្យលើកដី ។ រូបស្រីល្ងិតល្ងង់មិនចេះអីសូម្បីតែត្រីក៏មិនចេះរក សូម្បីតែស្លឹកឈើព្រៃក៏មិនស្គាល់ បុកស្រូវរែកទឹកក៏មិនចេះ ។ មានតែទឹកភ្នែកហូរជ្រែកភ័ក្ត្រស្រីដែលធ្លាប់ប្រដូរ រៀបរាប់រឿងចុកណែនពេញទ្រូង ។

## ភ្លៀវប្រមុះស្រួច

មួយថ្ងៃ ពីរថ្ងៃ បីថ្ងៃកន្លងផុតទៅ ។ នៅព្រឹកនេះ ខ្ញុំរៀបចេញទៅធ្វើការហើយ ខ្ញុំឃើញសមមមិត្តកាន ព្រមទាំងឈ្លបចាស់-ក្មេងប្រហែលដប់នាក់មុខប្លែកៗ មានស្ពាយកាំភ្លើងវែងគ្រប់គ្នាដែលខ្ញុំមិនដែលឃើញពីមុនមកសោះ ។ ពួកគេដើរមកក្នុងបន្ទប់ខ្ញុំ ហើយ មិត្តកាន និយាយមកខ្ញុំថា÷

-មិត្តណាងឯងបើចង់ឲ្យគ្រួសាររួចខ្លួនត្រឡប់មកវិញ មានស្អីប្រគល់ឲ្យអង្គការទាំងអស់មក ។ ខ្ញុំលស់ព្រលឹងភាំងស្មារតីរកនឹកមិនឃើញថាប្តីខ្ញុំដូចជាគេហៅទៅជួយភ្ជួរទេ ហេតុអីក៏មានកំហុសវិញ? មិត្តកាន បន្តថា÷

-កុំឆ្ងល់អី មិត្តណាង ឯងប្តីធ្វើការអីក៏អង្គការដឹងដែរ អង្គការភ្នែកម្នាស់ណា៎ ។

ក្នុងពេល មិត្តកាន កំពុងនិយាយឈ្លបប៉ុន្មាននាក់ទៀតក៏រើកកាយជជុះអីវ៉ាន់បន្តិចបន្តួចក្នុងបន្ទប់ខ្ញុំ ។ ពួកគេរើកកាយចាប់តាំងពីក្រឡអំបិល ប្រចាប់ញក់ញីខ្ទើយកើយ ចាក់ដេះក្នុងចង្ក្រានគ្មានឃើញអ្វីសោះ ។ ខ្ញុំនឹកក្នុងចិត្តថា ប្តីសម្លាញ់ខ្ញុំពិតជាមានគ្រោះថ្នាក់អ្វីហើយ ។ ខ្ញុំមិនគិតយូរឡើយ ខ្ញុំរើក្នុងចង្អេរសំបុកមាន់ដែលមានមេមាន់មួយកំពុងក្រាបពងនៅពីក្រោយខ្នងឈ្លបម្នាក់ ហើយដែលគេពុំបានចាប់អារម្មណ៍ ។ នៅក្នុងចំបើងមានកជាមាសសល់ប្រហែល៤-៥ ។ ខ្ញុំយកហុចឲ្យសមមិត្តកានដោយដៃពីរ រកនិយាយអ្វីក៏ពុំចេញដែរ ។ ឈ្លបក្មេងៗដើរចេញអស់ហើយ ខ្ញុំនឹកឃើញនៅសល់លុយ២០០ដុល្លារនៅក្នុងខ្នារអំបោះសូត្រដែលខ្ញុំទុកជាយូរមកហើយ ។ ខ្ញុំក៏ទៅស្រាយអំបោះ

យកលុយ នោះដែលខ្ញុំរុំក្រណាត់កៅស៊ូជាច្រើនជាន់ពីក្រោយក មកហុចឲ្យ មិត្តកាន ជាសំណូកចុងក្រោយ ។ មិត្តកាន មិនស្គាល់ លុយអ្វីទេ សួរខ្ញុំទាំងលូកដៃយកថា៖

-លុយស្អីហ្នឹងមិត្តណាង?

ខ្ញុំមិនហ៊ានថាដុល្លារទេ ព្រោះខ្លាចថាខ្ញុំជាចក្រពត្តិអាមេរិក ឬជាខ្មែរសេ.អុី.អា កាហ្សេបេ ស្អីគេនោះ ។

-ចាស! លុយនេះទៅប្រទេសណាក៏ចាយបានដែរមិត្ត សូម មិត្តយកទុកចុះ ខ្ញុំមិនដឹងទុកធ្វើអីទេ ហើយសូមមិត្តបងជួយប្តីខ្ញុំ ផង ។

មិត្តកាន មិនឆ្លើយ ដៃក្តាប់លុយដើរចេញទៅយ៉ាងលឿន ។ ខ្ញុំរង់ចាំមើលប្តីខ្ញុំមួយថ្ងៃហើយមួយថ្ងៃទៀត ចាំបាត់ៗមិនឃើញ ប្រុសថ្លៃត្រឡប់មកវិញសោះ ។ ព្រឹកនេះ ខ្ញុំគេតម្រូវឲ្យទៅស្ទូង នៅជិតផ្លូវជាតិ (ក្រោយមកខ្ញុំដឹងថាកន្លែងនោះគឺជិតស្ពានគាប៉ុន ជាប់ព្រំប្រទល់ខេត្តសៀមរាប) ។ ដើរតាមផ្លូវ ពួកយើងអ្នក ស្ទូងទាំងអស់គ្នាត្រូវសមមិត្តកាន មកពិនិត្យផ្ទាល់ មើលទៅដូចជា ម៉ឹងម៉ាត់ណាស់ ហាក់មានសភាពការណ៍អ្វីប្លែក ។

មិត្តកាន បានប្រាប់ពួកយើងថា «ថ្ងៃនេះមានពួកបារាំង និងភ្ញៀវបរទេសច្រើនណាស់ មកលេងឆ្លងកាត់ផ្លូវស្រុកយើងនេះ ហេតុនេះបងប្អូនអ្នកស្ទូងទាំងអស់បើឃើញមានឡានបើកកាត់ តាមនេះត្រូវឱនស្ទូងទាំងអស់គ្នា ហាមមិនឲ្យងើបឈរដាច់ខាត ។»

ពួកយើងស្ទូងប្រហែលជិតថ្ងៃត្រង់ទៅហើយ ទើបឃើញ មានឡានម៉ែរសីដែសស្ទើរចាស់ពណ៌សបីគ្រឿងបើកកាត់តាមផ្លូវ នោះ ។ ពួកគេឈប់ឡានចម្ងាយប្រហែល៥០ម៉ែត្រពីពួកយើង ហើយមានពួកបរទេសបួន-ប្រាំនាក់ចុះពីឡាន ដៃកាន់ម៉ាស៊ីនថត តម្រង់មកពួកយើងដែលកំពុងឱនស្ទូង ។ ខ្ញុំនិងបងស្រីម្នាក់ ដែលស្ទូងជិតគ្នា ក្រោកឈរដោយស៊ីយប្រតិកម្មភ្លេចគិតបំរាម ដែល មិត្តកាន ទើបនឹងហាម ។ ពួកយើងហាក់ចង់ស្រែកប្រាប់ បរទេសអស់នោះឲ្យជួយពួកយើងផង យើងវេទនាណាស់ ស្រាប់ តែ មិត្តកាន ស្រែកភ្ញាក់សំឡេងពីខាងក្រោយមកថា៖

-មិត្តឯងទាំងពីរចង់ស្លាប់អ្ហេស?

ពួកយើងឱនចុះវិញភ្លាម ។ ខ្លួនខ្ញុំឡើងញ័រចំប្រប់ ព្រោះ ហ៊ានល្មើសនឹងបញ្ជា ។ ក្រោយមកទើបខ្ញុំដឹងថា ហេតុដែលពួកគេ មិនឲ្យយើងឈរ ព្រោះកុំឲ្យភ្ញៀវបរទេសឃើញរូបរាងស្គម កំព្រីងរបស់ពួកយើង ។ ល្ងាចនេះខ្ញុំមកផ្ទះវិញ ឃើញកូនប្រុស ខ្ញុំគេងស្តូកស្តឹងនៅលើគ្រែឬស្សីទាំងគ្មានកម្លាំងកំហែងក្នុងខ្លួន បន្តិចសោះ ។ ខ្ញុំគ្មានលទ្ធភាពអាចរកដូរអង្ករឬត្រីសាច់អ្វីបានទេ ព្រោះអស់មានរបស់សំខាន់អ្វីមានតម្លៃនឹងដូរបានឡើយ ។ អឹសាឡេះ ឲ្យខ្ញុំយកស្លឹកទឹកដោះគោមកដាំឲ្យកូនប្រុសខ្ញុំញ៉ាំដើម្បី ឲ្យវានោមបានច្រើនឲ្យវាស្រកហើម ប៉ុន្តែវាគ្រវីក្បាលមិនព្រម ញ៉ាំសោះ ។ បបរក៏មិនញ៉ាំ ទឹកក៏មិនញ៉ាំ ។ ៣ថ្ងៃក្រោយមក កូនសម្លាញ់ខ្ញុំក៏ស្លាប់ចោលខ្ញុំទៅ ។

ខ្ញុំយំមិនចេញ ធ្វើអ្វីក៏មិនកើត គិតតែពីអន្ទះអន្ទែងខ្មោចសព កូន ។ កូនប្រុសសម្លាញ់ម្តាយ កូនតស៊ូជាមួយម្តាយយូរណាស់ មកហើយ ឥឡូវអ្នកឃ្លាតចោលម្តាយទៅទៀត ។ ចំណែកឯ ឪពុកកូនក៏មិនដឹងនៅឯណា ។ ខ្ញុំរសាឯកាម្នាក់ឯងកណ្តាលទន្លេដ៏ ធំធេង ។ អឹសាឡេះ និងពួកជិតពីរ-បីនាក់ទៀតមកជួយរុំសព កូនប្រុសកំព្រាខ្ញុំ ។ រីឯ អឹសាឡេះ សួរខ្ញុំថា៖ មានខោអាវណាល្អ ជាងនេះបន្តិចទេ ផ្លាស់ឲ្យកូន?

ខ្ញុំឆ្លើយថា៖ គ្មានទេអឹ ។

សាកសពកូនប្រុសសម្លាញ់ចិត្តខ្ញុំត្រូវរុំដោយកន្ទេល រហែកស្អៀកសម្លៀកបំពាក់កញ្ចាស់ គ្មានធូប គ្មានទៀន គ្មាន ព្រះសង្ឃឲ្យធម៌ គ្មានញាតិមិត្តចូលរួម គ្មានឪពុកនៅក្បែរ គ្មានអ្វីៗ ទាំងអស់ ក្រៅពីអ្នកជិតខាងពីរ-បីនាក់ ។

កូនខ្ញុំស្លាប់ទៅហើយ គេបានសុខហើយ គេទុកឲ្យខ្ញុំរស់ នៅវេទនាកណ្តាលលានមរណៈ ។

យប់នេះ ខ្ញុំអង្គុយស្រណោះស្រណោចម្នាក់ឯងនៅមាត់ទ្វារ បន្ទប់ខ្ញុំ ។ ខ្ញុំយល់ថាពិភពលោកនេះហាក់ដូចជាធូលាយណាស់ សម្រាប់ខ្ញុំ រស់នៅគ្មានញាតិ គ្មានមិត្តអ្វីទាំងអស់ ។ នៅពេល ដែលខ្ញុំកំពុងសរសេររឿងនេះ ទឹកភ្នែកខ្ញុំក៏ហូរហៀរមកដោយ មិនដឹងខ្លួន គឺទឹកភ្នែកដែលរីងស្ងួតហួតហែងអស់រយៈពេលជាង ២៣ឆ្នាំទៅហើយ គឺទឹកភ្នែកឈឺចាប់ព្រាត់ប្រាស រន្ធត់ ញាប់ញ័រ ដែលមនុស្សលោកសម័យនេះមិនធ្លាប់ជួបប្រទះ ។

ចាប់ពីពេលនោះមកខ្ញុំលែងនឹកនាបាយទឹក ។ ខ្ញុំទៅធ្វើការ ដោយគ្មានកម្លាំងកំហែងក្នុងខ្លួនបន្តិចសោះ មិនថ្លៃនិយាយរកអ្នក

ណាទាំងអស់ ។ អ៊ឹសាឡេះនិងប្រពន្ធគាត់តែងនិយាយលួងលោមខ្ញុំដោយលើកឧទាហរណ៍ថា មានគេរាប់លាននាក់វេទនាដូចយើងអ៊ីចឹងដែរ យើងត្រូវតែតស៊ូរស់នៅដើម្បីនៅចាំជួបប្ដីប្រពន្ធ ឪពុកម្ដាយ បងប្អូនដែលបែកគ្នាជាង៣ឆ្នាំមកហើយ ។

ឥឡូវដល់ខែច្រូតហើយ ខ្ញុំពុំចាំថាជាខែអីឆ្នាំអីទេ ។ ខ្ញុំចាំថាក្រោយមរណភាពកូនប្រុសខ្ញុំ ៤-៥ថ្ងៃ គឺដល់ថ្ងៃភ្ជុំបិណ្ឌល្មម ព្រោះមានប្រធានក្រុមពីរនាក់ដើរចែកអង្ករដំណើបតាមផ្ទះពួកខ្ញុំដែលទើបនឹងមកថ្មីនេះដែរ ។ គេដើរចែកឲ្យពួកខ្ញុំនៅពេលកណ្ដាលយប់ស្ងាត់ដើម្បីកុំឲ្យប្រជាជនចាស់ច្រណែន ។ ក្នុងម្នាក់ៗគេចែកអង្ករដំណើបឲ្យពីរកំប៉ុងទុកវេចនំអន្សម ។ ខ្ញុំទុកក្នុងបន្ទប់ត្រូវគេចូលលួចបាត់ថែមទៀត ។ ខ្ញុំវិលវល់ឈរមើលតែទឹកស៊ឹងចោរចូលលួចយកខោអាវ យកឆ្នាំង យកចាន មួយថ្ងៃបន្តិចៗ ទីបំផុតគឺនៅសល់តែ ខោអាវមួយចង្កេះជាប់នឹងខ្លួន ។

ព្រឹកៗឡើងប្រពន្ធ អ៊ឹសាឡេះ តែទាញដៃខ្ញុំទៅច្រូត ព្រោះកុំឲ្យគេស្ដីឲ្យខ្ញុំ ។ ខ្ញុំដើរទាំងគ្មានព្រលឹងទៅធ្វើការ ។ ខ្យល់ខែកត្តិកខ្ញុំដើរឆ្លងស្ពានដើមត្នោត ព្រឹកណាក៏ខ្ញុំធ្លាក់ទឹកប្រឡាយដែរ ។ ខ្ញុំត្រូវគេជួយទាញដៃឡើងពីទឹករងាររញ៉ីរញ៉ាក់ដូចកូនសត្វ ។ ចាននិងស្លាបព្រាដែលខ្ញុំកាន់យកទៅទុកហូបបាយក៏អណ្ដែតតាមទឹករាល់ថ្ងៃ ។ ទីបំផុតខ្ញុំអត់មានអ្វីទាំងអស់ គឺនៅសល់តែជីវិតមួយប៉ុណ្ណោះដែលពុំដឹងរបូតទៅថ្ងៃណាទៀត ។

ថ្ងៃខ្លះខ្ញុំមិនទៅធ្វើការ មិនហូបបាយ មិនខ្វីខ្វាចប្រធានភូមិ មិនខ្លាចឈ្លប មិនដឹងថាខ្លួនជាអ្នកណា ហើយឈ្មោះពិតប្រាកដក៏មិនដឹង គឺក្លាយជាឡីកឺ វង្វេងវង្វាន់កណ្ដាលសង្គមឃាតករគួរឲ្យសង្វេគជាទីបំផុត ។

ប៉ុន្មានថ្ងៃនេះប្រពន្ធ អ៊ឹសាឡេះ តែងមកដុំត្រចៀកខ្ញុំឲ្យខ្ញុំមានព្រលឹងព្រលះឡើងវិញ ។ គាត់លួចខ្សឹបប្រាប់ខ្ញុំថា÷ នែ៎ក្មួយណាង! ប៉ុន្មានថ្ងៃនេះពួសូរកាំភ្លើងមាំណាស់ ហើយអ៊ឹមើលទៅពួកឈ្លបដូចជាស្លូតណាស់ មិនសូវស្ដីឲ្យពួកយើងទេ តាំងស្មារតីឡើងក្មួយ ។

ខ្ញុំញឹមៗមិនបានយកចិត្តទុកដាក់ស្ដាប់ប៉ុន្មានទេ ។ ព្រឹកនេះពិតដូចយើងទាំងអស់គ្នាស្មានមែន ពេលដែលពួកយើងកំពុងតែឱនច្រូតស្រូវយើងឃើញប្រពន្ធប្រធានក្រុមប្រពន្ធឈ្លបរត់ត្របាញ់ជើងសំដៅទៅស្រែ លាត់សំពត់ចង់ដល់ក្រលៀន មានទឹកមុខភិតភ័យជាខ្លាំង ខ្លះដូចជាពេបចង់យំផង រត់ទៅដល់ខ្សឹបប្រាប់ប្ដីគេឲ្យទៅភូមិជាបន្ទាន់ ។ ពួកយើងមានសេរីភាពបានសម្រាកកម្លាំងបន្តិចឈរជជែកលេងសើច គ្មានដឹងថាមានហេតុ-ការណ៍អ្វីកើតឡើងទេ ។ ថ្ងៃជិតត្រង់មានកូនចៅអ្នក១៧មេសារត់ប្រសេចប្រសាចតម្រង់មកកន្លែងពួកយើងច្រូតដោយទឹកមុខរីករាយខុសពីពួកមូលដ្ឋាន ។ ពួកកូនចៅអស់នោះស្រែកដោយអំណរថា÷

-ម៉ែអើយ ស្រុកយើងបានរំដោះហើយ!

តើមានពាក្យអ្វីសប្បាយជាងពាក្យមួយម៉ាត់នេះ ។ ពួកយើងរត់ត្របាញ់ជើងត្រឡប់មកភូមិវិញ ដើម្បីរៀបចំអីវ៉ាន់ត្រឡប់ទៅស្រុកកំណើត ។ ខ្ញុំដើរយឺតតាមក្រោយគេ គ្មានសប្បាយគ្មានរំភើបញាប់ញ័រអ្វីនឹងគេបន្តិចសោះ ។ តើមានន័យអ្វីទៅបើជីវិតឯកោយ៉ាងនេះ ។ ម្នាក់ៗរៀបចំខោអាវ ខ្លះរត់ទៅរោងបាយដើម្បីកើបអង្ករអំបិលប្រហុកយកទៅទុកហូបតាមផ្លូវ ។ ខ្ញុំគ្មានអ្វីរៀបចំនឹងគេសោះ ខ្ញុំឈរដូចទីងមោងនៅមាត់ស៊ឹងជិតបន្ទប់ហាក់គ្មានវិញ្ញាណអ្វីបន្តិចនៅក្នុងខ្លួន ។

ស៊ឹងអើយ! អ្នកដឹងដំណើរប្ដីសម្លាញ់ខ្ញុំទេ ជួយប្រាប់គាត់ផង ខ្ញុំកំពុងតែរងាខ្លាំងណាស់ ស្រុកគេបានសាន្តត្រាណហើយ យើងនាំគ្នាទៅស្រុកយើងវិញ ។ ត្រឡប់មកបងសម្លាញ់! យើងរៀបចំជីវិតយើងជាថ្មី (ឬមួយក៏បង...អូយទេវតាអើយសូមកុំឲ្យដូចការគិតរបស់ខ្ញុំឲ្យសោះ) មកជួយប្រពន្ធផង ដូចដែលបងធ្លាប់ជួយខ្ញុំបីឆ្នាំថ្វាយកន្លងមកហើយ ។ ឱជីវិតអើយ! គ្មានអ្វីលំបាកជាងការព្រាត់ប្រាសគ្នាទេ ហើយក៏គ្មានអ្វីសប្បាយជាងការជួបជុំគ្នាដែរ ។

ខ្ញុំកំពុងតែភាន់ទាំងស្មារតីប្រពន្ធ អ៊ឹសាឡេះ មកអូសដៃខ្ញុំចេញដំណើរទៅជាមួយគាត់ ។ ខ្ញុំមានតែកញ្ឆើមួយ អង្ករពីរកំប៉ុងអាវដៃវែងនិងសំពត់ខ្មៅជ្រលក់មួយរយបំណះប៉ុណ្ណោះ តែខ្ញុំទូលពុំចង់រួចសោះ ពីព្រោះជើងខ្ញុំហើមធំពេក ។ ខ្ញុំងាកមើលទឹកស៊ឹងជាលើកចុងក្រោយ មើលបន្ទប់ក្រង់ស្រូវ មើលដើមអំពិលដែលខ្ញុំធ្លាប់ឈោងបេះបានតែស្លឹកចាស់ៗ ។ លាហើយទឹកកន្លែងដែលផ្ទុំក្លិនស្អេះស្អាបដោយសមុទ្រឈាម លាហើយកែវភ្នែកដ៏កាច

សាហាវគ្មានមនុស្សធម៌របស់ពួកឈ្លបក្មេងៗ លាហើយទឹកបបររាវកខ្វក លាហើយអ្វីៗគ្រប់យ៉ាងដែលគ្រួសារខ្ញុំសាងជាមួយគ្នា លាហើយកូនសម្លាញ់ម្តាយទាំងបី លាហើយស៊ីងទឹកជោរដែលអ្នកនាំយកជីវិតប្តីនិងកូនខ្ញុំទៅអស់រលីងគ្មានដំណឹងអ្វីបន្តិចសោះ ។

ខ្ញុំដើរពុំចង់រួច មានអារម្មណ៍ថាដូចជាឮសំឡេងប្តីនិងកូនខ្ញុំស្រែកហៅពីក្រោយ ។ ខ្ញុំងាកក្រោយជាញឹកញាប់ក្រែងប្តីសម្លាញ់ខ្ញុំត្រឡប់មករកខ្ញុំវិញ ។ លោកអ្នកអានទាំងអស់ ដល់វគ្គនេះខ្ញុំពុំអាចទប់ទឹកភ្នែក ព្រោះនឹកឃើញរឿងដូចនៅថ្មីៗ បែកគ្នាស្រស់ៗពេក ។ យើងពុំនឹកស្មានថាបែកគ្នាតែបីថ្ងៃសោះ ប្តីអើយ! យើងបែរជាបែកគ្នារហូតយ៉ាងនេះទៅវិញ ទាំងពុំឃើញស្រមោលអ្វីបន្តិចសោះ ។

ខ្ញុំដើរដោយលំបាកក្នុងចំណោមគ្រួសាររាប់រយនាក់ពេញណែនតាមផ្លូវ ។ គ្រួសារគេធ្វើដំណើរដោយទឹកមុខរីករាយ ព្រោះគេមិនបែកបាក់គ្នា ។ ខ្លះមុខស្ងួតព្រោះបាត់បង់កូនចៅ តែទោះយ៉ាងណាក៏គេនៅគ្រាន់បើជាងខ្ញុំច្រើន ព្រោះគេនៅមានគ្នីគ្នាគ្រាន់កំដរដែរ ។ ចំណែកខ្ញុំដើរតែម្នាក់ឯងដូចបដាចា គឺបដាចាទីពីរគ្មានខុសបន្តិចសោះ ។

ខ្ញុំហាក់ដើរក្នុងវាលខ្សាច់សាហារ៉ាដ៏ធំធេងតែម្នាក់ឯងទាំងដំណើរធេងធោងកណ្តាចកណ្តែងពេកក្រៃ ។

បងអើយ! ហេតុអ្វីយើងមកត្រូវបែកគ្នានៅពេលហែលជិតដល់កោះត្រើយទៅហើយ ។

ខ្ញុំឆ្លងស្ពានតាប៉ុន ចូលដល់ស្រុកក្រឡាញ់ (ក្នុងខេត្តសៀមរាប) ។ ជាមួយរលកមនុស្សជាច្រើននាក់ដែលខ្ញុំពុំស្គាល់ម្នាក់សោះ ។ ពេញមួយព្រឹកខ្ញុំដើរបានតែប្រហែលពីរគីឡូម៉ែត្រប៉ុណ្ណោះ ហើយរកម្លប់អង្គុយសម្រាក ។ ប្រជាជននៅស្រុកក្រឡាញ់មានទឹកមុខរីករាយសាច់ឈាមស្រស់បស់សម្លៀកបំពាក់ស្អាតបាត ពុំដូចពួកយើងជនភៀសខ្លួនមកពីខាងបាត់ដំបងទេ ព្រោះពួកគេពុំចេញទៅណាចោលស្រុកភូមិដូចពួកយើង ។ ពួកគេទាំងក្មេងទាំងចាស់ចេញមករោមមើលពួកយើងដូចសត្វចម្លែកដូច្នេះ ។ គេអាណិតអាសូរយើង ព្រោះឃើញក្បាលជង្គង់ធំជាងក្បាល មុខស្លេកស្លាំងគ្មានឈាម ខ្លួនស្គមកំព្រឹង សម្លៀកបំពាក់រហែករយ៉ៃ ។ ខ្ញុំអង្គុយចោងហោងយកក្រមាររហែកទ្រាប់គូថ ។ អ្នកភូមិនិងក្មេងៗប្រុសស្រីពីរ-បីនាក់ដើរតម្រង់មក ខ្ញុំព្រោះពុំឃើញខ្ញុំវៀសវៃដាំបាយដូចគេឯងឯងទៀតឡើយ ។ គាត់សួរខ្ញុំថា៖

-នាង! នាងឈ្មោះអី? ស្រុកកំណើតនៅឯណា? ម៉េចឃើញតែម្នាក់ឯងដូច្នេះ?

-ខ្ញុំឬ? (ខ្ញុំសួរគាត់វិញ ពុទ្ធោតើខ្ញុំឈ្មោះអ្វីទៅ? ស្រុកខ្ញុំនៅឯណាក៏មិនដឹង) ។

ខ្ញុំគ្មានការចងចាំអ្វីបន្តិចសោះ តើឲ្យខ្ញុំឆ្លើយថាម៉េចទៅ? ខ្ញុំឈ្មោះអ្វី? ខ្ញុំនឹកមិនឃើញទេ ទេវតាអើយសូមលោកជួយប្រាប់ខ្ញុំផង ។

ខ្ញុំឆ្លើយមិនរួចក្រៅពីគ្រវីក្បាល នឹកអ្វីក៏មិនឃើញ ។ អ៊ំប្រុសគាត់អាណិតខ្ញុំក៏និយាយថា៖

-នៅក្នុងភូមិនេះជាមួយនឹងខ្ញុំហើយ ចាំខ្ញុំជួយមើលឲ្យមានព្រលឹងព្រលះនឹងគេ មានសាច់មានឈាមឡើងវិញ ចាំទៅមុខទៀត!

ខ្ញុំមិនឆ្លើយថាម៉េចផង កូនៗគាត់ពីរ-បីនាក់ក៏ទាញដៃខ្ញុំឡើង ខ្លះជួយយកកញ្ជើខ្ញុំទៅមុន ។ ផ្ទះអ៊ំប្រុសនៅជិតនេះដែរ ចម្ងាយប្រហែល៥០ម៉ែត្រពីផ្លូវធំ ។ ប្រពន្ធគាត់ឈ្មោះ យឿន អាយុប្រហែល៥០ឆ្នាំហើយ គាត់ចិត្តល្អ ហើយអាណិតអាសូរខ្ញុំណាស់ ។ គាត់ថាឲ្យខ្ញុំនៅជាមួយគាត់ ធ្វើជាកូនចៅគាត់តែម្តងទៅ ព្រោះកូនគាត់ស្លាប់អស់បីនាក់ ហើយសល់តែម្នាក់ប៉ុណ្ណោះ ។ ចំណែកអ៊ំប្រុសឈ្មោះ សុខ គាត់ធ្លាប់បួសជាសង្ឃ កាលពីសង្គមចាស់ ទើបក្នុងផ្ទះគាត់យកស្បង់លោកធ្វើជាវាំងននិងស្រោមខ្នើយ ។ អ៊ំសុខ អាយុ៦០ឆ្នាំហើយ គាត់យកអំបោះឆៅពណ៌សមកចងដៃសងខាងរបស់ខ្ញុំ យកទឹកមួយផ្តិលមកប្រោះព្រំលើក្បាលខ្ញុំហៅព្រលឹងបួន-ដប់ចូលមកខ្លួនខ្ញុំវិញ ។

បីថ្ងៃកន្លងខ្ញុំបានស្រឡះក្នុងខួរក្បាលបន្តិចដឹងខ្លួនថាឈ្មោះអី តែនៅរកនឹកឈ្មោះពិត ក្នុងសំបុត្រកំណើត ហើយធ្វើការអីផ្ទះនៅឯណារកនឹកមិនឃើញសោះ ។ ខ្ញុំរស់នៅបានប្រហែលកន្លះខែហើយនៅផ្ទះអ៊ំប្រុស សុខ និងអ៊ំស្រី យឿន ខ្ញុំនឹករឭកបងប្អូន ឪពុកម្តាយខ្ញុំ ជីដូនខ្ញុំពុំដឹងរស់ឬស្លាប់យ៉ាងណា... ។

## ភ្លេងការប្រហារចិត្តខ្ញុំ

ខ្ញុំបានលាគ្រួសារអ៊ឹសុខ និង អ៊ឹស្រីយឿន និងញាតិមិត្តជិតខាងផ្ទះដែលតែអាណិតស្រឡាញ់ខ្ញុំ តែងហុចនំហុចនែកឲ្យហូបមិនដែលដាច់ ។ អ្នកស្រុកអ្នកភូមិអស់នោះគាត់អាឡោះអាល័យខ្ញុំណាស់ ពួកគាត់ជូនពរឲ្យខ្ញុំជួបនឹងឪពុកម្ដាយបងប្អូនទាំងអស់ដែលបែកគ្នា៣ឆ្នាំប្លាយមកហើយ ។

ខ្ញុំចាប់ផ្ដើមធ្វើដំណើរផ្សងព្រេងទៀតហើយ នៅតាមផ្លូវនៅតែមានអ្នក១៧មេសាយើងមិនចេះដាច់ ។ ខ្ញុំចេះតែដើរតាមគេពីភូមិមួយដល់ភូមិមួយ ប៉ុន្តែខ្ញុំភ្លេចឈ្មោះភូមិអស់នោះទៅហើយ ។ នៅតាមផ្លូវខ្ញុំបានជួបអ្នកដែលរស់នៅក្នុងភូមិជាមួយខ្ញុំខ្លះដែរ ។ មានថ្ងៃនោះ ខ្ញុំបានជួបនឹងបងស្រីម្នាក់ដែលគាត់ឆ្លងទន្លេនៅកណ្ដាលផ្លូវ គាត់បានសុំជ្រកក្រោមផ្ទះគេសម្រាកសិនកូនគាត់គឺកូនប្រុស ប៉ុន្តែវាមិនសូវថ្ងោសទេ ។ ម្ចាស់ផ្ទះក៏មានមេត្តាធម៌ឲ្យបាយទឹកគាត់ហូបរាល់ថ្ងៃ ។ ជាតិជាស្ត្រីគ្មានអ្វីវេទនាក្នុងពេលឆ្លងទន្លេ ហើយរឹតតែលំបាកទៀតនោះ គឺគ្មានប្ដីនៅជួយថែទាំ ។ ខ្ញុំបានសួរថា ប្ដីគាត់ទៅណាហើយ ។ បងស្រីយំ ហ៊ឺក្លាម ហើយនិយាយមិនចង់ចេញថា÷ បាត់គាត់តាំងពីនៅក្នុងភូមិម៉េ្វះ គេថាស្នើទៅជួយធ្វើរោងបាយមួយភ្លែត តាំងពីល្ងាចនោះមកក[8] បាត់គាត់រហូត ។

បងស្រីយំអណ្ដឺតអណ្ដក ឱបកូនប្រុសដែលហាក់តំណាងឲ្យរូបប្ដីគាត់ ។ ខ្ញុំធ្វើដំណើរទៅមុខទៀតជាមួយកូនបង្កេចដែលមានខោអាវចំណាស់ពីរកំប្លេ កូនឆ្នាំងបាយមួយ មុងមួយ និងភួយមួយ ។

ខ្ញុំធ្វើដំណើរពីភូមិមួយដល់ភូមិមួយដូចជាអ្នកទេសចរ (អ្នកទេសចរសក់ក្បាលកន្ទ្រើង) ។ ទឹកន្លែងណាដែលឮសូរភ្លេងការ ភ្លេងបុណ្យ ចម្រៀងលោក ស៊ិន ស៊ីសាមុត, អ្នកស្រី រស់ សេរីសុទ្ធា, អ្នកស្រី ហ៊ុយ មាស គឺមានវត្តមានខ្ញុំនៅទីនោះហើយ ។ តែខ្ញុំពុំមែនជាភ្ញៀវកិត្តិយសក្នុងពិធីអស់នោះទេ ខ្ញុំនៅកៀនកៀនតជិតរោងបុណ្យក្រោមដើមឈើ ។ ជួនកាលខ្ញុំកំពុងតែលន្លង់លន្លោចនឹងចម្រៀងអស់នោះ ភ្លេចខ្លួន ភ្លេចបាយភ្លេចទឹក មានដៃមួយមកកេះស្មាខ្ញុំ ហើយហុចបាយមួយចានក្ដៅហុយៗ ហើយនិងសម្លម្ជូរយួនមួយចានឲ្យខ្ញុំហូប ។ គេដាក់ទានហើយត្រូវតែហូប ខ្ញុំសូមជូនកុសលផលបុណ្យដល់បងប្អូនទាំងអស់ដែលបានជួយស្រោចស្រង់ជីវិតខ្ញុំ (នៅក្នុងគ្រាដ៏សែនកម្សត់នោះ) ។ រយៈពេលប្រហែលមួយខែជាង ខ្ញុំចូលដល់ខេត្តសៀមរាប គេឲ្យពួកយើងនៅម្ដុំ នៅជាយខេត្ត ខ្ញុំពុំដឹងថាជាភូមិអី សង្កាត់អីទេ ។ នៅម្ដុំនោះធុំក្លិនស្អុយលាមកជាខ្លាំង អ្នកណាដើរកាត់ទីនោះត្រូវតែយកដៃខ្ទប់ច្រមុះ ។ រាល់ព្រឹកមានរថយន្តកងទ័ពវៀតណាម (ឡានG.M.C) បួន-ដល់រាល់ថ្ងៃមកដឹកយកពួកជនភៀសខ្លួនយកទៅដាក់តាមភូមិស្រុករបស់គេវិញ ។ ឡានកងទ័ពនោះខ្ពស់ណាស់ ខ្ញុំគោងឡើងមិនរួចនឹងគេទេ ហើយក៏គ្មានអ្នកណាគេគិតគូរពីខ្ញុំ ជួយទាញខ្ញុំឡើងដែរ ។ ព្រោះគេរវល់គិតតែបងប្អូនគេប៉ុណ្ណោះ ។ ហេតុនេះខ្ញុំត្រូវនៅខេត្តសៀមរាបនេះមួយថ្ងៃហើយមួយថ្ងៃទៀត ជិតកន្លះខែខ្ញុំត្រូវដើរសុំបាយអង្ករអ្នកស្រុកអ្នកភូមិជារៀងរាល់ថ្ងៃ ។ ព្រឹកនេះខ្ញុំតាំងចិត្តថាត្រូវតែឡើងឡានឲ្យរួច ទោះឡើងតែខ្លួនទទេក៏ដោយ ។ ខ្ញុំបានឲ្យកូនឆ្នាំង មុងភួយទៅស្ត្រីម្នាក់ដែលនៅសំណាក់ជិតខ្ញុំអស់រលីង ។ ខ្ញុំខំប្រវាគោងឡើងឡានយោធាវៀតណាមនោះជាមួយគេឯងដែរ តែទោះជាខំយ៉ាងណាក៏គ្មានកម្លាំងកំហែងឡើងរួចឡើយ ។ ឡានជិតចេញហើយ ខ្ញុំបែកញើសរហាម គ្មានសង្ឃឹមថាបានទៅនឹងគេទេ ។ ស្រាប់តែចៃដន្យមានអ៊ិប្រុសម្នាក់ ដែលបម្រុងយកកង់ឡើងលើឡាន ក្រឡេកឃើញខ្ញុំឈរអេះអុញក្បែរនោះ ក៏សួរខ្ញុំថា÷

-ក្មួយចង់ឡើងឡានឬ? ម៉េចមិនឡើងឲ្យលឿនទៅឡានជិតចេញហើយ ។

ខ្ញុំឆ្លើយថា÷

-ខ្ញុំឡើងមិនរួចទេអ៊ំ ។

អ៊ំប្រុសក៏ឲ្យខ្ញុំឡើងជាន់លើកែបកង់របស់គាត់ ។ ខ្ញុំត្រេកអរណាស់ ហើយអ៊ំប្រុសក៏ឡើងតាមពីក្រោយដែរ ។ ប្រហែលថ្ងៃត្រង់ឡានក៏ឈប់នៅស្ពានដើម្បីឲ្យពួកយើងអ្នកជិះចុះដាំបាយទឹកហូប ។ ខ្ញុំចុះមកអង្គុយសំកុកព្រោះគ្មានឆ្នាំង គ្មានអង្ករដាំនឹងគេ ។ ពេលនោះមានបងស្រីម្នាក់ផ្ទះនៅជិតនោះ ស្លៀកសារុងសូត្រ ពាក់អាវម៉ុងតាហ្គុយ ហើយមានកូនស្រីម្នាក់អាយុប្រហែល១០ឆ្នាំ សាច់ឈាមស្រស់ថ្លា បានដើរមកសួរខ្ញុំថា÷

-ប្អូនស្រីហេតុអ្វីមិនដាំបាយហូបនឹងគេ?

ខ្ញុំឆ្លើយថា÷

-ខ្ញុំគ្មានបានឆ្ងាំងអង្ករអីនឹងគេទេបងស្រី ។

បងស្រីដើរសំដៅទៅផ្ទះនៅក្បែរនោះហើយដួសបាយមួយចានស្រូបសម្លម្ជូរខ្ទុះយកមកឲ្យខ្ញុំហូប ។ ខ្ញុំបានថ្លែងអំណរគុណដល់បងស្រីក្រោយពេលហូបបាយហើយ ។ បងស្រីសួរខ្ញុំថាគ្មានគ្រួសារទេឬ? បើនៅម្នាក់ឯង កុំទៅភ្នំពេញអីនៅជាមួយគាត់ហ្នឹងហើយ ។

ខ្ញុំសឹៗដូចត្រូវថ្នាំសណ្តំមិនដឹងឆ្លើយថាម៉េច ។ ពេលឡានស៊ីដ្ឋេ ខ្ញុំក៏លាគាត់ឡើងឡានទៅដោយមានបងប្អូននៅលើឡានជួយទាញដៃឡើង ។

ល្ងាចហើយ ឡានបានយកពួកយើងទៅទម្លាក់ចោលនៅស្គន់ ។ ខ្ញុំចុះពីលើឡានស្មាបគូថខោរហែករយ៉ៃ ព្រោះពុំដឹងអង្គុយលើរបស់អ្វីខ្លះ ។ ខ្ញុំនិងបងប្អូនជម្លៀសឯទៀតសម្រាកនៅក្រោមដើមអំពិលបារាំងធំមួយ ។ ព្រឹកឡើងអ្នកខ្លះក៏រៀបចំឥវ៉ាន់ចេញដំណើរទៅមុខទៀតជាបន្តបន្ទាប់ ។ មានតែអ្នកដែលមានឪពុកម្តាយចាស់ទៅមិនទាន់រួច ត្រូវនៅសម្រាកយកកម្លាំងសិន ។ ខ្ញុំនៅសម្រាកទីនោះមួយថ្ងៃហើយមួយថ្ងៃទៀត ព្រោះគ្មានកម្លាំងទៅមុខនឹងគេ មានអ្នកជម្លៀសខ្លះគេឲ្យអង្ករ ឲ្យឆ្នាំង ខ្លះឲ្យមុងភួយខ្ញុំដណ្តប់ ដូច្នេះខ្ញុំក៏មានទ្រព្យសម្បត្តិខ្លួនឯងឡើងវិញហើយ ។ ខ្ញុំនៅសម្រាកនៅទីនោះបានមួយអាទិត្យ មានបងប្រុសម្នាក់អាយុប្រហាក់ប្រហែលខ្ញុំ ហើយមានកូនស្រីមួយប្រហែល ៤-៥ឆ្នាំ បានមកស្នើខ្ញុំធ្វើជាគូគាប់ដោយគាត់បង្ហាញរបស់មួយដុំនៅចង្កេះខោថែវរបស់គាត់ ។ គាត់ថាអាណិតខ្ញុំណាស់ឃើញនៅម្នាក់ឯង គាត់ធានាចិញ្ចឹមខ្ញុំឲ្យរស់សុខសប្បាយដូចគេឯង ។ ខ្ញុំនៅធ្មឹងគ្មានរំភើបគ្មានញាប់ញ័រ បេះដូងខ្ញុំស្លាប់បាត់ទៅហើយរឿងអីខ្ញុំមានអារម្មណ៍ស្រឡាញ់ប្រុសដទៃទៀត នៅពេលដែលមនុស្សជាទីស្រឡាញ់របស់ខ្ញុំទាំងអស់ ទើបនឹងឃ្លាតចោលខ្ញុំនៅថ្មីៗនៅឡើយ ។ ខ្ញុំឆ្លើយយ៉ាងខ្លីជាមួយគាត់ថា÷

-ខ្ញុំមិនទាន់នឹកនារឿងប្តីសីអីទេ ។

ព្រឹកឡើងបុរសនោះក៏នាំកូនចេញដំណើរទៅភ្នំពេញបាត់ទៅ ។ បួន-ប្រាំថ្ងៃក្រោយ ខ្ញុំក៏ចេញដំណើរសំដៅទីក្រុងភ្នំពេញដែរ ។ ទម្រាំមកដល់ត្រើយខាងកើតអរិយក្សត្រជិតកន្លះខែ ។ ខ្ញុំត្រូវជិះទូកឆ្លងទន្លេ នៅពេលដែលជិះទូកឆ្លងទន្លេ ខ្ញុំចោលភ្នែកមកកើតហើយឃើញដងស្ពានជ្រោយចង្វារដាច់ខ្ទួន ដែលនៅឈរជ្រងោកាត់ទទឹងទន្លេគួរឲ្យស្រណោះបំផុត ។ ខ្ញុំមកដល់ត្រើយគីឡូម៉ែត្រលេខ៧ ។ ទីនោះគឺជាផ្សារមួយយ៉ាងធំមានមនុស្សអ៊ូអរ លក់ដូរនំចំណីគ្រប់បែបយ៉ាង ធ្វើឲ្យខ្ញុំឃ្លានជាខ្លាំង ។ ខ្ញុំកំពុងតែឈរភ្លេចខ្លួននឹងនំចំណី ស្រាប់តែមានដៃមួយមកកេះស្មាខ្ញុំគឺមិត្តសម្លាញ់ស្រីខ្ញុំដែលធ្លាប់ធ្វើការជាមួយគ្នាតាំងពីសង្គមចាស់គឺអារុណ ។ យើងពីរនាក់ឱបរឹតគ្នាយ៉ាងយូរដោយក្តីនឹករឭក ។ អារុណ គេនៅជុំគ្នាប្តីប្រពន្ធគេមិនសូវកម្សត់ដូចខ្ញុំទេ ។ ខ្ញុំបានទៅមើលផ្ទះខ្ញុំនៅម្តុំផ្សារស៊ីឡឹប គ្មានសល់អ្វីទាំងអស់ ហើយបង្អួសទៅមើលកន្លែងប្តីខ្ញុំកប់របស់១០ជំហានពីរបងផ្ទះក៏រកពុំឃើញកន្លែងកប់របស់ ព្រោះគេរើរបងនោះចោល ហើយដាំដើមចេកជំនួសវិញទៅហើយ ។ គ្មានសល់អ្វីទេ លោកឪពុកអ្នកម្តាយ ជីដូនជីតា ប្អូនប្រុស៤នាក់ ។ ក្រោយមក ខ្ញុំបានជួបប្អូនប្រុសទី៤ឈ្មោះហេង សុខម៉ាឡា ដែលវានៅរស់និងជាអ្នកជួយកត់ត្រាប្រលោមលោកសោកនាដកម្មនេះ ។

កន្លះខែក្រោយមក ពួកយើងក៏នាំគ្នាដាក់ពាក្យចូលធ្វើការនៅក្រសួងសុខាភិបាល ។ យើងក៏ត្រូវគេចាត់តាំងឲ្យមកធ្វើការនៅពេទ្យលោកសង្ឃដែលឥឡូវដូរដាក់ជាមន្ទីរពេទ្យព្រះកុសុមៈវិញ ។ ខ្ញុំបានជួបមិត្តភ័ក្រ្តជាច្រើនទៀត មានស្រី មានប្រុស ។ ហើយក៏មានមិត្តប្រុសខ្លះដែលពោះម៉ាយបានសុំរៀបការជាមួយខ្ញុំ តែខ្ញុំគ្មានចិត្តនឹកនារឿងអស់នេះសោះ ។

នៅឆ្នាំ១៩៨០ ខ្ញុំដាច់ចិត្តរៀបការនឹងបុរសម្នាក់ដែលតាមស្រឡាញ់ខ្ញុំយ៉ាងស្វិតស្វាញបំផុត ។ ២៣ឆ្នាំកន្លងហើយខ្ញុំមានកូនអាយុ១៦ឆ្នាំ ។ ចិត្តបំណងថានឹងរួមរស់ជាមួយគ្នា តស៊ូនឹងគ្នារហូតដល់ចាស់ស្លាប់ ប៉ុន្តែបែរជាពុំដូចចិត្តប្រាថ្នាទៅវិញ ។ ទីបំផុតខ្ញុំក៏សម្រេចចិត្តបែកពីគាត់ ព្រោះតែយើងរស់នៅពុំសូវចុះសម្រុងនឹងគ្នា ។ មកដល់ត្រង់វគ្គបញ្ចប់នេះ ដោយសារតែជីវិតហាក់ដូចជារកន័យមិនឃើញ ខ្ញុំសម្រេចចិត្តសង្ខេបបញ្ចប់យ៉ាងសោះកក្រោះបំផុត ។ ជីវិតដូចឆាកល្ខោន ។ ឥឡូវខ្ញុំអាយុ ៥២ឆ្នាំហើយ ផែនដីពិតជាមូលមែន វិលចុះវិលឡើងខ្ញុំនៅតែជាស្ត្រីមេម៉ាយដដែល គួរឲ្យចង់សើចណាស់ ។

កំពុងតែស្មុងអារម្មណ៍ កូនប្រុសពៅខ្ញុំឈ្មោះ សម្បត្តិ បានមកអង្គុយជិតខ្ញុំ ហើយវាហុចកាវ៉ែមកឲ្យខ្ញុំមួយដុំដែលជាទម្លាប់របស់វាពេលត្រឡប់មកពីរៀនរាល់ថ្ងៃ។ វាលូកដៃជូតទឹកភ្នែកលើផែនថ្ពាល់ដ៏ជ្រីវជ្រួញរបស់ខ្ញុំ ។

“ស្រមោលបង” សូមលំឱនកាយគោរពលាអស់លោកអ្នកអានទាំងអស់ដោយចិត្តសោកស្តាយ ហើយរង់ចាំការទិតៀនពីអស់លោកទាំងអស់ដោយចិត្តរីករាយនឹងសូមអភ័យទោសផងដែរចំពោះមិត្តកម្សត់ទាំងអស់ក្នុងរបបពួកឃាតករអាវខ្មៅនេះ បើមានការខុសឆ្គងអ្វី ។ សូមផ្ញើការនឹករឭកចំពោះមិត្តកម្សត់ទាំងអស់ដែលឥឡូវមិនដឹងទៅដល់ទីណាខ្លះ សូមមិត្តទាំងអស់បានប្រកបតែនឹងសេចក្តីសុខគ្រប់ប្រការ ។

សូមថ្លែងអំណរគុណចំពោះគ្រួសារក្មួយប្រុស ឡាច សំរេង ដែលបានជួយដាក់កម្លាំងចិត្តដល់ខ្ញុំទើបរឿងស្រមោលបងនេះអាចកើតជារូបរាងឡើង ។

**រេហង សុខផាន់ណា**

## ដំណឹងសួររកបងប្រុស


ស៊ុន សុខវិជ្ជា

ខ្ញុំបាទឈ្មោះ ស៊ុន សុខវិជ្ជា ស្រុកកំណើតនៅភូមិទី៣ ឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ព្រាំ ញ៉ែម ម្តាយឈ្មោះ នួន អ្នកទាំងពីរស្លាប់នៅជំនាន់ប៉ុលពត ។ ខ្ញុំមានបងប្អូននាក់ ទី១) ឈ្មោះ អួន ហៅ អឿន (ប្រុស) ទី២) រ៉ែន (ស្លាប់) ទី៣) ឈ្មោះ ពេញ (ស្លាប់) និងរូបខ្ញុំ ។ ខ្ញុំបាទសូមសួររកឈ្មោះ អួន ហៅ អឿន បានបែកគ្នាកាលពីចុងឆ្នាំ១៩៧៦ នៅមន្ទីរកុមារទួលគោកភ្នំពេញ ។សព្វថ្ងៃមិនដឹងជាបងប្រុសរស់នៅកន្លែងណា ប្រសិនបើបងបានឮដំណឹង ឬញាតិមិត្តបានស្គាល់ឈ្មោះនេះសូមផ្តល់ដំណឹងតាមទូរស័ព្ទលេខ ០១១ ៧៧៧ ៧២២ ឬមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។

សូមអរគុណ ។


ព្រាំ ញ៉ែម នួន

## ដំណឹងសួររកប្អូននិងក្មួយ


កែប សុផា មុនឆ្នាំ១៩៧៥

នាងខ្ញុំឈ្មោះ កែប សុផា ហៅ មោង អ៊ីម អាយុ៤៩ឆ្នាំ សព្វថ្ងៃរស់នៅគីឡូម៉ែត្រលេខ៦ ទីក្រុងភ្នំពេញ ។ សូមសួររកឈ្មោះ មោង សាម៉េត (ប្អូនប្រុស) និង គង់ មុន្នី (ក្មួយប្រុស) ។ អ្នកទាំងពីរកើតឆ្នាំថោះដូចគ្នា បច្ចុប្បន្នអាយុប្រហែល៤១ឆ្នាំ ។ អ្នកទាំងពីរបានបែកចេញពីក្រុមគ្រួសារនៅក្នុងឆ្នាំ១៩៧៨ គឺនៅពេលដែលខ្មែរក្រហមចាប់ក្រុមគ្រួសារយកទៅសម្លាប់ ។ ពេលនោះអ្នកទាំងពីរធ្វើការនៅកងចល័តភូមិភាគ ។ ក្រោយមកបងបានឮដំណឹងថាប្អូនរស់នៅក្នុងតំបន់ខ្មែរក្រហម ។

បើប្អូន ក្មួយ បានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះទាំងពីរខាងលើនេះ សូមផ្តល់ដំណឹងមកនាងខ្ញុំតាមទូរស័ព្ទលេខ ០១២ ៤១៤ ៦៩១ ឬមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ។


ឪពុកម្តាយរបស់ កែប សុផា



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនិងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 54, June 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**